**UNITED NATIONS**
Cambodia Office of the High
Commissioner for Human Rights

**NATIONS UNIES**
Bureau du Haut Commissaire
aux droits de l'homme au Cambodge

Special Representative of the Secretary-General
for human rights in Cambodia
តំណាងពិសេសរបស់លោកអគ្គលេខាធិការទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា

**OHCHR**

# សម្បទានដីសេដ្ឋកិច្ចនៅកម្ពុជា

# ទស្សនៈវិស័យខាងសិទ្ធិមនុស្ស

ខែ មិថុនា ឆ្នាំ ២០០៧

10, Street 302, Sangkat Boeng Keng Kang I, Khan Chamcar Mon, Phnom Penh Cambodia
Tel: +(855) 23 987 671 / 987 672 / 993 590 / 993 591 or 216 342 Fax: +(855) 23 212 579 or 213 587
E-mail: cambodia@ohchr.org Website: http://cambodia.ohchr.org

# មាតិកា

*ទំព័រ*


សេចក្តីសង្ខេប ..... ១

១. សេចក្តីផ្តើម ..... ៣

២. ក្របខ័ណ្ឌច្បាប់សំរាប់សម្បទានដីសេដ្ឋកិច្ច ..... ៥

២.១. ការធ្វើចំណាត់ថ្នាក់ដី និងកម្មសិទ្ធិលើដីធ្លី ..... ៥

២.២. ច្បាប់ភូមិបាល និងសម្បទានដីសេដ្ឋកិច្ច ..... ៦

២.៣. អនុក្រឹត្យស្តីពីសម្បទានដីសេដ្ឋកិច្ច ..... ៧

២.៤. ទំនាក់ទំនងជាមួយច្បាប់ដទៃទៀត ..... ៩

៣. ទិដ្ឋភាពទូទៅនៃសម្បទានដីសេដ្ឋកិច្ចនៅកម្ពុជា ..... ១១

៣.១. ចំនួនសម្បទានដីសេដ្ឋកិច្ចដែលបានផ្តល់ ..... ១១

៣.២. លេខាធិការដ្ឋានបច្ចេកទេសសម្បទានដីសេដ្ឋកិច្ច ..... ១៣

៣.៣. ការត្រួតពិនិត្យឡើងវិញសម្បទានដីសេដ្ឋកិច្ចដែលមានស្រាប់ ..... ១៣

៣.៤. ការទទួលបានព័ត៌មាន និងឯកសារផ្សេងៗ ..... ១៣

៤. ច្បាប់ និងការអនុវត្តន៍ជាក់ស្តែង ..... ១៥

៤.១. ការអនុវត្តតាមសេចក្តីតម្រូវរបស់ច្បាប់ និងនីតិវិធីច្បាប់ ..... ១៥

៤.២. ដីឯកជនរបស់រដ្ឋ និងផែនការប្រើប្រាស់ដី ..... ១៥

៤.៣. ការពិគ្រោះយោបល់ជាសាធារណៈ និង ការវាយតំលៃហេតុប៉ះពាល់ខាងបរិស្ថាន និងសង្គម ..... ១៧

៤.៤. ទំហំដីសម្បទាន និងកម្មសិទ្ធិ ..... ១៨

៤.៥. ការគោរពក្របខ័ណ្ឌស្តីពីការការពារព្រៃឈើ ..... ២០

៥. ផលប៉ះពាល់នៃសម្បទាន ..... ២១

៥.១. ការទន្ទ្រានលើដីកសិកម្ម និងដីសំរាប់ចិញ្ចឹមសត្វពាហណៈ ..... ២១

៥.២. ការបាត់បង់សិទ្ធិប្រើប្រាស់ព្រៃឈើ និងអនុផលព្រៃឈើ ..... ២៣

៥.៣. ការផ្លាស់ប្តូរទីកន្លែងរស់នៅ ..... ២៤

៥.៤. ផលប៉ះពាល់លើផ្នែកសំខាន់ខាងវប្បធម៌ និងខាងជំនឿ ........................................... ២៥

៥.៥. ការបំផ្លិចបំផ្លាញបរិស្ថាន .................................................................................. ២៦

៦. ផលប៉ះពាល់លើជនជាតិដើមភាគតិច ............................................................................ ២៧

៦.១. សារសំខាន់នៃដីធ្លី និងធនធានធម្មជាតិចំពោះជនជាតិដើមភាគតិច ............................ ២៧

៦.២. សម្បទានដីសេដ្ឋកិច្ច និងសម្បទានដទៃទៀតនៅក្នុងតំបន់ជនជាតិដើមភាគតិច .............. ២៨

៦.៣. ការផ្ទេរកម្មសិទ្ធិដីធ្លីជនជាតិដើមភាគតិច និងការចុះបញ្ជីកម្មសិទ្ធិដីសមូហភាព ............. ២៨

៦.៤. ផលប៉ះពាល់ផ្សេងទៀតលើសហគមន៍ជនជាតិដើមភាគតិច ....................................... ៣០

៧. សិទ្ធិទទួលបានការដោះស្រាយប្រកបដោយប្រសិទ្ធិភាព .................................................. ៣០

៧.១. វិធានការរបស់សហគមន៍ ..................................................................................... ៣០

៧.២. បរិយាកាសនៃការបំពេញការងាររបស់សង្គមស៊ីវិល និងសហគមន៍ ................................ ៣២

៧.៣. ការប្រើប្រាស់ប្រព័ន្ធយុត្តិធម៌ ................................................................................ ៣៣

៨. តើអ្នកណាទទួលផលពីសម្បទានដីសេដ្ឋកិច្ច? ................................................................ ៣៤

៨.១. អ្នកទទួលផលពីសម្បទានដីសេដ្ឋកិច្ច ...................................................................... ៣៤

៨.២. ការបំពេញតាមគោលដៅនៃសម្បទានដីសេដ្ឋកិច្ច ....................................................... ៣៥

៨.៣. គំនិតផ្តួចផ្តើមអភិវឌ្ឍន៍របស់សហគមន៍ និងសេចក្តីត្រូវការរបស់សហគមន៍ ..................... ៣៦

៩. សេចក្តីសន្និដ្ឋាន ........................................................................................................ ៣៨

១០. អនុសាសន៍ .............................................................................................................. ៤០

ឧបសម្ព័ន្ធ ១ : សម្បទានដីសេដ្ឋកិច្ចដែលបានផ្តល់ ............................................................ ៤២

ឧបសម្ព័ន្ធ ២ : សម្បទានដីសេដ្ឋកិច្ចដែលបានលុបចោល ..................................................... ៥៥

# សេចក្តីសង្ខេប

ដីទំហំ ៩៤៣.០៦៩ ហិកតា នៅតំបន់ជនបទនៃប្រទេសកម្ពុជា ត្រូវបានផ្តល់ជាសម្បទានដីសេដ្ឋកិច្ច ឱ្យក្រុមហ៊ុនឯកជននានា សំរាប់ការអភិវឌ្ឍន៍ដំណាំកសិ-ឧស្សាហកម្ម ។ ដីសម្បទានចំនួន ៣៦ ក្នុងចំណោម ដីសម្បទាន ៥៩ ត្រូវបានផ្តល់ឱ្យពាណិជ្ជករបរទេស ឬឥស្សរជនល្បីឈ្មោះខាងនយោបាយ និងពាណិជ្ជកម្ម ។ ស្ថិតិនៃដីសម្បទានទាំងនេះ មិនរាប់បញ្ចូលនូវសម្បទានដីសេដ្ឋកិច្ចដែលមានទំហំតូច ( មិនលើសពី ១០០០ ហិកតា) ដែលបានផ្តល់នៅថ្នាក់ខេត្ត-ក្រុង ដោយសារព័តិមានស្តីពីចំនួន និងកម្មសិទ្ធិនៃដីសម្បទានទាំងនេះ មិនត្រូវបានគេបញ្ចេញឱ្យដឹង ។

ចាប់តាំងពីឆ្នាំ១៩៩៦ តំណាងពិសេសជាបន្តបន្ទាប់នៃលោកអគ្គលេខាធិការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា បានសំដែងកង្វល់អំពីផលប៉ះពាល់នៃសម្បទានដីសេដ្ឋកិច្ចទៅលើសិទ្ធិមនុស្ស និងជីវភាពរស់នៅរបស់សហគមន៍ជនបទនានា ។ កង្វល់ដែលបានលើកឡើងនៅទសវត្សរ៍កន្លងមក រហូតមកទល់បច្ចុប្បន្ននេះនៅតែមានជាដដែល ។

ឫសគល់នៃកង្វល់ទាំងនេះ គឺភាពទន់ខ្សោយក្នុងការប្រត្តិបត្តិ និងការអនុវត្តន៍តាមសេចក្តីតម្រូវរបស់ច្បាប់ភូមិបាល និងអនុក្រឹត្យស្តីពីសម្បទានគោលដៅសេដ្ឋកិច្ច ដែលគ្រប់គ្រងលើការផ្តល់ និងការគ្រប់គ្រងលើសម្បទានដីសេដ្ឋកិច្ច ។ លក្ខខណ្ឌចម្បងៗសំរាប់ការផ្តល់សម្បទាន ដូចជាការចុះបញ្ជីថាជាដីឯកជនរបស់រដ្ឋ និងការពិគ្រោះយោបល់ជាសាធារណៈ និងការវាយតំលៃហេតុប៉ះពាល់បរិស្ថាន និងសង្គម នៅមិនទាន់បានធ្វើនៅឡើយ ។ ដូចគ្នានេះដែរ ការកំរិតអំពីទំហំ និងកម្មសិទ្ធិសម្បទានដីសេដ្ឋកិច្ចមិនត្រូវបានអនុវត្តន៍ត្រឹមត្រូវនៅឡើយ ។ បុគ្គលមួយចំនួនបានប្រើប្រាស់ឈ្មោះក្រុមហ៊ុនផ្សេង១គ្នា ដើម្បីទាញអត្ថប្រយោជន៍ពី ដីសម្បទានច្រើនឡូង ដែលផ្ទុយទៅនឹងច្បាប់ភូមិបាល និងដើម្បីទទួលបានសម្បទានជាប់ព្រំប្រទល់គ្នាសំរាប់គោលបំណងតែមួយ ដើម្បីជៀសវាងពីការកំរិតទំហំ១០.០០០ ហិកតា ។ សម្បទានជាច្រើនត្រូវបានផ្តល់លើតំបន់ព្រៃ និងក្នុងអតីតតំបន់ព្រៃសម្បទាន ផ្ទុយនឹងច្បាប់ស្តីពីព្រៃឈើ និងបទបញ្ញត្តិស្តីពីព្រៃឈើ ។ ទោះបីជាមានការបំពានច្បាប់ទាំងនេះក៏ដោយ ក៏មិនឃើញមានការត្រួតពិនិត្យជាប្រព័ន្ធណាមួយលើសម្បទានទាំងនេះ ដូចបានតម្រូវដោយអនុក្រឹត្យ ស្តីពីសម្បទានដីសេដ្ឋកិច្ច ។ ជាបន្ថែមទៀត ប្រព័ន្ធយុត្តិធម៌ខកខានក្នុងការលើកស្ទួយសិទ្ធិ របស់សហគមន៍ដែលរងផលប៉ះពាល់ និងការគោរពចំពោះច្បាប់ និងការដាក់ឱ្យក្រុមហ៊ុនទទួលខុសត្រូវចំពោះទង្វើរបស់ខ្លួន ។

ជាលទ្ធផល សម្បទានដីសេដ្ឋកិច្ចបន្តប៉ះពាល់អវិជ្ជមានលើសិទ្ធិមនុស្ស និងជីវភាពរស់នៅរបស់សហគមន៍ជនបទដែលពឹងផ្អែកលើដីធ្លី និងធនធានព្រៃឈើសំរាប់ចិញ្ចឹមជីវិត ។ កង្វល់ដែលបានសំដែងជារួមគឺ ការទន្ទ្រានលើដីកសិកម្ម និងដីវាលស្មៅសំរាប់ចិញ្ចឹមសត្វពាហណៈ និងការបាត់បង់មុខរបរចិញ្ចឹមជីវិត ការទន្ទ្រានលើដីព្រៃ និងការបាត់បង់សិទ្ធិប្រមូលអនុផលព្រៃឈើ ផលប៉ះពាល់លើផ្នែកដែលមានសារៈសំខាន់ខាងវប្បធម៌ និងជំនឿ

ការជម្លៀសចេញ និងការធ្វើឱ្យខូចបរិស្ថាន ។ របាយការណ៍លើកឡើងពីកង្វល់ ជាពិសេសអំពីផលប៉ះពាល់របស់សម្បទានដីសេដ្ឋកិច្ច និងសម្បទានដទៃទៀតលើសហគមន៍ជនជាតិដើមភាគតិច ដែលសិទ្ធិកម្មសិទ្ធិលើដីសមូហភាពរបស់ពួកគេត្រូវបានការពារដោយច្បាប់កម្ពុជា ។ ការផ្ទេរសិទ្ធិដីធ្លីរបស់ជនជាតិដើមភាគតិច តាមរយៈការផ្ដល់សម្បទានផ្សេងៗកំពុងធ្វើឱ្យខូចលទ្ធភាពរបស់សហគមន៍ជនជាតិដើមភាគតិច ក្នុងការចុះបញ្ជីកម្មសិទ្ធិសមូហភាពរបស់ខ្លួនលើដីព្រៃពៃណី និងក្នុងការអនុវត្តន៍សិទ្ធិរបស់ពួកគេលើដីធ្លីតាមច្បាប់ភូមិបាល ។

ជំនួសឱ្យការជំរុញការអភិវឌ្ឍន៍នៅជនបទ និងការកាត់បន្ថយភាពក្រីក្រ សម្បទានដីសេដ្ឋកិច្ចបានធ្វើឱ្យខូចដល់សិទ្ធិ និងជីវភាពរស់នៅរបស់សហគមន៍ជនបទនានាក្នុងប្រទេសកម្ពុជា ។ ដើម្បីជំរុញដល់ការគ្រប់គ្រងប្រកបដោយចិរភាព និងសមធម៌លើដីធ្លី និងធនធានធម្មជាតិរបស់កម្ពុជា សំរាប់ជាប្រយោជន៍ដល់ប្រជាជនកម្ពុជាគ្រប់រូប លោកតំណាងពិសេសបានធ្វើអនុសាសន៍ជាច្រើនហូរហែរ ពាក់ព័ន្ធនឹងការអនុវត្តន៍ច្បាប់ភូមិបាល និងអនុក្រឹត្យស្ដីពីសម្បទានដីសេដ្ឋកិច្ច ការការពារ និងការអនុវត្តន៍សិទ្ធិលើដីធ្លីរបស់ជនជាតិដើមភាគតិច សិទ្ធិទទួលបានព័ត៌មានពាក់ព័ន្ធនឹងសម្បទានដីសេដ្ឋកិច្ច និងអំពីអ្នកដែលទទួលផលប្រយោជន៍ពីសម្បទានទាំងនេះ និងការប្រតិបត្តិច្បាប់ព្រមទាំងការទទួលបានការដោះស្រាយប្រកបដោយប្រសិទ្ធិភាព សំរាប់សហគមន៍ដែលទទួលផលប៉ះពាល់ ។ របាយការណ៍នេះក៏បានផ្ដល់ជាអនុសាសន៍ ឱ្យពិចារណាអំពីគំរូកសិកម្មតាមជំរើសផ្សេង ដោយផ្ដល់អាទិភាពដល់កសិកម្មដែលមានទ្រង់ទ្រាយតូច និងដល់គំនិតផ្ដួចផ្ដើមអភិវឌ្ឍន៍របស់សហគមន៍នានា ។ អនុសាសន៍ទាំងនេះមានចែងលំអិតនៅផ្នែកចុងបញ្ចប់នៃរបាយការណ៍នេះ ។

# ១. សេចក្តីផ្តើម

ប្រទេសកម្ពុជា ជាសង្គមដែលពឹងផ្អែកវិស័យកសិកម្មជាសំខាន់ ហើយប្រជាពលរដ្ឋភាគច្រើននៃប្រទេសនេះពឹងផ្អែកលើដីធ្លី និងធនធានធម្មជាតិ ដូចជាព្រៃឈើ និង ត្រី ដើម្បីស្វែរភាពនៃជីវភាពរស់នៅ ។ នៅតំបន់ជនបទនៃប្រទេសកម្ពុជា ដី ផ្សារភ្ជាប់យ៉ាងជ្រាលជ្រៅទៅនឹងជីវភាពវប្បធម៌ និងជំនឿ នៃសហគមន៍ជនជាតិដើមភាគតិច និង សហគមន៍មិនមែនជនជាតិដើមភាគតិច ។

តាំងពីដើមទសវត្សឆ្នាំ ១៩៩០មក រដ្ឋាភិបាលកម្ពុជា បានផ្តល់ដីទំហំធំៗជាច្រើនអោយក្រុមហ៊ុនឯកជន ដើម្បីធ្វើវិនិយោគលើចំការឈើដាំ និងកសិកម្មទ្រង់ទ្រាយធំ ។ការធ្វើសម្បទានដីនេះ ធ្វើឱ្យមានផលប៉ះពាល់ អវិជ្ជមានដល់សិទ្ធិមនុស្ស និងជីវភាពរស់នៅ របស់សហគមន៍រស់នៅតាមជនបទនៃប្រទេសកម្ពុជា ។

នៅក្នុងខែវិច្ឆិកា ឆ្នាំ២០០៤ លោកតំណាងពិសេសមុន បានចេញរបាយការណ៍មួយ ដែលបានបង្ហាញពីទស្សនវិស័យខាងសិទ្ធិមនុស្សលើសម្បទានដីគោលដៅសេដ្ឋកិច្ច(“របាយការណ៍ឆ្នាំ២០០៤”) ។ របាយការណ៍នេះផ្តល់នូវបច្ចុប្បន្នភាព លើការវិវត្តន៍ជាគន្លឹះមួយចំនួន ចាប់តាំងពីរបាយការណ៍ឆ្នាំ២០០៤ មក រួមទាំងក្របខ័ណ្ឌច្បាប់ និងបទបញ្ញាដែលបានពិនិត្យឡើងវិញមួយចំនួន សំរាប់ការផ្តល់ និងការគ្រប់គ្រងសម្បទានដីសេដ្ឋកិច្ច និងការអនុវត្តន៍ក្របខ័ណ្ឌនេះ ។ ផលប៉ះពាល់នៃសម្បទានដីសេដ្ឋកិច្ចបន្តមានដូចគ្នាទៅនឹងលំនាំនៃផលប៉ះពាល់ទាំងឡាយ ដែលបានចងក្រងក្នុងរបាយការណ៍ឆ្នាំ២០០៤ ដែលបានបញ្ជាក់ថា សម្បទានបានធ្វើអោយខូចអត្ថប្រយោជន៍នៃការចិញ្ចឹមជីវិតរបស់សហគមន៍ជនបទ ហើយពួកគេបានទទួលផលតិចតួចបំផុតពីសម្បទានទាំងនេះ ហើយមិនមានដំណោះស្រាយ ឬការជួយអន្តរាគមន៍ដោយប្រសិទ្ធិភាពទេ នៅពេលដែលសិទ្ធិរបស់ពួកគេត្រូវបានរំលោភបំពាន ។

របាយការណ៍ឆ្នាំ២០០៤ បានដាក់ចេញនូវអនុសាសន៍ជាច្រើន រួមទាំងអនុសាសន៍មួយ ដែលស្នើឱ្យធ្វើការពិចារណាឡើងវិញអំពីប្រព័ន្ធសម្បទាន និងរកជំរើសផ្សេងទៀតសំរាប់ការអភិវឌ្ឍន៍កសិកម្ម សំរាប់ជាប្រយោជន៍ដល់ប្រជាពលរដ្ឋកម្ពុជានៅតំបន់ជនបទ ។ ទោះជាយ៉ាងណាក៏ដោយ សម្បទានដីគោលដៅសេដ្ឋកិច្ចនៅតែត្រូវបានរដ្ឋាភិបាល មើលឃើញថាជាមធ្យោបាយមួយសំរាប់ការអភិវឌ្ឍន៍សេដ្ឋកិច្ចនៅកម្ពុជា ដោយទោះបីជាវាមិនមានផលប្រយោជន៍សេដ្ឋកិច្ចយ៉ាងជាក់ស្តែង ផ្តល់អោយប្រទេសនេះ និងប្រជាជនរបស់ខ្លួនក៏ដោយ ។

អនុក្រឹត្យស្តីពីសម្បទានដីសេដ្ឋកិច្ច ត្រូវបានអនុម័តក្នុងខែធ្នូ ឆ្នាំ២០០៥ នេះគឺជាការបោះជំហានទៅមុខដ៏សំខាន់ក្នុងការបង្កើតក្របខ័ណ្ឌច្បាប់ និងបទបញ្ញាសំរាប់ការផ្តល់ និងការគ្រប់គ្រងសម្បទាន រួមទាំងសេចក្តីតម្រូវឱ្យមានការពិគ្រោះយោបល់ជាសាធារណៈ និងការវាយតំលៃហេតុប៉ះពាល់បរិស្ថាន និងសង្គម ។ ទោះជាយ៉ាងណាក៏ដោយ បទបញ្ញត្តិទាំងនេះ មិនត្រូវបានអនុវត្ត និងប្រតិបត្តតាមដោយត្រឹមត្រូវទេ និងមិនមានការពិនិត្យឡើងវិញចំពោះ

សម្បទានដែលមានស្រាប់ ហើយសម្បទានដីសេដ្ឋកិច្ចនៅតែបន្តផ្តល់លើដីព្រៃ និងដីរបស់ជនជាតិដើមភាគតិច ដោយរំលោភបំពានច្បាប់ជាដដែល ។

ការរីកចំរើនមួយជំហានទៀតដ៏គួរឱ្យស្វាគមន៍ គឺការបង្កើតវិបសាយចុះផ្សាយព័ត៌មានស្តីពីសម្បទានដីសេដ្ឋកិច្ច និងការប្រាប់ឱ្យដឹងពីចំនួន និងទីតាំងនៃសម្បទានដីសេដ្ឋកិច្ចដែលបានផ្តល់រួចហើយ និងព័ត៌មានជាមូលដ្ឋានស្តីពីសម្បទានិក ។ ទោះជាយ៉ាងណាក៏ដោយ ក៏នៅតែតម្រូវឱ្យមានតម្លាភាព និងការទទួលខុសត្រូវច្រើនថែមទៀត ក្នុងការគ្រប់គ្រងធនធានរបស់រដ្ឋ ។ ជាពិសេសគឺមិនទាន់មានព័ត៌មានស្តីពីសម្បទានដីសេដ្ឋកិច្ច ដែលអាជ្ញាធរខេត្តបានផ្តល់នោះទេ ។

សំនួរជាគន្លឹះមួយសួរថា តើអ្នកណាទទួលផលពីសម្បទានដីសេដ្ឋកិច្ច និងការផ្តល់ដីធ្លី និងធនធានធម្មជាតិរបស់កម្ពុជា ។ ព័ត៌មានដែលអាចរកបាននៅលើវិបសាយរបស់ក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ បង្ហាញថាសម្បទានដីសេដ្ឋកិច្ចជាច្រើន ត្រូវបានផ្តល់អោយដោយមានទំនោរគាំទ្រប្រយោជន៍ក្រុមហ៊ុនបរទេស និងឥស្សរជននយោបាយ និងពួកពាណិជ្ជករ រួមទាំងសមាជិកព្រឹទ្ធសភា និងឧកញ៉ា[១] មួយចំនួន ។ សម្បទានទាំងនេះ នៅមិនឃើញមានផ្តល់ផលប្រយោជន៍ដល់សហគមន៍ជនបទ ហើយក៏មិនមានរួមចំណែកក្នុងចំណូលរដ្ឋនៅឡើយ ។

ដូចបានកត់សំគាល់ដោយធានាគារពិភពលោកក្នុងការវាយតំលៃពីភាពក្រីក្រ ឆ្នាំ២០០៦ ថា ភាពក្រីក្រកើតមានច្រើននៅតំបន់ជនបទ ដែលចំនួន ៩១ភាគរយ នៃប្រជាពលរដ្ឋក្រីក្ររស់នៅតំបន់ជនបទ ។ ភាពក្រីក្រនៅជនបទនឹងនាំឱ្យក្លាយជាបញ្ហាធ្ងន់ធ្ងរថែមទៀតនៅកម្ពុជា ប្រសិនបើសហគមន៍ទាំងនោះ នៅតែត្រូវគេដកហូតយកដីធ្លី និងប្រភពធនធានសំរាប់ចិញ្ចឹមជីវិតរបស់ពួកគេ ។ វិធានការជាបន្ទាន់ត្រូវតែចាត់អោយមានឡើង ដើម្បីធានាការគ្រប់គ្រងប្រកបដោយចិរភាពលើដីធ្លី និងធនធានធម្មជាតិរបស់កម្ពុជា និងការបែងចែកប្រកបដោយ សមធម៌នូវផលប្រយោជន៍ដែលទទួលបានមកពីការលូតលាស់សេដ្ឋកិច្ចរបស់ខ្លួន ។

---

[១] ឧកញ៉ា " គឺជាងារមួយដែលបានផ្តល់ឱ្យ " សប្បុរសជនណាម្នាក់ " ដែលបានប្រគល់ប្រាក់ ១០០.០០០ ដុល្លារ ឱ្យរដ្ឋ ជាទឹកប្រាក់ ឬជាសំភារៈ ។ ងារនេះត្រូវបានព្រះមហាក្សត្រប្រទាន តាមសំណើររបស់រាជរដ្ឋាភិបាលកម្ពុជា ។

## ២. ក្របខ័ណ្ឌច្បាប់សំរាប់សម្បទានដីសេដ្ឋកិច្ច

រាជរដ្ឋាភិបាលកម្ពុជាគឺជាភាគីមួយនៃសន្ធិសញ្ញាសិទ្ធិមនុស្សសំខាន់ៗ រួមទាំងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ អនុសញ្ញាអន្តរជាតិស្តីពីការបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍។ សន្ធិសញ្ញាទាំងនេះ រួមជាមួយសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្សធានាការពារសិទ្ធិលើដីធ្លី និងសិទ្ធិមិនត្រូវបានគេដកហូតយកដីធ្លីតាមទំនើងចិត្ត សិទ្ធិមានកំរិតជីវភាពរស់នៅសមរម្យរួមទាំងស្បៀងអាហារ និងផ្ទះសម្បែង សិទ្ធិស្វ័យសំរេច និងសិទ្ធិមិនត្រូវបានគេដកហូតមធ្យោបាយសំរាប់ចិញ្ចឹមជីវិតរបស់ខ្លួន សិទ្ធិសេរីភាពក្នុងការសំដែងមតិ និងសិទ្ធិក្នុងការប្រជុំ សិទ្ធិស្មើគ្នាចំពោះមុខច្បាប់ និងសិទ្ធិទទួលបានការការពារស្មើគ្នាដោយច្បាប់ និងសិទ្ធិទទួលបានការដោះស្រាយប្រកបដោយប្រសិទ្ធិភាព។

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា បានបញ្ចូលទៅក្នុងច្បាប់ជាតិនូវការធានាការពារសិទ្ធិមនុស្ស ដែលមានចែងក្នុងសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងសន្ធិសញ្ញាសិទ្ធិមនុស្សសំខាន់ៗ ហើយជាពិសេស ការពារសិទ្ធិកម្មសិទ្ធិលើដីធ្លីរបស់ប្រជាពលរដ្ឋកម្ពុជា និងសេរីភាពក្នុងការសំដែងមតិ និងការជួបប្រជុំ។

### *២.១. ការធ្វើចំណាត់ថ្នាក់ដី និងកម្មសិទ្ធិលើដីធ្លី*

យោងតាមមាត្រា១៥ នៃច្បាប់ភូមិបាល និងអនុក្រឹត្យស្តីពីការគ្រប់គ្រងដីរដ្ឋ ដីសាធារណៈរបស់រដ្ឋ គឺជាដីដែលប្រើប្រាស់សំរាប់ផលប្រយោជន៍សាធារណៈ ហើយដែលរួមមានទាំងទ្រព្យដែលកើតឡើងពីធម្មជាតិ ដូចជាព្រៃឈើ។ ដីឯកជនរបស់រដ្ឋ គឺជាដីទាំងឡាយណា ដែលមិនមែនជាកម្មសិទ្ធិ ឬកាន់កាប់ដោយឯកជន ឬ សមូហភាពដូចមានចែងក្នុងច្បាប់ភូមិបាល។ អនុក្រឹត្យស្តីពីការគ្រប់គ្រងដីរដ្ឋ បានដាក់ចេញនូវក្របខ័ណ្ឌសំរាប់ធ្វើការកំណត់ដីរដ្ឋ ការរៀបចំ ការចុះបញ្ជី និងការធ្វើចំណាត់ថ្នាក់ដីរដ្ឋ និងកំណត់អំពីសេចក្តីតម្រូវឱ្យមានគោលការណ៍ណែនាំផ្នែករដ្ឋបាលបន្ថែមទៀត។

ក្រោមច្បាប់ភូមិបាល បុគ្គលណាម្នាក់ដែលកាន់កាប់ដោយសន្តិវិធី ដោយគ្មានការជំទាស់ លើដីដែលមិនមែនជាដីសាធារណៈរបស់រដ្ឋ សំរាប់រយៈពេល ៥ឆ្នាំ មុនការប្រកាសឱ្យប្រើច្បាប់ភូមិបាល មានសិទ្ធិស្នើសុំប័ណ្ណកម្មសិទ្ធិស្ថាពរ។ បុគ្គលទាំងឡាយណាដែលបានកាន់កាប់ដីរយៈពេលតិចជាង ៥ឆ្នាំ អាចស្នើសុំប័ណ្ណកម្មសិទ្ធិស្ថាពរបាន បន្ទាប់ពីរយៈពេល ៥ឆ្នាំ។ ទោះជាយ៉ាងណាក៏ដោយ ដូចបានកត់សំគាល់ក្នុងរបាយការណ៍ឆ្នាំ២០០៤ ភាគច្រើននៃប្រជាពលរដ្ឋនៅជនបទមិនមានឯកសារទទួលស្គាល់កម្មសិទ្ធិដីធ្លីរបស់ពួកគេទេ ម្យ៉ាងដោយសារពួកគេយល់ថា វាមិនមែនជាការចាំបាច់ត្រូវមានប័ណ្ណកម្មសិទ្ធិ ម្យ៉ាងទៀតដោយសារពួកគេមិនមានលទ្ធភាពដើម្បីទទួលបានប័ណ្ណកម្មសិទ្ធិ។

*២.២. ច្បាប់ភូមិបាល និងសម្បទានដីសេដ្ឋកិច្ច*

ច្បាប់ភូមិបាល ត្រូវបានប្រកាសឱ្យប្រើនៅថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ អនុញ្ញាតឱ្យផ្តល់សម្បទានដី ដែលឆ្លើយតបទៅនឹងគោលដៅសង្គម ឬសេដ្ឋកិច្ច[២] ។ ច្បាប់ភូមិបាលក៏មានចែងអំពី "សម្បទានប្រភេទផ្សេងទៀត" រួមទាំងសម្បទានរ៉ែ សម្បទាននេសាទ សម្បទានកំពង់ផែ និងការអភិវឌ្ឍន៍ឧស្សាហកម្ម ដែលមិនស្ថិតក្រោមបទបញ្ញត្តិនៃច្បាប់នេះទេ ។ សម្បទានដីត្រូវសំអាងលើលិខិតគតិយុត្តិជាក់លាក់ ដែលបានចេញមុនការកាន់កាប់ដី ដោយអាជ្ញាធរមានសមត្ថកិច្ច ហើយត្រូវតែចុះបញ្ជីនៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ។

សម្បទានដីសេដ្ឋកិច្ច អាចធ្វើឡើងបានតែនៅលើដីឯកជនរបស់រដ្ឋប៉ុណ្ណោះ សំរាប់រយៈពេលអតិបរមា៩៩ ឆ្នាំ ។ សម្បទានទាំងនេះមិនអាចបង្កើតសិទ្ធិកម្មសិទ្ធិលើដីនោះបានឡើយ ហើយក្រៅតែពីសិទ្ធិផ្ទេរដីសម្បទាន សម្បទានិកមានសិទ្ធិដទៃទៀត ដែលដូចគ្នាទៅនឹងសិទ្ធិកម្មសិទ្ធិ នៅក្នុងរយៈពេលនៃកិច្ចសន្យា ។

សម្បទានដីសេដ្ឋកិច្ច មិនត្រូវមានទំហំលើសពី ១០.០០០ ហិកតាឡើយ ហើយសម្បទានដីដែលសំរេចហើយនៅមុនការអនុម័តច្បាប់ភូមិបាលដែលមានទំហំលើសការកំណត់នេះ ត្រូវកាត់បន្ថយ ដើម្បីឱ្យស្របតាមការកំណត់ ប៉ុន្តែមានការលើកលែងជាពិសេស ក្នុងករណីដែលការកាត់បន្ថយនេះមានឥទ្ធិពលធ្វើអោយខូចប្រយោជន៍ អាជីវកម្មដែលកំពុងមានដំណើរការ ។[៣] មាត្រា៥៩ ហាមឃាត់បន្ថែមទៀត ចំពោះការផ្តល់សម្បទានដីច្រើនកន្លែង ឱ្យបុគ្គលតែម្នាក់ ឬឱ្យនីតិបុគ្គលច្រើន ប៉ុន្តែគ្រប់គ្រងដោយរូបវន្តបុគ្គល ឬនីតិបុគ្គលដដែល។ ដែលមានទំហំសរុបច្រើនជាង ១០.០០០ ហិកតា ។

មាត្រា៦២ ចែងថា រាល់សម្បទានដីសេដ្ឋកិច្ច ត្រូវចាប់ផ្តើមធ្វើអាជីវកម្មក្នុងរយៈពេល ១២ ខែ បន្ទាប់ពីការផ្តល់សម្បទាន បើមិនដូច្នោះទេ នឹងត្រូវទុកជាមោឃៈ ។ សម្បទានដែលបានផ្តល់មុនច្បាប់ភូមិបាល ត្រូវធ្វើអាជីវកម្មក្នុងរយៈពេល ១២ ខែ គិតពីថ្ងៃដែលច្បាប់ភូមិបាលចូលជាធរមាន ពុំនោះទេនឹងត្រូវទុកជាមោឃៈ ។ សម្បទានក៏អាចត្រូវបានមោឃៈភាពផងដែរ ប្រសិនបើមានការខកខានធ្វើអាជីវកម្មរយៈពេលលើសពី១២ ខែ ដោយពុំមានមូលហេតុត្រឹមត្រូវ ។ រាល់ការមិនបានបំពេញសៀវភៅបន្ទុកនាំឱ្យមានការដកហូតសម្បទាន ហើយសម្បទានិក គ្មានសិទ្ធិទារសំណងនៃការខូចខាតណាមួយ បណ្តាលមកពីការដកហូតសម្បទាននេះឡើយ ។

---

[២] សម្បទានសង្គមកិច្ច គឺជាយន្តការមួយដើម្បីផ្តល់ដីឯកជនរបស់រដ្ឋ ទៅអោយគ្រួសារក្រីក្រដែលគ្មានដីធ្លី សំរាប់សង់លំនៅដ្ឋាន និងធ្វើកសិកម្ម ។ យន្តការនេះមានកំណត់ក្នុងអនុក្រឹត្យស្តីពីសម្បទានសង្គមកិច្ច ។

[៣] អនុក្រឹត្យស្តីពីសម្បទានដីសេដ្ឋកិច្ច អនុញ្ញាតឱ្យគណៈរដ្ឋមន្ត្រីផ្តល់ការលើកលែងនេះ ប៉ុន្តែត្រូវបញ្ជាក់ច្បាស់ថា ការកាប់ឆ្ការដើមឈើ ឬដុតព្រៃសំអាតដី មិនត្រូវចាត់ទុកជាអាជីវកម្មកំពុងដំណើរការឡើយ ។

មាត្រា១៨ នៃច្បាប់ភូមិបាលចែងថា  សម្បទានមិនស្របតាមបញ្ញត្តិខាងលើនឹងត្រូវទុកជាមោឃៈ និងគ្មានអានុភាព។ មាត្រា៥៥ ចែងថា សម្បទានដីត្រូវបានដកហូតវិញ ដោយរដ្ឋាភិបាល ក្នុងករណីលក្ខខ័ណ្ឌច្បាប់មិនត្រូវបានគោរព ហើយសម្បទានិកមានសិទ្ធិប្ដឹងជំទាស់នឹងសេចក្ដីសំរេចនេះ។ តុលាការអាចមោឃៈភាពសម្បទានដី ប្រសិនបើសម្បទានិកមិនគោរពតាមខដោយឡែកដែលមានចែងក្នុងកិច្ចសន្យា។

## *២.៣.  អនុក្រឹត្យស្ដីពីសម្បទានដីសេដ្ឋកិច្ច*

អនុក្រឹត្យស្ដីពីសម្បទានដីសេដ្ឋកិច្ច ត្រូវបានចុះហត្ថលេខាដោយនាយករដ្ឋមន្ត្រី កាលពីថ្ងៃទី២៧ ខែធ្នូ ឆ្នាំ ២០០៥ កំណត់លក្ខណៈវិនិច្ឆ័យ នីតិវិធី យន្ដការ និងការរៀបចំស្ថាប័នសំរាប់ការផ្ដល់សម្បទានដីសេដ្ឋកិច្ច សំរាប់ការតាមដានត្រួតពិនិត្យការអនុវត្តន៍កិច្ចសន្យា និងសំរាប់ការត្រួតពិនិត្យឡើងវិញលើសម្បទានដីសេដ្ឋកិច្ច ដែលបានផ្ដល់មុនពេលដែលអនុក្រឹត្យនេះចូលជាធរមាន ស្របតាមការការកំណត់នៃច្បាប់ភូមិបាល។

សម្បទានដីសេដ្ឋកិច្ចត្រូវបានកំណត់ថាជា យន្ដការមួយសំរាប់ផ្ដល់ដីឯកជនរបស់រដ្ឋសំរាប់ធ្វើអាជីវកម្មកសិកម្ម និងកសិ-ឧស្សាហកម្ម។ គោលបំណងនៃការផ្ដល់ដីសម្បទាន រួមមានការជំរុញវិនិយោគវិស័យកសិកម្ម បង្កើនការងារនៅជនបទ ឱកាសមានមុខរបរផ្សេងៗសំរាប់ចិញ្ចឹមជីវិត និងការបង្កើតប្រាក់ចំណូលជាតិ។

សម្បទានដីសេដ្ឋកិច្ចអាចត្រូវបានផ្ដល់អោយចំពោះតែដីដែលបំពេញលក្ខណៈវិនិច្ឆ័យដូចខាងក្រោមនេះ:

(១) ដីដែលបានចុះបញ្ជី និងបានធ្វើចំណាត់ថ្នាក់ថាជាដីឯកជនរបស់រដ្ឋ ស្របតាមអនុក្រឹត្យស្ដីពីការគ្រប់គ្រងដីរដ្ឋ និងអនុក្រឹត្យស្ដីពីនីតិវិធីនៃការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លី ឬអនុក្រឹត្យស្ដីពីការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំ។

(២) ផែនការប្រើប្រាស់ដីធ្លី ដែលបានអនុម័តដោយគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្ត-ក្រុង និងការប្រើប្រាស់ដីស្របតាមផែនការ។

(៣) ការវាយតំលៃហេតុប៉ះពាល់បរិស្ថាន និងសង្គម ត្រូវបានបំពេញចំពោះការប្រើប្រាស់ដី និងផែនការអភិវឌ្ឍន៍ដី។

(៤) មានដំណោះស្រាយសំរាប់បញ្ហាតាំងទីលំនៅថ្មី ស្របតាមក្របខ័ណ្ឌច្បាប់ និងនីតិវិធីដែលមានស្រាប់។ មិនត្រូវមានការតាំងទីលំនៅថ្មីដោយគ្មានការស្ម័គ្រចិត្ត ពីអ្នកកាន់កាប់ដីស្របច្បាប់ ហើយត្រូវគោរពសិទ្ធិមានច្រកចេញចូលទៅកាន់ដីឯកជន ។

(៥) ត្រូវមានការពិគ្រោះយោបល់ជាសាធារណៈ ជាមួយអាជ្ញាធរដែនដី និងប្រជាពលរដ្ឋមូលដ្ឋាន ពាក់ព័ន្ធនឹងគំរោង ឬសំណើរសម្បទានដីសេដ្ឋកិច្ច ។

សំណើរសម្បទានដីសេដ្ឋកិច្ច ត្រូវមានការវាយតំលៃអំពីលក្ខណៈវិនិច្ឆ័យ ដែលរួមបញ្ចូលទាំងការលើកកំពស់កំរិតជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយចីរភាព ការជៀសវាង ឬការកាត់បន្ថយអោយនៅតិចបំផុតនូវផលប៉ះពាល់អវិជ្ជមានខាងសង្គម ការបង្កើតអោយមានការងារធ្វើកាន់តែច្រើន និងការផ្សារភ្ជាប់ និងការគាំទ្រ ទៅវិញទៅមករវាងសម្បទានដីសេដ្ឋកិច្ច និងសម្បទានដីសង្គមកិច្ច ។

ការផ្តល់សម្បទានដីសេដ្ឋកិច្ច អាចត្រូវបានផ្តួចផ្តើម តាមរយៈសំណើរមានការអំពាវនាវ ដែលរដ្ឋាភិបាលជាអ្នកលើកគំរោងដើម្បីអំពាវនាវអោយអ្នកវិនិយោគដាក់សំណើរ ឬ សំណើរមិនមានការអំពាវនាវដែលអ្នកវិនិយោគជាអ្នកលើកគំរោង ។ ទោះជាយ៉ាងណាក៏ដោយ វិធីសាស្ត្រអាទិភាពសំរាប់ការផ្តល់សម្បទាន គឺវិធីសាស្ត្រអំពាវនាវអោយដាក់សំណើរក្នុងលក្ខណៈប្រកួតប្រជែង ហើយចំពោះសំណើរមិនមានការអំពាវនាវ អាចត្រូវបានពិចារណាតែក្នុងករណីដែលអ្នកវិនិយោគ សន្យាផ្តល់អត្ថប្រយោជន៍ក្នុងលក្ខណៈពិសេស តាមរយៈការនាំមកនូវ បច្ចេកវិទ្យាថ្មី ការផ្សារភ្ជាប់រវាងសម្បទានដីសេដ្ឋកិច្ច និងសម្បទានដីសង្គមកិច្ច ឬលទ្ធភាពពិសេសក្នុងការរកទីផ្សារកែច្នៃ ឬទីផ្សារនាំចេញ ។

ក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ មានសិទ្ធិផ្តល់សម្បទានដីសេដ្ឋកិច្ចដែលលើសពី១.០០០ ហិកតា ឬ តំលៃវិនិយោគសរុប ១០.០០០.០០០.០០០ រៀល (ប្រមាណជា ២.៥០០.០០០ ដុល្លារ) ។[៤] អភិបាលខេត្ត-ក្រុង មានសិទ្ធិផ្តល់សម្បទានដីក្រោមទំហំកំណត់នេះ ។ ការទទួលខុសត្រូវរបស់អាជ្ញាធរមានសមត្ថកិច្ចចុះកិច្ចសន្យា រួមមានការដាក់អោយអនុវត្តកិច្ចសន្យាដីសម្បទានសេដ្ឋកិច្ច តាមដានការអនុវត្តន៍កិច្ចសន្យា និងការរាយការណ៍ជូនគណៈរដ្ឋមន្ត្រីរៀងរាល់ ៦ខែម្តង ។

ការត្រួតពិនិត្យឡើងវិញលើសម្បទានដីសេដ្ឋកិច្ចដែលមានស្រាប់

អនុក្រឹត្យបង្កើតលេខាធិការដ្ឋានបច្ចេកទេសសំរាប់សម្បទានដីសេដ្ឋកិច្ច ដែលមានសមាសភាពតំណាងក្រសួង និងស្ថាប័ន រដ្ឋាភិបាលចំនួនប្រាំបី ។[៥] ក្នុងរយៈពេល ៩០ថ្ងៃបន្ទាប់ពីការតែងតាំង លេខាធិការដ្ឋានបច្ចេកទេសត្រូវ

---

[៤] សូមកត់សំគាល់ថា នៅក្នុងអត្ថបទបកប្រែជាភាសាអង់គ្លេសនៃអនុក្រឹត្យនេះ ការកំណត់នេះត្រូវបានបញ្ជាក់មិនត្រឹមត្រូវទេ ១០.០០០.០០០ រៀល (ប្រមាណជា ២.៥០០ ដុល្លារ) ។

[៥] ក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្រសួងមហាផ្ទៃ ក្រសួងបរិស្ថាន ក្រសួងពាណិជ្ជកម្ម និងក្រុមប្រឹក្សាអ្នកច្បាប់ ។

បង្កើតសៀវភៅកត់ត្រាសម្បទានដីសេដ្ឋកិច្ច ហើយត្រូវជូនដំណឹងក្នុងរយៈពេល ៣០ថ្ងៃ ដល់អាជ្ញាធរមានសមត្ថកិច្ចចុះកិច្ចសន្យា និងក្រុមហ៊ុនសម្បទានទាំងអស់ ស្នើសុំឱ្យផ្តល់ព័ត៌មាន និងឯកសារថតចំលងដែលពាក់ព័ន្ធ ដីសម្បទានដែលបានផ្តល់មុនអនុក្រឹត្យនេះ ។ ព័ត៌មាន និង ឯកសារ ត្រូវចុះនៅក្នុងសៀវភៅកត់ត្រាសម្បទានដីសេដ្ឋកិច្ច ក្នុងរយៈពេល ៦ខែ បន្ទាប់ពីថ្ងៃជូនដំណឹង ។

អាជ្ញាធរមានសមត្ថកិច្ចចុះកិច្ចសន្យា ដោយមានការគាំទ្រពីលេខាធិការដ្ឋានបច្ចេកទេស ត្រូវអនុវត្តនូវការត្រួតពិនិត្យឡើងវិញសម្បទានដីសេដ្ឋកិច្ចដែលមានស្រាប់ រួមទាំងការត្រួតពិនិត្យឡើងវិញលើការអនុវត្តរបស់សម្បទានិក តាមលក្ខខណ្ឌនៃកិច្ចសន្យា ថ្លៃឈ្នួលប្រើប្រាស់ដី និងប្រាក់ចំណូលដទៃទៀតដែលបានមកពីកិច្ចសន្យា ការធ្វើការពិគ្រោះយោបល់ជាសាធារណៈ ដើម្បីប្រមូលមតិយោបល់អំពីសកម្មភាពសម្បទានដីសេដ្ឋកិច្ច នៅក្នុងឃុំ-សង្កាត់ ដែលសម្បទានតាំងនៅ ការស្នើឱ្យមានការធ្វើនិយ័តកម្មដី[៦] និងការស្នើឱ្យកាត់បន្ថយដោយស្ម័គ្រចិត្តនូវសម្បទានដីសេដ្ឋកិច្ចដែលមានទំហំលើសពី ១០.០០០ ហិកតា ។ ប្រសិនបើសម្បទានិកណាម្នាក់មិនមានឆន្ទៈកាត់បន្ថយទំហំដីសម្បទានរបស់ខ្លួនដោយស្ម័គ្រចិត្តទេនោះ អាជ្ញាធរមានសមត្ថកិច្ចចុះកិច្ចសន្យា ត្រូវផ្តួចផ្តើមធ្វើការចរចាអំពីការកាត់បន្ថយទំហំសម្បទាននេះ ហើយរាយការណ៍ជូនគណៈរដ្ឋមន្ត្រីដើម្បីមានវិធានការ ប្រសិនបើការចរចាមិនបានសំរេចជោគជ័យ ក្នុងអំឡុងពេល ៦ខែ ឬប្រសិនបើសម្បទានិកខកខានមិនបានចូលខ្លួនមកធ្វើការចរចាក្នុងរយៈពេល ៤៥ថ្ងៃ ទេនោះ ។

លេខាធិការដ្ឋានបច្ចេកទេសត្រូវចេញរបាយការណ៍ត្រួតពិនិត្យឡើងវិញមួយ ដោយរួមមានទាំងការផ្តល់អនុសាសន៍ថាតើ កិច្ចសន្យានោះកំពុងដំណើរការដោយពេញលេញឬទេ តើកិច្ចសន្យានោះគួរមានការកែប្រែចំណុចជាក់លាក់ទេ ហើយថាតើគួរតែលុបចោលកិច្ចសន្យានោះដោយសារតែសម្បទានិកបានបំពានលើកិច្ចសន្យា និងបញ្ជាក់ពីការវិវត្តន៍អំពីការកាត់បន្ថយទំហំដីសម្បទានដោយការស្ម័គ្រចិត្ត ឬដោយការចរចា ។ របាយការណ៍ត្រួតពិនិត្យអនុសាសន៍ របស់លេខាធិការដ្ឋានបច្ចេកទេស និងលទ្ធផលចុងក្រោយនៃការពិនិត្យឡើងវិញ ត្រូវបានរក្សាទុកជាឯកសារសាធារណៈ នៅនឹងលេខាធិការដ្ឋានបច្ចេកទេស និងនៅគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត-ក្រុង ។

### *២.៤. ទំនាក់ទំនងជាមួយច្បាប់ដទៃទៀត*

មានបញ្ញត្តិច្បាប់ និងលិខិតុបករណ៍ដទៃទៀត ដែលទាក់ទងនឹងការផ្តល់ និងការគ្រប់គ្រងសម្បទានដីសេដ្ឋកិច្ច ។

---

[៦] ការធ្វើនិយ័តកម្មដី គឺជាការទទួលខុសត្រូវរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ហើយការទទួលខុសត្រូវរួមមានទាំងការកែតំរូវក្បាលដី ការវិនិច្ឆ័យសិទ្ធិលើដីធ្លី របស់អ្នកកាន់កាប់ក្បាលដី ក្នុងតំបន់ត្រួតពិនិត្យឡើងវិញ និងការវាស់វែង និងការចុះបញ្ជីក្បាលដីតាមនីតិវិធីជាធរមាន ។

ជំពូក ៣ នៃច្បាប់ភូមិបាល ទទួលស្គាល់សិទ្ធិសហគមន៍ជនជាតិដើមភាគតិចលើកម្មសិទ្ធិសមូហភាពលើដីធ្លីរបស់ខ្លួន ដែលរួមមានរាល់សិទ្ធិ និងការការពារកម្មសិទ្ធិដូចកម្មសិទ្ធឯកជនដែរ។[៧] ដីសហគមន៍ជនជាតិដើមភាគតិចមានដីសំរាប់រៀបចំនិវេសនដ្ឋាន និងប្រកបរបរកសិកម្ម ដែលរួមមានទាំងដីដែលបានដាំដុះជាក់ស្តែង និងដីបំរុងទុកចាំបាច់ក្នុងការដូរវេនដំណាំ។ មាត្រា២៣ នៃច្បាប់ភូមិបាលចែងថា សហគមន៍ជនជាតិដើមភាគ ត្រូវបន្តគ្រប់គ្រងដី និងសហគមន៍របស់ខ្លួនទៅតាមប្រពៃណី ទំនៀមទំលាប់ ក្នុងពេលរង់ចាំការកំណត់ខាងផ្លូវច្បាប់នូវលក្ខន្តិកៈសហគមន៍។ នៅពេលដែលពួកគេ ត្រូវបានចុះបញ្ជីជានីតិបុគ្គលហើយ សហគមន៍ទាំងនោះអាចដាក់ពាក្យសុំចុះបញ្ជីប័ណ្ណកម្មសិទ្ធិ សមូហភាពបាន។

ច្បាប់ស្តីពីព្រៃឈើអនុញ្ញាតឱ្យធ្វើសម្បទានព្រៃឈើ តែទោះជាដូច្នោះក្តី ចាប់តាំងពីខែមករា ឆ្នាំ២០០២ មកមានការប្រកាសផ្អាកការកាប់ឈើនៅក្នុងព្រៃសម្បទាន។ អនុក្រឹត្យស្តីពីការគ្រប់គ្រងព្រៃសម្បទានចែងថា ព្រៃសម្បទានដែលបានលុបចោល ឬដកហូតវិញ ត្រូវបង្វែរទៅជាតំបន់ការពារព្រៃធម្មជាតិ ហើយមិនអាចបង្វែរទៅជាសម្បទានដីសេដ្ឋកិច្ច ឬផ្តល់ឱ្យក្រុមហ៊ុនដទៃទៀតបានឡើយ។ មាត្រា ២៩ នៃច្បាប់ស្តីពីព្រៃឈើហាមឃាត់ការកាប់រំលំដើមឈើដែលផ្តល់ជ័រមានគុណភាពខ្ពស់ ឬដែលសហគមន៍មូលដ្ឋានចោះយកជ័រសំរាប់ប្រើប្រាស់ជាប្រពៃណី។ ជំពូក៩ នៃច្បាប់នេះ ទទួលស្គាល់ និងធានាសិទ្ធិប្រើប្រាស់ជាប្រពៃណីរបស់សហគមន៍មូលដ្ឋាន ដើម្បីប្រមូល ប្រើប្រាស់ផលនិងអនុផលព្រៃឈើ។ សិទ្ធិប្រើប្រាស់ជាប្រពៃណី រួមមានទាំងការលែងសត្វពាហនៈឱ្យស៊ីស្មៅក្នុងព្រៃ និងការលក់ផល អនុផលព្រៃឈើ ដោយពុំចាំបាច់មានលិខិតអនុញ្ញាត។ ជំពូក៩ ក៏បានចែងអំពីការបែងចែកផ្នែកណាមួយនៃព្រៃអចិន្ត្រៃយ៍ទុកបំរុងសំរាប់ជាព្រៃរបស់សហគមន៍ ដោយផ្តល់អោយសហគមន៍ដែលនៅក្នុង ឬនៅជិតតំបន់ព្រៃនោះ នូវសិទ្ធិ ដើម្បីគ្រប់គ្រង និងទាញយកប្រយោជន៍ពីព្រៃ តាមលក្ខណៈមួយដែលមាននិរន្តភាព។

ច្បាប់ស្តីពីការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ តម្រូវអោយធ្វើការវាយតំលៃហេតុប៉ះពាល់បរិស្ថាន ដោយត្រូវអនុវត្តចំពោះរាល់សកម្មភាព និងគំរោងសាធារណៈ និងឯកជនទាំងអស់។ ក្រសួងពាក់ព័ន្ធត្រូវពិគ្រោះយោបល់ជាមួយ ក្រសួងបរិស្ថាន មុននឹងចេញសេចក្តីសំរេចណាមួយ ឬដឹកនាំសកម្មភាពផ្សេងៗទាក់ទងនឹងការអភិរក្ស ការអភិវឌ្ឍន៍ ឬការគ្រប់គ្រងធនធានធម្មជាតិ។ ក្រសួងបរិស្ថាន សហការជាមួយក្រសួងពាក់ព័ន្ធត្រូវធ្វើការសិក្សា ដើម្បីវាយតំលៃហេតុប៉ះពាល់បរិស្ថានទៅលើធនធានធម្មជាតិ ហើយផ្តល់អនុសាសន៍ទៅក្រសួងពាក់ព័ន្ធ ដើម្បីធានាថាធនធានធម្មជាតិ ត្រូវបានអភិរក្ស អភិវឌ្ឍន៍ និងគ្រប់គ្រងក្នុងលក្ខណៈសមហេតុផល និងប្រកបដោយចិរភាព។

---

[៧] ប៉ុន្តែ សហគមន៍ជនជាតិដើមភាគតិច មិនអាចលក់ដូរ ចំណែកដីដែលជាកម្មសិទ្ធិសមូហភាពដែលបានកំណត់ថាជាដីសាធារណៈរបស់រដ្ឋបានឡើយ ។

## ៣. និន្នាការទូទៅនៃសម្បទានដីសេដ្ឋកិច្ចនៅកម្ពុជា

### *៣.១. ចំនួនសម្បទានដីសេដ្ឋកិច្ចដែលបានផ្តល់*

របាយការណ៍ឆ្នាំ២០០៤ បានរាយបញ្ជីឈ្មោះក្រុមហ៊ុនចំនួន៦៤ ដែលមានកិច្ចសន្យាសម្បទាន ឬដែលមានលិខិតស្នើសុំការយល់ព្រមលើសំណើរសម្បទានដីសេដ្ឋកិច្ច នៅក្នុងខេត្តចំនួន១៣។ បើតាមព័តិមានដែលបានផ្តល់ដោយក្រសួង កសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ នៅដើមឆ្នាំ២០០៧ គឺ ចាប់ពីឆ្នាំ១៩៩២ ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៦ រាជរដ្ឋាភិបាលកម្ពុជាបានផ្តល់សម្បទានដីសេដ្ឋកិច្ចចំនួន៩៧ នៅក្នុងខេត្ត-ក្រុង ចំនួន១៦ នៅកម្ពុជា។ ក្នុងចំនួននេះមានសម្បទានចំនួន៩ ដែលត្រូវបានយល់ព្រមជាគោលការណ៍ដោយគណៈរដ្ឋមន្ត្រី គ្របដណ្តប់លើផ្ទៃដីចំនួន ៦៤.២០៨ ហិកតា ប៉ុន្តែកិច្ចសន្យាសម្បទានទាំងនោះមិនទាន់បានចុះហត្ថលេខានៅឡើយទេ។ ក្នុងកំឡុងពេលនេះ ក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ បានបញ្ជាក់ថា កិច្ចសន្យារបស់ក្រុមហ៊ុនចំនួន៣០ ត្រូវបានលុបចោល ដែលគ្របដណ្តប់លើផ្ទៃដីចំនួន ២៦៥.២៣០ ហិកតា (សូមមើលឧបសម្ព័ន្ធ២)។ ទោះជាយ៉ាងណាក៏ដោយ មានតែក្រុមហ៊ុន៩ ដែលមានឈ្មោះក្នុងបញ្ជីនេះប៉ុណ្ណោះ មានចុះកិច្ចសន្យាសម្បទានជាមួយក្រសួង ហើយក្រុមហ៊ុនដទៃទៀត មានត្រឹមតែលិខិតយល់ព្រមជាគោលការណ៍លើសំណើរសម្បទានប៉ុណ្ណោះ។

គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៦ នៅសល់សម្បទានដែលមានសុពលភាពចំនួន៥៩[៨] គ្របដណ្តប់លើផ្ទៃដីចំនួន ៩៤៣.០៦៩ ហិកតា ក្នុងខេត្តចំនួន ១៥។ ចំនួនផ្ទៃដីនេះគិតទៅប្រហែលប្រមាណជា ៥.២ % នៃផ្ទៃដីសរុបក្នុងប្រទេសកម្ពុជា និង ១៤.៥ % នៃផ្ទៃដីដែលអាចដាំដុះបានទាំងអស់ក្នុងប្រទេសកម្ពុជា។[៩] បញ្ជីនៃសម្បទានដីសេដ្ឋកិច្ចដោយរួមមាន ឈ្មោះ និងទីតាំង មានចែងក្នុង ឧបសម្ព័ន្ធ១។

ខេត្តស្ទឹងត្រែងមានសម្បទានដីសេដ្ឋកិច្ចច្រើនជាងគេបំផុត ដែលមានក្រុមហ៊ុនសម្បទានចំនួន១០ គ្របដណ្តប់លើផ្ទៃដី ១៧៩.៨៩៩ ហិកតា។ ខេត្តដែលផ្ទៃដីទំហំធំត្រូវបានផ្តល់អោយក្រុមហ៊ុនសម្បទាន គឺខេត្តកំពង់ឆ្នាំង និងពោធិសាត់ ដែលក្រុមហ៊ុនចំនួន ២ ត្រូវបានផ្តល់ដីសម្បទាន គ្របដណ្តប់លើផ្ទៃដី ៣១៨.០២៨ ហិកតា : ក្រុមហ៊ុនភាពីម៉ិច តែមួយគត់លាតសន្ធឹងលើខេត្តទាំងពីរនេះ ដែលមានផ្ទៃដី ៣១៥.០២៥ ហិកតា។ ស្រុក ដែលផ្ទៃដីភាគច្រើនត្រូវបានផ្តល់អោយក្រុមហ៊ុនសម្បទាន មានស្រុកសំបូរ ក្នុងខេត្តក្រចេះ ស្រុកស្ទឹងត្រែង និងស្រុក សេសាន ក្នុងខេត្តស្ទឹងត្រែង និងស្រុកភ្នំស្រួច ក្នុងខេត្តកំពង់ស្ពឺ។

---

[៨] ព័តិមានពីក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ រាយបញ្ជីឈ្មោះក្រុមហ៊ុនចំនួន ៥៧ ដែលត្រូវបានផ្តល់សម្បទាន ប៉ុន្តែមានសម្បទានសរុបចំនួន៥៩ ត្រូវបានផ្តល់ ដោយសារក្រុមហ៊ុនភាពីម៉ិច ក្នុងខេត្តកំពង់ឆ្នាំង និងពោធិសាត់ និងសាជីវកម្ម ស៊ី.ជេ ខាំបូឌា ចំកាត់ក្នុងខេត្តកំពង់ស្ពឺបានចុះកិច្ចសន្យាសម្បទានដោយលែកពីគ្នាសំរាប់ដីសម្បទានដែលមានទីតាំងជាប់គ្នា។

[៩] សូមមើលជំរឿនប្រជាជនទូទៅនៃកម្ពុជា ឆ្នាំ១៩៩៨ របស់វិទ្យាស្ថានជាតិស្ថិតិ ដែលបានបញ្ជាក់នៅក្នុងរបាយការណ៍ឆ្នាំ២០០៤។

| ឈ្មោះខេត្ត | ចំនួនក្រុមហ៊ុន | ចំនួនសម្បទាន | ផ្ទៃដី (ហិកតា) |
|---|---|---|---|
| ស្ទឹងត្រែង | ១០ | ១០ | ១៧៩.៨៩៩ |
| កំពង់ស្ពឺ | ៨ | ៩ | ៩០.២៥៦ |
| ក្រចេះ | ៧ | ៧ | ៦៤.៣៧៣ |
| រតនគិរី | ៥ | ៥ | ៥៣.៧៤៧ |
| កំពង់ចាម | ៥ | ៥ | ១២.០៧០ |
| កំពង់ធំ | ៤ | ៤ | ៣៥.៥៦១ |
| កោះកុង | ៣ | ៣ | ៧៩.៣០០ |
| កំពត | ៣ | ៣ | ៣៦.២០០ |
| សៀមរាប | ៣ | ៣ | ១៩.២៣៥ |
| មណ្ឌលគិរី | ២ | ២ | ១៧.៦០០ |
| ឧត្តរមានជ័យ | ២ | ២ | ១៦.០០០ |
| ក្រុងព្រះសីហនុ | ២ | ២ | ១២.៨០០ |
| ពោធិសាត់ | ២ | ២ | ១៤១.៩៦៣ |
| កំពង់ឆ្នាំង | ១ | ១ | ១៧៦.០៦៥ |
| បាត់ដំបង | ១ | ១ | ៨.០០០ |
| **សរុប** | **៥៨** | **៥៩** | **៩៤៣.០៦៩** |

តួលេខ និងព័ត៌មានផ្តល់ដោយក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ មិនបានដាក់បញ្ចូលសម្បទានដីសេដ្ឋកិច្ចដែលមានទំហំមិនលើសពី ១.០០០ ហិកតា ផ្តល់ដោយអាជ្ញាធរខេត្តទេ។ ក្រសួងកសិកម្ម រុក្ខា ប្រម៉ាញ់ និងនេសាទ បានបញ្ជាក់ថា ខ្លួនមិនមានតួនាទីផ្តល់ព័ត៌មានស្តីពីសម្បទានទាំងនេះឡើយ ហើយក៏មិនអាចរកព័ត៌មានបន្ថែមអំពីចំនួន និងទីតាំងសម្បទានទាំងនេះពីប្រភពរដ្ឋាភិបាលបានដែរ។ បើតាមព័ត៌មានដែលទទួលបានពីប្រភពដទៃទៀត សម្បទានដីសេដ្ឋកិច្ច ដែលមានទំហំមិនលើសពី ១.០០០ ហិកតា ត្រូវបានផ្តល់ក្នុងខេត្តកំពង់ធំ ក្រចេះ មណ្ឌលគិរី ឧត្តរមានជ័យ និងរតនគិរី ហើយសំណើរជាបន្តបន្ទាប់ទៀត កំពុងស្ថិតក្នុងការពិចារណា។ នៅចុងឆ្នាំ២០០៦ មានព័ត៌មានដែលអាចជឿទុកចិត្តបានបញ្ជាក់ថា មានសំណើរសម្បទានដីសេដ្ឋកិច្ចចំនួន១០ ដែលមានទំហំមិនលើសពី ១.០០០ ហិកតា ត្រូវបានស្នើទៅអាជ្ញាធរខេត្ត ក្នុងខេត្តមណ្ឌលគិរី ហើយសំណើរសម្បទានចំនួន២២ ផ្សេងទៀត ក្នុងខេត្តក្រចេះ កំពុងស្ថិតក្នុងការពិចារណា។

### ៣.២. *លេខាធិការដ្ឋានបច្ចេកទេសសម្បទានដីសេដ្ឋកិច្ច*

សមាជិក ៨រូប នៃលេខាធិការដ្ឋានបច្ចេកទេសសម្បទានដីសេដ្ឋកិច្ច ត្រូវបានតែងតាំងដោយនាយករដ្ឋមន្ត្រី នៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៦។ នៅថ្ងៃទី១ ខែសីហា ឆ្នាំ២០០៦ ក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ បានបង្កើតក្រុមជំនួយការមួយក្រុម ដែលមានសមាសភាពមន្ត្រីក្រសួងនានា ដើម្បីជួយលេខាធិការដ្ឋានបច្ចេកទេស ក្នុងការអនុវត្តនីភារកិច្ចរបស់ខ្លួន។ មកទល់នឹងបច្ចុប្បន្ននេះ សកម្មភាពរបស់លេខាធិការដ្ឋានបច្ចេកទេស បានផ្ដោតលើការបង្កើតមុខងារ និងអាណត្តិរបស់ខ្លួន រៀបចំទម្រង់ពាក្យសុំថ្មី និងកិច្ចសន្យាសម្បទានដីសេដ្ឋកិច្ច និងធ្វើការណែនាំដល់ក្រុមហ៊ុននានា ក្នុងការរៀបចំធ្វើការវាយតំលៃហេតុប៉ះពាល់បរិស្ថាន និងសង្គម។[១០]

ក្នុងខែសីហា ឆ្នាំ២០០៦ លេខាធិការដ្ឋានបច្ចេកទេសបានផ្ញើរសេចក្ដីជូនដំណឹងទៅអាជ្ញាធរមានសមត្ថកិច្ចចុះកិច្ចសន្យា ស្នើសុំឱ្យផ្ដល់ព័ត៌មាន និងឯកសារមួយចំនួនទាក់ទងនឹងសម្បទាន ដែលបានផ្ដល់នៅមុនអនុក្រឹត្យស្ដីពីសម្បទានដីសេដ្ឋកិច្ច។ ក្នុងខែមករា ឆ្នាំ២០០៧ ក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ បាននិយាយឱ្យដឹងថា លេខាធិការដ្ឋានបច្ចេកទេស ប្រមូលទិន្នន័យស្ដីពីសម្បទានដីសេដ្ឋកិច្ចពីក្រសួង និងអជ្ញាធរខេត្ត ហើយថាសៀវភៅកត់ត្រាដីសម្បទានសេដ្ឋកិច្ច នឹងត្រូវបានបង្កើតនៅពេលដែលបានទទួលព័ត៌មានទាំងនេះ។ មិនមានព័ត៌មានបន្ថែមស្ដីពីស្ថានភាពនៃសៀវភៅកត់ត្រាសម្បទានដីសេដ្ឋកិច្ច ទេ ចាប់តាំងពីពេលនោះមក។

### ៣.៣. *ការត្រួតពិនិត្យឡើងវិញសម្បទានដីសេដ្ឋកិច្ចដែលមានស្រាប់*

ក្នុងខែធ្នូ ឆ្នាំ២០០៥ ក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ បានរំលឹកថា ក្រុមហ៊ុនដែលមានសកម្មភាពចំនួន១០ ត្រូវបានត្រួតពិនិត្យឡើងវិញ។ ក្រៅពីការលុបចោលសម្បទានដែលក្រសួងបានលើកឡើងនៅដើមឆ្នាំ២០០៧ គេមិនទាន់ដឹងច្បាស់នៅឡើយទេថា តើការត្រួតពិនិត្យឡើងវិញជាទូទៅលើសម្បទានដែលមានស្រាប់បានចាប់ផ្ដើមឬយ៉ាងណានោះ។ សម្បទានដែលមានស្រាប់ដែលមានទំហំធំបំផុត រួមមាន សម្បទានរបស់ក្រុមហ៊ុន ភាពីម៉ិច ក្នុងខេត្តពោធិសាត់ និងខេត្តកំពង់ឆ្នាំង ហើយនិង ក្រុមហ៊ុន ហ្គ្រីន ស៊ី (Green Sea) ដែលមានទំហំ ១០០.៨៥២ ហិកតា ក្នុងខេត្តស្ទឹងត្រែង មិនទាន់ត្រូវបានត្រួតពិនិត្យឡើងវិញនៅឡើយ។

### ៣.៤. *ការទទួលបានព័ត៌មាន និងឯកសារផ្សេងៗ*

អភិបាលកិច្ចល្អ ដែលជាស្នូលនៃយុទ្ធសាស្ត្រចតុកោណរបស់រដ្ឋាភិបាលសំរាប់កំណើន ការងារ សមធម៌ និងប្រសិទ្ធិភាព គឺ "ដើម្បីធានាឱ្យមានតម្លាភាព និងការទទួលខុសត្រូវពេញលេញក្នុងកិច្ចការទាំងអស់របស់រដ្ឋាភិបាល

---

[១០] បទបង្ហាញរបស់ លោក ចាយ សាគុណ អនុប្រធានមន្ទីរផែនការ និងស្ថិតិ នៃក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ ដល់ក្រុមការងារបច្ចេកទេសព្រៃឈើ និងបរិស្ថាន ខែធ្នូ ឆ្នាំ២០០៦។

រួមទាំងការដាក់លក់ ឬការជួលទ្រព្យសម្បត្តិសាធារណៈ" ។ វាជាការសំខាន់ណាស់ ដែលត្រូវដឹងថា តើអ្នកណាទទួលផលពីសម្បទានដីសេដ្ឋកិច្ច និងពីការធ្វើសម្បទានដីធ្លី និងធនធានធម្មជាតិរបស់កម្ពុជា ។

របាយការណ៍ឆ្នាំ២០០៤ បានអំពាវនាវឱ្យបញ្ចេញឱ្យដឹងនូវព័ត៌មានពាក់ព័ន្ធនឹងសម្បទានដីសេដ្ឋកិច្ច រួមទាំងកិច្ចសន្យា ផែនទី ម្ចាស់ភាគហ៊ុន និងប្រាក់ចំណូលដែលបានទទួលពីសម្បទាន ។ សន្ទស្សន៍ត្រួតពិនិត្យរួមមួយចំនួនដែលបានយល់ព្រម ដោយរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍នៅក្នុងសម័យប្រជុំក្រុមពិគ្រោះយោបល់ក្នុងខែធ្នូ ឆ្នាំ២០០៤ និងខែមីនា ឆ្នាំ២០០៦ អំពាវនាវសុំឱ្យបញ្ចេញឱ្យដឹងភ្លាម១ជាសាធារណៈនូវកិច្ចសន្យាសម្បទាន និងការអនុវត្តន៍កិច្ចសន្យា និងអោយមានការបង្កើតយន្តការមួយ សំរាប់ផ្សព្វផ្សាយតាមកាលកំណត់នូវព័ត៌មានស្តីពីសម្បទានដីសេដ្ឋកិច្ច ។

នៅពាក់កណ្តាលឆ្នាំ២០០៦ ក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ បានបង្កើតគេហទំព័រសម្បទានដីសេដ្ឋកិច្ចនៅលើវិបសាយរបស់ខ្លួន ដែលបញ្ចូលព័ត៌មាននៃទំរង់សម្បទានទាំងឡាយដែលបានផ្តល់ និងព័ត៌មានជាមូលដ្ឋានរបស់ក្រុមហ៊ុន ។[១១] នៅក្នុងខែមីនា ឆ្នាំ២០០៧ គេហទំព័រនេះត្រូវបានធ្វើបច្ចុប្បន្នភាព ដើម្បីឆ្លុះបញ្ចាំងព័ត៌មានស្តីពីសម្បទាន មកដល់ត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៦ ។ ព័ត៌មានត្រូវបានផ្តល់នៅគ្រប់សម្បទានទាំងអស់ដែលមានទំហំច្រើនជាង ១.០០០ ហិកតា រួមទាំងសេចក្តីលំអិតអំពីក្រុមហ៊ុន ។ គេហទំព័រនេះបានរាយឈ្មោះនាយកក្រុមហ៊ុន ប៉ុន្តែមិនបានរាយឈ្មោះម្ចាស់ភាគហ៊ុននៃក្រុមហ៊ុនសម្បទានទាំងអស់នោះទេ ។តម្រូវឱ្យមានព័ត៌មានលំអិតថែមទៀតអំពីកម្មសិទ្ធិលើសម្បទាន និងក្រុមហ៊ុនសម្បទាននានា រួមទាំងព័ត៌មានអំពី នាយកក្រុមហ៊ុន និងម្ចាស់ភាគហ៊ុនទាំងអស់ ។

មិនមានព័ត៌មានត្រូវបានផ្តល់អំពីសម្បទានដែលមានទំហំមិនលើសពី ១.០០០ ហិកតាទេ ។ព័ត៌មាននេះត្រូវតែបញ្ចេញអោយសាធារណជនដឹងជាបន្ទាន់ រួមទាំងសេចក្តីលំអិតអំពីសម្បទានិក និងទីតាំង ទំហំ គោលបំណង និងស្ថានភាពនៃសម្បទានទាំងនោះ ។ ព័ត៌មានស្តីពីសំណើរសម្បទានដីសេដ្ឋកិច្ច ដែលស្ថិតក្នុងការពិចារណា ឬបានយល់ព្រមជាគោលការណ៍ ក៏គួរតែបានបញ្ចេញឱ្យដឹង ដោយហេតុថាសម្បទានិកជាច្រើនចាប់ផ្តើមសកម្មភាពរបស់ខ្លួននៅមុនពេលចុះកិច្ចសន្យា ។ ម្យ៉ាងវិញទៀត ព័ត៌មានស្តីពីការអនុវត្តន៍តាមអនុក្រឹត្យស្តីពីសម្បទានដីសេដ្ឋកិច្ចគឺជាការចាំបាច់ រួមមានការពិគ្រោះយោបល់ជាសាធារណៈ និងការវាយតំលៃពីហេតុប៉ះពាល់បរិស្ថាន និងសង្គម និងរបាយការណ៍ពីការពិគ្រោះយោបល់ និងការវាយតំលៃទាំងនេះ ។

---

[១១] សូមមើល http://www.maff.gov.kh/elc/index.html.

## ៤. ច្បាប់ និង ការអនុវត្តន៍ជាក់ស្តែង

### *៤.១. ការអនុវត្តតាមសេចក្តីតម្រូវរបស់ច្បាប់ និងនីតិវិធីច្បាប់*

ក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ បានលើកឡើងថា ខ្លួនមានការលំបាកដើម្បីអនុវត្តតាម លក្ខខ័ណ្ឌតំរូវនៃអនុក្រឹត្យស្តីពីសម្បទានដីសេដ្ឋកិច្ច ដោយសារតែក្រសួងប្រឈមមុខនឹងការដាក់កំហិតពីអ្នកវិនិយោគនានាដែលស្វែងរកដីសម្បទាន។ មន្ត្រីទាំងនោះបានបរិយាយថា ប្រសិនបើក្រសួងត្រូវរង់ចាំរហូតដល់ខ្លួនមានលទ្ធភាពអនុវត្តតាម លក្ខខ័ណ្ឌតម្រូវនៃអនុក្រឹត្យ ទើបផ្តល់សម្បទាន នោះអ្នកវិនិយោគនឹងមិនចាប់អារម្មណ៍ក្នុងការដាក់ទុននៅកម្ពុជាទៀតឡើយ ។[១២] ទោះជាយ៉ាងណាក៏ដោយ ច្បាប់របស់ប្រទេសបានចងកាតព្វកិច្ច ហើយចេតនាក្នុងការលើកកំពស់វិនិយោគវិស័យឯកជន មិនអាចជាលេសដើម្បីមិនអនុវត្តតាមលក្ខខ័ណ្ឌតំរូវនៃច្បាប់នោះទេ។

សម្បទានជាច្រើនមិនបានធ្វើអាជីវកម្មក្នុងរយៈពេល១២ខែចាប់ពីថ្ងៃចុះកិច្ចសន្យា ឬមិនមានសកម្មភាពរយៈពេលច្រើនជាង១២ខែ ដោយគ្មានការដាក់ទណ្ឌកម្ម។ ក្រុមហ៊ុន ហ្គ្រីន ស៊ី (Green Sea) ដែលមានដីសម្បទានទំហំ ១០០.៨៥២ ហិកតា ក្នុងខេត្តស្ទឹងត្រែង មិនបានធ្វើអាជីវកម្មនៅឡើយទេ ទោះបីជាមានការចាប់ផ្តើមធ្វើការសាងសង់ការដ្ឋាន នៅចុងឆ្នាំ២០០៦ ក្តី។ ក្រុមហ៊ុនដីសម្បទានដែលអសកម្មដទៃទៀតរួមមាន សម្បទានរបស់ក្រុមហ៊ុនភាពីម៉ិចដែលមានទំហំ ៣១៥.០២៥ ហិកតា ក្នុងខេត្តកំពង់ឆ្នាំង និងពោធិសាត់ ហើយក្រុមហ៊ុននេះក៏មិនបានបង់ប្រាក់កក់ដែរនេះបើតាមព័តិមានរបស់ក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ។ ផ្អែកលើព័តិមាន ដែលបានផ្តល់ដោយក្រសួងសម្បទានិកជាច្រើន មិនបានបង់ប្រាក់ឈ្នួលសម្បទានតាមការតម្រូវទេ មិនបានកំណត់ ឬធ្វើការវាស់វែងព្រំប្រទល់ដីសម្បទាន ឬបានបាត់បង់ទំនាក់ទំនងជាមួយក្រសួង។ ទាំងអស់នេះគឺជាមូលដ្ឋានដើម្បីលុបចោលសម្បទានដីសេដ្ឋកិច្ច ។

សម្បទានិកជាច្រើនបានចាប់ផ្តើមសកម្មភាពនៅក្នុងតំបន់ដែលបានស្នើសុំសម្បទាន នៅមុនការចុះកិច្ចសន្យាដែលផ្ទុយនឹងមាត្រា៥៣ នៃច្បាប់ភូមិបាល។ ឧទាហរណ៍ នៅក្នុងខេត្តកោះកុង គណៈរដ្ឋមន្ត្រីបានយល់ព្រមជាគោលការណ៍ ដើម្បីផ្តល់សម្បទានពីរទៅឱ្យ ក្រុមហ៊ុន កោះកុង ស៊ូហ្គើរ អ៊ិនដាសស្ទ្រី (Koh Kong Sugar Industry) និងក្រុមហ៊ុន កោះកុង ផ្លេនថេសិន (Koh Kong Plantation) ក្នុងខែមីនា ឆ្នាំ២០០៦។ ក្នុងខែឧសភា ឆ្នាំ២០០៦ ក្រុមហ៊ុនបានបង្កើតការដ្ឋាន និងបានចាប់ផ្តើមឈូសឆាយដីក្នុងស្រុកស្រែអំបិល រួមទាំងដីស្រែ និងចំការដំណាំរបស់អ្នកស្រុក ។កិច្ចសន្យាសម្បទាន ត្រូវបានធ្វើឡើងនៅពេលក្រោយមកគឺ នៅថ្ងៃទី២ ខែសីហា ឆ្នាំ២០០៦។ ឧទាហរណ៍

[១២] នៅក្នុងសម័យប្រជុំគណៈកម្មាធិការសំរបសំរួលរដ្ឋាភិបាល និងប្រទេសអ្នកផ្តល់ជំនួយ នៅថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០០៧ ឯកឧត្តម ចាន់ សារ៉ុន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ បានគូសបញ្ជាក់ថា ក្រុមហ៊ុននានាមិនចង់ធ្វើការវាយតំលៃហេតុប៉ះពាល់បរិស្ថាន និងសង្គម នៅមុនការដាក់ពាក្យសុំសម្បទានដីសេដ្ឋកិច្ចឡើយ ដោយសារគេត្រូវចំណាយពេលវេលា និងលុយកាក់ច្រើន។

មួយទៀត គឺសម្បទានរបស់ក្រុមហ៊ុន អ៊ូជីសាន (Wuzhishan) ក្នុងខេត្តមណ្ឌលគីរី ដែលក្រុមហ៊ុនបានចាប់ផ្តើមសកម្មភាពការងារនៅលើដីជនជាតិដើមភាគតិច នៅពាក់កណ្តាលឆ្នាំ២០០៤ នៅមុនពេលចុះកិច្ចសន្យាសម្បទានថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០០៥។

ច្បាប់ភូមិបាលចែងថា សម្បទានដីមិនអាចប៉ះពាល់ ដីផ្លូវដើរ ឬផ្លូវគមនាគមន៍ ឬផ្លូវទឹក ត្រពាំង និងដែនទឹកបំរុង ដែលប្រជាជនប្រើប្រាស់ក្នុងជីវភាពរស់នៅប្រចាំថ្ងៃរបស់ខ្លួនឡើយ។ ប៉ុន្តែមានសម្បទានជាច្រើនបានបិទផ្លូវដើរ និងផ្លូវដែលប្រជាពលរដ្ឋប្រើប្រាស់ ដើម្បីចូលទៅតំបន់ព្រៃ និងទៅរកអនុផលព្រៃឈើ។ ឧទាហរណ៍ ក្នុងខេត្តក្រចេះ ក្រុមហ៊ុន គ្លូបល អាគ្រីខលឆឺរល ឌីវីឡុបមិន (Global Agricultural Development) ត្រូវបានគេរាយការណ៍ថាបានបង្កើតរបាំងបិទផ្លូវដែលប្រជាពលរដ្ឋប្រើប្រាស់ ដើម្បីទារប្រាក់ថ្លៃឈ្នួលពីអ្នកប្រើប្រាស់ផ្លូវនេះ។ ក្នុងខេត្តពោធិសាត់ ក្រុមហ៊ុន រតនាវិសាល បានបិទប្រឡាយទឹកដែល ប្រជាពលរដ្ឋប្រើប្រាស់សំរាប់ស្រោចស្រប់ស្រែរបស់ខ្លួន បន្ទាប់ពីមានការតវ៉ាពីសហគមន៍ មួយឆ្នាំក្រោយមក ប្រឡាយនោះត្រូវបានបើកឡើងវិញ។

### *៤.២. ដីឯកជនរបស់រដ្ឋ និងផែនការប្រើប្រាស់ដី*

លក្ខខណ្ឌចម្បង សំរាប់ការផ្តល់សម្បទានដីសេដ្ឋកិច្ច គឺការចុះបញ្ជីដី ថាជាដីឯកជនរបស់រដ្ឋ និងការអនុម័តផែនការប្រើប្រាស់ដីធ្លី ដែលក្នុងនេះសំណើរប្រើប្រាស់ដីធ្លីត្រូវតែស្របគ្នា។

ការកំណត់ ការធ្វើចំណាត់ថ្នាក់ និងការចុះបញ្ជីជាប្រព័ន្ធ នៃដីឯកជន និងដីសាធារណៈរបស់រដ្ឋនៅកម្ពុជាមិនទាន់បានធ្វើនៅឡើយទេ ហើយនៅក្នុងករណីភាគច្រើន ផែនការប្រើប្រាស់ដីមិនទាន់បានអនុម័តដោយគណៈកម្មាធិការគ្រប់គ្រងដីធ្លីថ្នាក់ខេត្ត-ក្រុងទេ។ ទោះជាយ៉ាងណាក៏ដោយ សម្បទានដីសេដ្ឋកិច្ចនៅតែត្រូវបានផ្តល់ជាបន្ត។ នៅក្នុងករណីជាច្រើន ដីដែលបានធ្វើសម្បទានអោយក្រុមហ៊ុន ជាដីដែលប្រជាពលរដ្ឋមូលដ្ឋានបានធ្វើការដាំដុះរយៈពេលជាច្រើនឆ្នាំមកហើយ តាំងពីមុនឆ្នាំ២០០១ មក ហើយសហគមន៍ទាំងនេះ បានបំពេញតាមសេចក្តីតម្រូវសំរាប់ការទាមទារសិទ្ធិកម្មសិទ្ធិតាមច្បាប់ភូមិបាល។ នៅក្នុងករណីខ្លះ សហគមន៍មូលដ្ឋានក៏បានចូលរួមក្នុងការផ្តួចផ្តើមគំនិតសំរាប់ការគ្រប់គ្រងដីធ្លី និងធនធានធម្មជាតិប្រកបដោយចិរភាព តាមរយៈសំណើរ ឬផែនការប្រើប្រាស់ដីធ្លីដែលមានការចូលរួម ដើម្បីបង្កើតព្រៃសហគមន៍។ ការផ្តួចផ្តើមទាំងនេះត្រូវបានគេបញ្ឈប់ ឬបោះបង់ចោលបន្ទាប់ពី ដីត្រូវបានផ្តល់សម្បទានអោយក្រុមហ៊ុន។

នៅថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧ រដ្ឋាភិបាលបានចេញសារាចរមួយ ដែលមានការរង់ចាំជាយូរមកហើយ ស្តីពីវិធានការទប់ស្កាត់ការកាន់កាប់ដីធ្លីខុសច្បាប់ ដើម្បីអនុវត្តមាត្រា១៨ នៃច្បាប់ភូមិបាល។ ទោះជាយ៉ាងណាក៏ដោយ សារាចរនេះមិនគ្របដណ្តប់លើសម្បទានដីសេដ្ឋកិច្ចទេ ដោយចែងថា ការដកហូត ឬការកាត់បន្ថយទំហំនៃដីសម្បទានសេដ្ឋកិច្ច ត្រូវអនុវត្តតាមនីតិវិធី ដែលបានកំណត់ក្នុងអនុក្រឹត្យស្តីពីសម្បទានដីសេដ្ឋកិច្ច។

*៤.៣. ការពិគ្រោះយោបល់ជាសាធារណៈ និងការវាយតំលៃហេតុប៉ះពាល់បរិស្ថាន និងសង្គម*

មានលក្ខខ័ណ្ឌចម្បង ចំនួនពីរទៀត តំរូវអោយមានមុននឹងផ្តល់សម្បទានដីសេដ្ឋកិច្ច គឺ ការពិគ្រោះយោបល់ជាសាធារណៈ និងការវាយតំលៃពីហេតុប៉ះពាល់បរិស្ថាន និងសង្គម ។ នៅក្នុងករណីភាគច្រើន ការពិគ្រោះយោបល់ជាសាធារណៈ មិនបានធ្វើនៅក្នុងសហគមន៍ នៅមុនពេលផ្តល់សម្បទានទេ ។ ដូចគ្នានេះដែរ ការវាយតំលៃយ៉ាងម៉ត់ចត់ និងពិតប្រាកដ ពីហេតុប៉ះពាល់បរិស្ថាន និងសង្គម ជាទូទៅមិនបានធ្វើជាមុនទេ ។

ឧទាហរណ៍ មានការវាយតំលៃដំបូងពីហេតុប៉ះពាល់បរិស្ថាន និងសង្គម ត្រូវបានធ្វើសំរាប់សម្បទានក្រុមហ៊ុន សលសុភា ពាណិជ្ជ និង ក្រុមហ៊ុន សុភក្តិនីកា ក្នុងស្រុកសេសាន ខេត្តស្ទឹងត្រែង ។ ប៉ុន្តែ ការវាយតំលៃទាំងនេះ ត្រូវបានធ្វើនៅក្នុងឆ្នាំ២០០៦ បន្ទាប់ពីការផ្តល់ដីសម្បទានអោយក្រុមហ៊ុនទាំងពីរ នៅថ្ងៃទី៨ ខែសីហា ឆ្នាំ២០០៥ ។ បើតាមមន្ទីរបរិស្ថានខេត្ត ក្រុមហ៊ុនអភិវឌ្ឍន៍ឯកជនសំរាប់ការពិគ្រោះយោបល់មួយដែលត្រូវបានទាក់ទងអោយធ្វើការវាយតំលៃ បានសិក្សាលើដីសម្បទាននេះ ដោយមានការចូលរួមពីអ្នកស្រុក និងសាធារណៈជន ។ ប៉ុន្តែអ្នកស្រុកបាននិយាយថា ពួកគេទាំងអស់គ្នាបានបដិសេធ មិនប្រគល់ដីនៅតំបន់របស់ខ្លួនឱ្យតំណាងក្រុមហ៊ុនទេ នៅពេលដែលតំណាងក្រុមហ៊ុនបានមកប្រាប់អ្នកស្រុក អំពីផែនការរបស់ក្រុមហ៊ុនដើម្បីអភិវឌ្ឍន៍ និងបង្កើតការងារនៅក្នុងមូលដ្ឋាននោះកាលពីខែកញ្ញា ឆ្នាំ២០០៥ ហើយនៅក្នុងខែមេសា ឆ្នាំ២០០៦ ក្រុមហ៊ុនសម្បទានរៀបចំពិធីជប់លាងមួយអោយអ្នកស្រុកដោយមានផ្តល់ស្រា និងអំណោយមួយចំនួន ដូចជាត្រាក់ទ័រ ដើម្បីលើកទឹកចិត្តពួកគេឱ្យយល់ព្រមតាមផែនការទាំងនេះ ។ សម្បទានទាំងពីរបានទន្ទ្រានលើដីកសិកម្ម និងព្រៃដែលសហគមន៍ជនជាតិដើមភាគតិចបានប្រើប្រាស់សំរាប់ប្រមូលអនុផលព្រៃឈើ ។ មន្ទីរបរិស្ថានខេត្តបានយល់ព្រមថា សម្បទានទាំងនេះនឹងប៉ះពាល់ដល់ជីវភាពរស់នៅ និងប្រពៃណី វប្បធម៌នៅក្នុងតំបន់ដែលជនជាតិដើមភាគតិចកំពុងតែកាន់កាប់ ។

នៅថ្ងៃទី១៥ ខែមីនា ឆ្នាំ២០០៦ ក្រុមហ៊ុន គ្លូបល អាគ្រីខលឆឺរល ឌីវីឡុបមិន (Global Agricultural Development) ក្រុមហ៊ុន អាស៊ី វើល អាគ្រីខលឆឺរល ឌីវីឡុបមិន (Asia World Agricultural Development) និងក្រុមហ៊ុន គ្រីន អាយលេន អាគ្រីខលឆឺរល ឌីវីឡុបមិន (Green Island Agricultural Development) ត្រូវបានផ្តល់ដីសម្បទាន សំរាប់ដាំម៉ៃសាក់ ដែលមានទំហំ ២៩.៣៨៣ ហិកតា ក្នុងស្រុកសំបូរ ខេត្តក្រចេះ ។ សហគមន៍រងផលប៉ះពាល់បានដឹង អំពីសម្បទានទាំងនេះក្នុងខែមេសា ឬខែឧសភា ឆ្នាំ២០០៦ នៅពេលដែលមន្ត្រីរដ្ឋាភិបាលថ្នាក់មូលដ្ឋានមួយក្រុម និងតំណាងក្រុមហ៊ុន បានមកធ្វើទស្សនកិច្ចនៅតំបន់នេះ ហើយប្រធានភូមិមួយរូបត្រូវបានគេស្នើសុំឱ្យអមដំណើរ ពួកគេដើរមើលដី និងព្រៃក្នុងតំបន់ទាំងនោះ និងដើម្បីពន្យល់ប្រាប់ពួកគេពីប្រភេទដី និងការប្រើប្រាស់ដីនៅក្នុងឃុំ ។ ៦ថ្ងៃក្រោយមក ក្រុមនេះបានមកធ្វើទស្សនកិច្ចលើកទី២ អមដំណើរដោយមន្ត្រីមកពីមន្ទីរបរិស្ថានខេត្ត និង បុគ្គលិកយោធា ហើយបានធ្វើការវាស់វែងព្រំដីសម្បទាន ដោយបោះបង្គោលកាត់តាម

វាលស្រែអ្នកភូមិនៅក្នុងតំបន់ខ្លះ។ បន្ទាប់មកសម្បទានិកបានបង្កើតការដ្ឋានរបស់ខ្លួន ក្នុងឃុំក្បាលដំរី ហើយចាប់ផ្ដើមកាប់ឆ្ការព្រៃ និងឈូសធ្វើផ្លូវ។

ស្រដៀងគ្នានេះដែរ ក្នុងស្រុកសំរោង ខេត្តឧត្ដរមានជ័យ ក្រុមហ៊ុន គ្រីស្តាល អាហ្គ្រោ (Crystal Agro) និងក្រុមហ៊ុន រៀល គ្រីន (Real Green) បានចុះកិច្ចសន្យាក្នុងខែមិថុនា និងខែកក្កដា ឆ្នាំ២០០៦ ដែលសម្បទាននីមួយៗមានទំហំ ៨.០០០ ហិកតា សំរាប់ ដំណាំដំឡូងមី និងដំណាំកសិ-ឧស្សាហកម្ម។ អ្នកស្រុកដែលរងផលប៉ះពាល់រួមមានជនជាតិភាគតិចគួយផង ក៏មិនត្រូវបានគេប្រាប់ឱ្យដឹង ឬបានពិគ្រោះយោបល់ជាមួយដែរ។ ពួកគេបានដឹងត្រឹមតែពីវត្តមានរបស់សម្បទាន នៅពេលដែល ក្រុមហ៊ុនចូលមកដល់ ហើយចាប់ផ្ដើមឈូសឆាយដី។ ក្រុមហ៊ុន រៀល គ្រីន បានចាប់ផ្ដើមសកម្មភាពរបស់ខ្លួន នៅចុងខែតុលា ឆ្នាំ២០០៦ ធ្វើឱ្យប៉ះពាល់ដល់ដីសង់លំនៅដ្ឋាន និងដីស្រែប្រមាណជា ៧០ គ្រួសារនៅក្នុងភូមិក្ដុល។ ក្រុមហ៊ុន គ្រីស្តាល អាហ្គ្រោ បានចាប់ផ្ដើមសកម្មភាពរបស់ខ្លួនក្នុងខែវិច្ឆិកា ឆ្នាំ២០០៦ ហើយភ្លាមៗនោះសកម្មភាព ឈូសឆាយរបស់ក្រុមហ៊ុន បានទន្ទ្រានលើដីស្រែ និងចំការប្រជាពលរដ្ឋជាច្រើនគ្រួសារក្នុងភូមិផ្អុង។

មានការបង្ហាញថែមទៀតអំពីការខ្វះការពិគ្រោះយោបល់ជាសាធារណៈ និងការវាយតំលៃពីផលប៉ះពាល់ប្រកបដោយប្រសិទ្ធិភាពនោះគឺ ជារឿយៗអ្នកស្រុកមិនបានដឹងអំពីព្រំប្រទល់ដីសម្បទានទាំងនោះទេ ហើយនៅក្នុងតំបន់ដែលមានដីសម្បទានច្រើន ពួកគេមិនដឹងថាក្រុមហ៊ុនមួយណាដែលប៉ះពាល់ដីរបស់ខ្លួនទេ។ ឧទាហរណ៍មានក្រុមហ៊ុនយ៉ាងតិចណាស់ក៏ ៦ដែរ ដែលត្រូវបានផ្ដល់សម្បទានក្នុងស្រុកសេសាន ខេត្តស្ទឹងត្រែង។ អ្នកស្រុកជាច្រើនបានធ្វើការតវ៉ាអំពីផលប៉ះពាល់ដោយសកម្មភាពការងាររបស់ក្រុមហ៊ុនទៅលើដីស្រែចំការរបស់ពួកគេ និងដើមច្បោះប៉ុន្តែមិនមានព័ត៌មានអំពី ព្រំប្រទល់ដីសម្បទាននៃក្រុមហ៊ុនទាំងនេះ ហើយក៏មិនបានដឹងថាតើក្រុមហ៊ុនមួយណាធ្វើឱ្យប៉ះពាល់ភូមិណានោះដែរ។

### *៤.៤ ទំហំដីសម្បទាន និងកម្មសិទ្ធិ*

សម្បទានដីសេដ្ឋកិច្ចចំនួន៩ ដែលមានផ្ទៃដីច្រើនជាង ១០.០០០ ហិកតា ដែលលើសពីទំហំកំណត់ក្នុងច្បាប់ភូមិបាល។[១៣] សម្បទានទាំងនេះ ត្រូវបានផ្ដល់នៅមុនការអនុម័តច្បាប់ភូមិបាល លើកលែងតែក្រុមហ៊ុន គ្រីនស៊ីក្នុងខេត្ត ស្ទឹងត្រែង។ សម្បទានចំនួន២ ត្រូវបានយល់ព្រមជាគោលការណ៍ ប៉ុន្តែកិច្ចសន្យានៅមិនទាន់បានចុះនៅឡើយ

[១៣] ក្រុមហ៊ុនភាពីម៉ិច (៣១៥.០២៥ ហិកតា) ក្រុមហ៊ុន គ្រីនស៊ី (១០០.៨៥២ ហិកតា) ក្រុមហ៊ុន គ្រីន វិច (៦០.២០០ ហិកតា) ក្រុមហ៊ុន ខាំបូ វិចទ័រ (២៦.៥៥០ ហិកតា) ក្រុមហ៊ុន ខាំបូឌា ហៃនីញ (២៣.០០០ ហិកតា) ក្រុមហ៊ុន មិត្តភាព ម៉ែន សារុន (២០.០០០ ហិកតា) ក្រុមហ៊ុន ខេមលេន (១៦.៤០០ ហិកតា) ក្រុមហ៊ុន អភិវឌ្ឍន៍ដំណាំឧស្សាហកម្ម អ៊ុក យុន (១២.៥០៦ ហិកតា) និងក្រុមហ៊ុន ម៉ុង ឬទ្ធី ដំណាំដូងប្រេង (១១.០០០ ហិកតា)។

ក៏មានទំហំលើសការកំណត់ ១០.០០០ ហិកតា ដែរ ។[១៤] សម្បទានដទៃទៀត ដែលបានផ្តល់ចាប់តាំងពីមាន ច្បាប់ភូមិបាលមក មានទំហំមិនលើសពី ១០.០០០ ហិកតា ប៉ុន្តែមានករណីមួយចំនួន បុគ្គល ឬក្រុមដដែលមាន ផលប្រយោជន៍ក្នុងសម្បទានដីសេដ្ឋកិច្ច ក្រោមឈ្មោះក្រុមហ៊ុនផ្សេងគ្នា ហើយដែលសម្បទានទាំងនេះ ត្រូវបានផ្តល់ អោយលើទីតាំងដែលមានព្រំប្រទល់ដីជាប់គ្នា សំរាប់គោលបំណងដូចគ្នា ។

ឧទាហរណ៍ ក្នុងខេត្តកោះកុង ក្រុមហ៊ុន កោះកុង ស៊ូហ្គើរ អ៊ិនដាសស្ទ្រី និងក្រុមហ៊ុន កោះកុង ផ្លេនថេសិន បានចុះកិច្ចសន្យាសម្បទាន ដែលដីសម្បទានមានទំហំ ៩.៧០០ ហិកតា និង ៩.៤០០ ហិកតា នៅថ្ងៃទី២ ខែ សីហា ឆ្នាំ២០០៦ ។ សមាជិកព្រឹទ្ធសភា លោក លី យ៉ុង ផាត់ គឺជានាយកក្រុមហ៊ុន កោះកុង ផ្លេនថេសិន រីឯជនជាតិថៃម្នាក់ ឈ្មោះ ចំរ៉ើន ឈីនថាមិត ជានាយកក្រុមហ៊ុន កោះកុង ស៊ូហ្គើរ អ៊ិនដាសស្ទ្រី ។ បើតាមរបាយការណ៍គួរឱ្យជឿទុកចិត្ត បានបញ្ជាក់ថា សមាជិកព្រឹទ្ធសភា លោក លី យ៉ុង ផាត់ ជាម្ចាស់ភាគហ៊ុនក្នុងក្រុមហ៊ុនទាំងពីរនេះ ដែលត្រូវបាន ផ្តល់សម្បទានក្នុងតំបន់ដែលមានព្រំប្រទល់ដីជាប់គ្នា ដើម្បីអភិវឌ្ឍន៍ចំការអំពៅ និងរោងចក្រកែច្នៃ ។ នៅស្រុកសំបូរ ខេត្តក្រចេះ ក្រុមហ៊ុនចំនួន ៣ ត្រូវបានផ្តល់អោយដីសម្បទានជាប់ៗគ្នា ដើម្បីដាំដើមម៉ៃសាក់ កាលពីថ្ងៃទី១៥ ខែមីនា ឆ្នាំ២០០៦[១៥] ដែលក្នុងចំនោមនេះក្រុមហ៊ុនពីរមានអាស័យដ្ឋានចុះបញ្ជីនៅជាមួយគ្នា ។ក្រុមហ៊ុន ៣ទៀត ត្រូវបានផ្តល់ ដីសម្បទានជាប់ៗគ្នា ដើម្បីដាំឈើហ្វាលាន (Pistacia Chinesis Bunge) នៅថ្ងៃទី១១ ខែសីហា ឆ្នាំ២០០៦ ក៏មានអាស័យដ្ឋានក្រុមហ៊ុនដែលបានចុះបញ្ជីតែមួយដែរ ។[១៦] ក្រុមហ៊ុនទាំង ប្រាំមួយនេះ ត្រូវគេមើលឃើញជាទូទៅ ថាមានជាប់ទាក់ទងគ្នា ។ ក្នុងស្រុកសំរោង ខេត្តឧត្តរមានជ័យ សម្បទានពីរ សំរាប់ដំណាំដំឡូងមី និងដំណាំកសិ-ឧស្សាហកម្ម ត្រូវបានផ្តល់លើដីជាប់ព្រំប្រទល់គ្នាឱ្យទៅក្រុមហ៊ុនពីរ ដែលសម្បទានទាំងពីរនេះមានម្ចាស់ជា ជនជាតិថៃ ដែលមានអាស័យដ្ឋានក្រុមហ៊ុនតែមួយ ។[១៧]

បុគ្គលមួយចំនួន មានប្រយោជន៍នៅក្នុងសម្បទានដីសេដ្ឋកិច្ចពីរ ឬច្រើន តាមរយៈការប្រើឈ្មោះក្រុមហ៊ុន ផ្សេងៗគ្នា ដែលដីសម្បទាននោះស្ថិតលើទីតាំងច្រើនកន្លែង រួមគ្នាមានទំហំលើសពី ១០.០០០ ហិកតា លើសពីការ កំណត់របស់ច្បាប់ ។នេះជាការផ្ទុយនឹងច្បាប់ភូមិបាល មាត្រា ៥៩ ។

---

[១៤] ក្រុមហ៊ុន យ៉ាលីន អ៊ិនធឺណាស្សួណល ត្រាស់ អ៊ិនវេសមេន (Yalin International Trust and Investment (Cambodia) Co Ltd) ខេត្តមណ្ឌលគីរី និងក្រុមហ៊ុន អឹម ខនសូលីឌេត ផ្លេនថេសិន (M Consolidate Plantation) ខេត្តកំពង់ស្ពឺ ។

[១៥] ក្រុមហ៊ុន គួបល អាហ្គ្រីខលឆឺរល ឌីវឺឡុបមិន ក្រុមហ៊ុន អាស៊ី វីល អាហ្គ្រីខលឆឺរល ឌីវឺឡុបមិន ក្រុមហ៊ុន ហ្គ្រីន អាយលេន អាហ្គ្រីខលឆឺរល ឌីវឺឡុបមិន ។

[១៦] ក្រុមហ៊ុន ផ្លេនថេស៊ិន អាហ្គ្រីខលឆឺរល ឌីវឺឡុបមិន ក្រុមហ៊ុន ហ្គ្រេត អេសេធ អាហ្គ្រីខលឆឺរល ឌីវឺឡុបមិន និងក្រុមហ៊ុន ហ្គ្រេត វនឌឺ អាហ្គ្រីខលឆឺរល ឌីវឺឡុបមិន។

[១៧] ក្រុមហ៊ុន ហ្គ្រីស្តាល អាហ្គ្រោ និងក្រុមហ៊ុន វៀលហ្គ្រីន។

ឧទាហរណ៍ដូចជានៅខេត្តស្ទឹងត្រែង ជនជាតិចិនម្នាក់ឈ្មោះ អាន យ៉ាំង យីន ឆាំង គឺជានាយកក្រុមហ៊ុនចំនួនបីផ្សេងគ្នា ដែលត្រូវបានផ្តល់សម្បទានសរុប ២៤.៨៥៤ ហិកតា។[១៨] សមាជិកព្រឹទ្ធសភា លោកម៉ុង ឬទ្ធី គឺជានាយករបស់ក្រុមហ៊ុនចំនួន៣ ដែលត្រូវបានផ្តល់សម្បទានដីសេដ្ឋកិច្ចសរុប ១១៣.៦៥២ ហិកតា នៅក្រុងព្រះសីហនុ និងខេត្តស្ទឹងត្រែង។[១៩] សមាជិកព្រឹទ្ធសភា លោក ឡាវ ម៉េងឃិន គឺជានាយកក្រុមហ៊ុនចំនួន២ ដែលបានផ្តល់សម្បទានដីសេដ្ឋកិច្ចសរុប ៤១៥.០២៥ ហិកតា ក្នុងខេត្តកំពង់ឆ្នាំង ពោធិសាត់ និងមណ្ឌលគិរី។[២០] សមាជិកព្រឹទ្ធសភា លោក ម៉ែន សារ៉ុន គឺជានាយកក្រុមហ៊ុនចំនួន២ ដែលត្រូវបានផ្តល់សម្បទានដីសេដ្ឋកិច្ចសរុប ២៤.៤០០ ហិកតា ក្នុងខេត្តរតនគិរី និងខេត្តកំពង់ចាម។[២១]

*៤.៥. ការគោរពតាមក្របខ័ណ្ឌស្តីពីការការពារព្រៃឈើ*

សម្បទានដីសេដ្ឋកិច្ចជាច្រើន ត្រូវបានផ្តល់នៅក្នុងតំបន់ព្រៃ ដែលជាដីសាធារណៈរបស់រដ្ឋ ឬនៅតំបន់ដែលជាអតីតព្រៃសម្បទាន ផ្ទុយនឹងអនុក្រឹត្យស្តីពីការគ្រប់គ្រងព្រៃសម្បទាន។ សម្បទានទាំងនេះក៏ផ្តល់នៅ តំបន់ដែលមានជនជាតិដើមភាគតិច ដែលពួកគេមានប្រពៃណីដ៏យូរលង់ក្នុងការប្រើប្រាស់ធនធានព្រៃឈើ និងអនុផលព្រៃឈើ ដូចជាការដងជ័រដែលជារបរចិញ្ចឹមជីវិតជាដើម។

ចាប់តាំងពីមានរបាយការណ៍ឆ្នាំ២០០៤ មកយ៉ាងតិចណាស់ក៏មានសម្បទានដីសេដ្ឋកិច្ចចំនួន ៥ ដែរ ដែលត្រូវបានផ្តល់នៅក្នុងតំបន់ដែលជាអតីតព្រៃសម្បទានក្រុមហ៊ុន ឃីងវូត អីនដាស្ទ្រី (Kingwood Industry) ក្នុងខេត្ត

---

[១៨] ក្រុមហ៊ុន ភូ ម៉ាឌី អ៊ិនវេសមេន គ្រុប (Phou Mady Investment Group) និង ក្រុមហ៊ុន ហ្គ្រែនលេន អាហ្គ្រីខលឆឺរល ឌីវីឡុបមិន (Grand Land Agricultural Development) ក្នុងស្រុកសេសាន និង ក្រុមហ៊ុន ជី.ជី វើលគ្រុប (GG World Group) ក្នុងខេត្តស្ទឹងត្រែង។

[១៩] ក្រុមហ៊ុន ហ្គ្រីន ស៊ី អ៊ិនដាស្ទ្រី ត្រូវបានផ្តល់សម្បទានដីទំហំ ១០០.៨៥២ ហិកតា ក្នុងខេត្តស្ទឹងត្រែង ហើយក្រុមហ៊ុន ម៉ុង ឬទ្ធី វិនិយោគទុនដំណាំដូងប្រេង មានសម្បទានដីសេដ្ឋកិច្ច ទំហំ ១១.០០០ ហិកតា នៅក្រុងព្រះសីហនុ និងក្រុមហ៊ុន ម៉ុង ឬទ្ធី វិនិយោគដំណាំជំឡូងមីកម្ពុជា មានសម្បទានដីសេដ្ឋកិច្ចទំហំ ១.៨០០ ហិកតា នៅក្រុងព្រះសីហនុ។

[២០] ក្រុមហ៊ុនភាពីម៉ិច ត្រូវបានផ្តល់សម្បទានដីសេដ្ឋកិច្ចពីរកន្លែង ទំហំ ៣១៥.០២៥ ហិកតា ក្នុងខេត្តកំពង់ឆ្នាំង និងខេត្ត ពោធិសាត់។ ក្រុមហ៊ុន អ៊ូជីសាន អិល.អេស ហ្គ្រុប ជាក្រុមហ៊ុនដែលមាន ព្រឹទ្ធសភា លោក ស៊ី គង់ទ្រីវ ជានាយកដែរនោះ ត្រូវបានផ្តល់សម្បទានដី ទំហំ ១០.០០០ ហិកតា លើដីរបស់ជនជាតិដើមភាគតិចក្នុងខេត្ត មណ្ឌលគិរី។ សមាជិកព្រឹទ្ធសភា លោក ឡាវ ម៉េង ឃិន ក៏ជានាយកសាជីវកម្មស៊ូកាគូ អិនស៍ ដែលនៅក្នុងខែកុម្ភៈ ឆ្នាំ២០០៧ ត្រូវបានផ្តល់សម្បទានសំរាប់រយៈពេល ៩៩ ឆ្នាំ ដើម្បីអភិវឌ្ឍន៍លើដីទំហំ ១៣៣ ហិកតា នៅជុំវិញបឹងកក់ក្នុងទីក្រុងភ្នំពេញ ដែលមានប្រជាពលរដ្ឋ ប្រមាណជា ៤.២២៥ គ្រួសារប្រឈមមុខនឹងការជម្លៀសចេញ។

[២១] ក្រុមហ៊ុន មិត្តភាពម៉ែន សារ៉ុន (ឬ ម៉ែន សារ៉ុន ហ្វ្រេនស៊ីប) ត្រូវបានផ្តល់សម្បទានដីសេដ្ឋកិច្ចទំហំ ២០.០០០ ហិកតា លើដីរបស់ជនជាតិដើមភាគតិច ក្នុងខេត្តរតនគិរី ក្នុងការដាក់ទុនរួមគ្នាជាមួយ ក្រុមហ៊ុន រ៉ាម៉ាខ្មែរអន្តរជាតិ (Rama Khmer International) និងក្រុមហ៊ុនរបស់ម៉ាឡេស៊ី គ្លូបលតិច អេសឌីអេន ប៊ីអេឆឌី (Global Tech, Sdn Bhd)។ ក្រុមហ៊ុន ម៉ែន សារ៉ុន អាហារណ៍ និហរណ៍ ត្រូវបានផ្តល់សម្បទានដីសេដ្ឋកិច្ចទំហំ ៤.៤០០ ហិកតា ក្នុងស្រុកមេមត់ ខេត្តកំពង់ចាម។

ក្រចេះ និងខេត្តស្ទឹងត្រែង ។[២២] ដូចគ្នានេះដែរ ក្រុមហ៊ុន អេឆ.អឹម.អេឆ លីមិធិត (HMH Co Ltd) ត្រូវបានផ្តល់សម្បទានដីសេដ្ឋកិច្ចនៅក្នុងតំបន់ដែលជាអតីតព្រៃសម្បទានក្រុមហ៊ុន ហ្គេត អន្តរជាតិ (GAT International) ក្នុង ខេត្តកំពង់ធំ ។

ក្នុងស្រុកសេសាន ខេត្តស្ទឹងត្រែង សម្បទានិកបានកាប់រំលំដើមឈើច្បោះ ដែលជាកម្មសិទ្ធិ និងដែលបានចោះយកជ័រដោយអ្នកស្រុក ផ្ទុយនឹងមាត្រា២៩ នៃច្បាប់ស្តីពីព្រៃឈើ ។ ការកាប់ដើមឈើច្បោះនេះចាត់ទុកជាបទល្មើសព្រៃឈើ និងរំលោភលើសិទ្ធិប្រើប្រាស់ជាប្រពៃណីរបស់សហគមន៍ ដែលបានចែងទទួលស្គាល់ក្នុងជំពូក៩ នៃច្បាប់ស្តីពីព្រៃឈើ ។ ការកាប់រំលំដើមច្បោះ កើតមានផងដែរ នៅក្រៅចំការកៅស៊ូទីរីង ក្នុងស្រុកសណ្តាន់ ខេត្តកំពង់ធំ ។

## ៥. ផលប៉ះពាល់នៃសម្បទាន

ផលប៉ះពាល់នៃសម្បទានដីសេដ្ឋកិច្ចបានបន្តបង្ហាញឱ្យឃើញពីនិន្នាការដដែលៗ ដូចដែលបានចងក្រងក្នុងរបាយការណ៍ឆ្នាំ២០០៤ និងរបាយការណ៍បន្តបន្ទាប់មកទៀតដែលលោកតំណាងពិសេស បានដាក់ជូនគណៈកម្មការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ និងក្រុមប្រឹក្សាសិទ្ធិមនុស្ស ។ ផលប៉ះពាល់ទាំងនេះ រាប់បញ្ចូល ទាំងកង្វល់អំពីការខ្វះការពិគ្រោះយោបល់ជាមួយសហគមន៍មូលដ្ឋាន ការទន្ទ្រានលើដី និងផលប៉ះពាល់អវិជ្ជមាន ទៅលើការចិញ្ចឹមជីវិតជាប្រពៃណី ការជម្លៀសចេញ ផលប៉ះពាល់អវិជ្ជមានលើបរិស្ថាន ការងារ និងលក្ខខណ្ឌការងារ អំពើហឹង្សា និងការបំភិតបំភ័យ និងការខ្វះដំណោះស្រាយ ឬការជួយអន្តរាគមន៍ប្រកបដោយ ប្រសិទ្ធិភាពចំពោះសហគមន៍ដែលរងផលប៉ះពាល់ ។ របាយការណ៍នេះ គូសបញ្ជាក់បន្ថែមទៀតអំពី លំនាំនៃផលប៉ះពាល់ទាំងនេះ ដោយផ្តោតការយកចិត្តទុកដាក់ជាពិសេសចំពោះផលប៉ះពាល់លើសហគមន៍ជនជាតិដើមភាគតិច ។

### *៥.១. ការទន្ទ្រានលើដីកសិកម្ម និងដីសំរាប់ចិញ្ចឹមសត្វពាហណៈ*

ការទន្ទ្រានលើដីកសិកម្ម និងដីវាលស្មៅសំរាប់ចិញ្ចឹមសត្វ ដែលនាំដល់ការបាត់បង់របរចិញ្ចឹមជីវិត នៅតែជាកង្វល់រួមដែលបានលើកឡើងដោយសហគមន៍ ហើយបញ្ហានេះកើតមានស្ទើរតែគ្រប់សម្បទានដែលកំពុងតែមានសកម្មភាពទាំងអស់ ។ កង្វល់ទាំងនេះ ត្រូវបានលើកឡើងដោយសហគមន៍ ដែលពាក់ព័ន្ធនឹងសម្បទានច្រើនជាង ២៣ ក្នុងខេត្តចំនួន ១១ ។

---

[២២] ក្រុមហ៊ុន គ្លូបល អាហ្គ្រីខលឆឺរល ឌីវឹឡុបមិន (Global Agricultural Development) ក្រុមហ៊ុន អាស៊ី វើល អាហ្គ្រីខលឆឺរល ឌីវឹឡុបមិន (Asia World Agricultural Development) ក្រុមហ៊ុន ហ្គ្រីន អាយលេន អាហ្គ្រីខលឆឺរល ឌីវឹឡុបមិន (Green Island Agricultural Development) ក្រុមហ៊ុន សល សុភា ពាណិជ្ជ ក្រុមហ៊ុនសុភក្តិនីកា ។

ការផ្តល់សម្បទានដីដល់ ក្រុមហ៊ុន កោះកុង ស៊ូហ្គើរ អ៊ិនដាសស្ទ្រី និងក្រុមហ៊ុន កោះកុង ផ្លេនថេសិន ក្នុងខែសីហា ឆ្នាំ២០០៦ ត្រូវបានធ្វើឡើងដោយគ្មានការពិគ្រោះយោបល់ជាសាធារណៈ ។ សម្បទានទាំងនេះ ស្ថិតក្នុងស្រុកស្រែអំបិល និងស្រុកបុទុមសាគរ ដែលអ្នកស្រុកបានធ្វើកសិកម្ម ចាប់តាំងពីឆ្នាំ១៩៧៩ ។ ការឈូសឆាយដីស្រែ និងចំការដំណាំរបស់អ្នកស្រុក ក្នុងស្រុកស្រែអំបិល បានធ្វើឱ្យមានផលប៉ះពាល់ប្រជាពលរដ្ឋជាង ៤០០ គ្រួសារ ដែលគ្រួសារខ្លះ មាននៅសល់ដីបន្តិចបន្តួច ឬគ្មាននៅសល់ដីសោះ សំរាប់ធ្វើកសិកម្ម ហើយរស់នៅដោយស្រូវដែលនៅសល់ពីឆ្នាំមុន ។ សម្បទាននេះ ក៏បានធ្វើអោយមានការរិតត្បិតដល់ដីស្មៅសំរាប់ចិញ្ចឹមសត្វពាហណៈរបស់អ្នកស្រុក ហើយសន្តិសុខក្រុមហ៊ុនត្រូវគេរាយការណ៍ថា បានចាប់ ឬ បាញ់សំលាប់សត្វពាហណៈដែលចូលទៅក្នុងតំបន់សម្បទាននោះ ។ មានសេចក្តីរាយការណ៍ថា ដោយសារតែបាត់បង់ប្រភពចំណូល អ្នកស្រុកកំពុងជួបប្រទះការលំបាកជាច្រើនក្នុងការសងប្រាក់កម្ចីក្រោមគំរោងឥណទានខ្នាតតូច ។ ក្រុមហ៊ុនទាំងពីរនេះ បានពង្រីកសកម្មភាពរបស់ខ្លួន ទោះបីជាមានកិច្ចខិតខំប្រឹងប្រែងដោះស្រាយបញ្ហាជំលោះ ដែលរួមទាំងការបង្កើតក្រុមការងារថ្នាក់ខេត្ត និងកិច្ចព្រមព្រៀងឱ្យក្រុមហ៊ុនផ្អាកសកម្មភាពឈូសឆាយជាបន្ត រហូតដល់ជំលោះត្រូវបានដោះស្រាយក៏ដោយ ។[២៣] ក្នុងខែមករា ឆ្នាំ២០០៧ ដីស្រែ និងដីចំការប្រមាណជា ៥០៧ ហិកតា របស់អ្នកស្រុកត្រូវបានឈូសឆាយ ។

នៅខេត្តក្រចេះ សម្បទានដីសេដ្ឋកិច្ចចំនួន ៦ ដែលត្រូវបានផ្តល់ឱ្យក្រុមហ៊ុន គ្លូបល អាគ្រីខលឆឺរល ឌីវឺឡុបមិន (Global Agricultrual Development) ក្រុមហ៊ុន អាស៊ី វើល អាគ្រីខលឆឺរល ឌីវឺឡុបមិន (Asia World Agricultrual Development) ក្រុមហ៊ុន គ្រីន អាយលេន អាគ្រីខលឆឺរល ឌីវឺឡុបមិន (Green Island Agricultrual Development) ក្រុមហ៊ុន ផ្លេនថេស៊ិន អាគ្រីខលឆឺរល ឌីវឺឡុបមិន (Plantation Agricultrual Development) ក្រុមហ៊ុន គ្រេត អេសេធ អាគ្រីខលឆឺរល ឌីវឺឡុបមិន (Great Asset Agricultrual Development) និងក្រុមហ៊ុន គ្រេត វនឌឺ អាគ្រីខលឆឺរល ឌីវឺឡុបមិន (Great Wonder Agricultrual Development) ក្នុងស្រុកសំបូរ បានទន្ទ្រានលើដីសហគមន៍ជនជាតិភាគតិចភ្នង មីល និងគួយ ក្នុងឃុំអូរគ្រៀង ឃុំក្បាលដំរី និងឃុំរលួសមានជ័យ ។ សហគមន៍ទាំងនេះ ពឹងអាស្រ័យលើដំណាំស្រូវ និងដំណាំតាមរដូវ និងការប្រមូល និងលក់អនុផលព្រៃឈើ ។ នៅពាក់កណ្តាលឆ្នាំ២០០៦ សម្បទានិកបី បានចាប់ផ្តើម ឈូសឆាយដី និងព្រៃ ដើម្បីបង្កើតផ្លូវ និងចំការម៉ៃសាក់ និងជីកប្រឡាយដើម្បីរារាំងអ្នកស្រុក និងសត្វពាហណៈ របស់ពួកគេមិនឱ្យចូលទៅក្នុងតំបន់សម្បទាន ។ សកម្មភាពរបស់ក្រុមហ៊ុនទាំងនេះបានបំផ្លិចបំផ្លាញ ដីស្រែ និងដីចំការ របស់អ្នកស្រុក ក៏ដូចជាតំបន់ព្រៃ ។ ដោយមើលឃើញ ផលប៉ះពាល់ដំបូងនៃសម្បទានទាំងនេះ នៅពេលដែលក្រុមហ៊ុនមិនទាន់ធ្វើអាជីវកម្ម

---

[២៣] កិច្ចព្រមព្រៀងនេះ ត្រូវបានធ្វើឡើងនៅថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០០៦ នៅក្នុងការពិភាក្សាសហគមន៍ រៀបចំដោយមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ។ កិច្ចព្រមព្រៀងនេះ ត្រូវបានចុះហត្ថលេខាដោយអភិបាលរងខេត្ត អភិបាលរងស្រុក មេឃុំជីខលើ និងតំណាងក្រុមហ៊ុន កោះកុង ស៊ូហ្គើរ អ៊ិនដាសស្ទ្រី តំណាងសហគមន៍ទាំងបី មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា មជ្ឈមណ្ឌលអប់រំច្បាប់សំរាប់សហគមន៍ និងអង្គការលីកាដូ ។

ពេញលេញនៅឡើយនោះ អ្នកស្រុកមានការព្រួយបារម្ភថានឹងមិនមានដី និងធនធានព្រៃឈើគ្រប់គ្រាន់សំរាប់ការរស់រានមានជីវិតរបស់សហគមន៍ខ្លួន នៅថ្ងៃអនាគត។

នៅខេត្តកំពង់ធំ សកម្មភាពរបស់ក្រុមហ៊ុនសម្បទាន អាន ម៉ាឌី គ្រុប[២៤] បានធ្វើឱ្យប៉ះពាល់ ២៩ ភូមិ ក្នុងឃុំទូលគ្រើល និងឃុំសាលាវិស័យ ក្នុងស្រុកប្រាសាទបាល័ង្គ ដែលមានប្រជាពលរដ្ឋ ៦៥ភាគរយ ជាជនជាតិដើមភាគតិចគួយ។ ក្រុមហ៊ុនបានចាប់ផ្តើមឈូសឆាយដីក្នុងខែធ្នូ ឆ្នាំ២០០៤ មុនពេលចុះកិច្ចសន្យាក្នុងខែឧសភា ឆ្នាំ២០០៥ និងដោយគ្មានការពិគ្រោះយោបល់ជាមុនជាមួយសហគមន៍។ ក្រុមហ៊ុនបានឈូសបំផ្លាញ វាលស្រែ និងចំការដំណាំរបស់ប្រជាពលរដ្ឋជាង៣០០គ្រួសារ ហើយបានបិទផ្លូវ ដែលអ្នកស្រុកធ្លាប់ប្រើប្រាស់ ដើម្បីចូលក្នុងតំបន់ព្រៃ។ ប្រជាពលរដ្ឋជាច្រើនគ្រួសារបានរាយការណ៍អំពីការខ្វះស្បៀងអាហារ ដោយសារការបាត់បង់មុខរបរចិញ្ចឹមជីវិតរបស់ពួកគេ។

### *៥.២. ការបាត់បង់សិទ្ធិប្រើប្រាស់ព្រៃឈើ និងអនុផលព្រៃឈើ*

កង្វល់អំពីការទន្ទ្រានលើតំបន់ព្រៃដោយក្រុមហ៊ុនសម្បទាន និងការបាត់បង់មុខរបររកអនុផលព្រៃឈើត្រូវបានលើកឡើងដោយសហគមន៍ជាច្រើន ពាក់ព័ន្ធនឹងសម្បទានជាង២២ នៅក្នុងខេត្តចំនួន ៨។

ក្នុងខេត្តស្ទឹងត្រែង ដីសម្បទានចំនួន ៥កន្លែង ដែលត្រូវបានផ្តល់អោយក្រុមហ៊ុន គ្របដណ្តប់តំបន់ព្រៃក្នុងស្រុកសេសាន រួមទាំងតំបន់ព្រៃក្រាស។[២៥] តំបន់នេះ ស្ថិតក្រោមការប្រើប្រាស់ជាព្រៃណីជាយូរលង់មកហើយ ដោយជនជាតិដើមភាគតិចភ្នង ព្រៅ និងគួយ ដែលពួកគេ រស់នៅពឹងផ្អែកលើ ការធ្វើស្រែ ការប្រមូលអនុផលព្រៃឈើ និងការប្រម៉ាញ់សត្វព្រៃ។ ក្នុងឃុំ ក្បាលរមាស គ្រួសារខ្លះមានដើមច្បោះជាង ១០០ ដើម។ សកម្មភាពការងាររបស់ក្រុមហ៊ុន បានក៏រិតសិទ្ធិអ្នកស្រុក ក្នុងការចូលព្រៃដើម្បីចោះយកជ័រ និងប្រមូលអនុផលព្រៃឈើ។ ដើមច្បោះដែលជាកម្មសិទ្ធិរបស់អ្នកស្រុក ត្រូវបានគេកាប់រំលំ ដោយផ្តល់សំណងជាទឹកប្រាក់តិចតួច។[២៦] អ្នកស្រុកបានរាយការណ៍ថា សន្តិសុខប្រដាប់អាវុធដែលបំរើការឱ្យក្រុមហ៊ុន  សុភក្តិនីកា បានហាមឃាត់ពួកគេពីការធ្វើដំណើរតាមផ្លូវក្នុងព្រៃដែលគេធ្លាប់ប្រើប្រាស់កន្លងមក ដើម្បីទៅកាន់ដើមឈើច្បោះរបស់ពួកគេ។ សហគមន៍ដែលរងផលប៉ះពាល់ព្រួយបារម្ភថា ព្រៃទាំងអស់ដែលពួកគេធ្លាប់ប្រើប្រាស់ជាប្រពៃណី និងពឹងអាស្រ័យសំរាប់ចិញ្ចឹមជីវិត នឹងត្រូវបាត់បង់អស់ នៅពេលដែលសម្បទានទាំងនោះ ត្រូវបានធ្វើអាជីវកម្មយ៉ាងពេញទំហឹង។ ក្នុងឆ្នាំ២០០៥ និងឆ្នាំ២០០៦

---

[២៤] ដីសម្បទាននេះ ជារបស់លោក ឧកញ៉ា អាន ម៉ាឌី ដែលគាត់ជាប្រធានសភាពាណិជ្ជកម្ម ខេត្តកំពង់ចាម។មានការលើកឡើងថា ក្រុមហ៊ុន អាន ម៉ាឌី គ្រុប ជាប់ទាក់ទងនឹងក្រុមហ៊ុន សុភក្តិនីកា ក្រុមហ៊ុន សល សុភា ពាណិជ្ជ និងក្រុមហ៊ុន ស៊ីវ ហ្គេក ក្នុងស្រុកសេសាន ខេត្តស្ទឹងត្រែង។

[២៥] ក្រុមហ៊ុន ហ្វ្រែនលេន អាហ្គ្រីខលឆឺរល ឌីវីឡុបមិន ក្រុមហ៊ុន ភូ ម៉ាឌី អ៊ិនវេសមេន គ្រុប ក្រុមហ៊ុន សល សុភា ពាណិជ្ជ ក្រុមហ៊ុន ស៊ីវ ហ្គេក អ៊ិនវេសមេន និងក្រុមហ៊ុន សុភក្តិនីកា។

[២៦] ឧទាហរណ៍ នៅក្នុងសម្បទាន សុភក្តិនីកា ។

សហគមន៍នានាក្នុងឃុំក្បាលរមាស បានផ្តួចផ្តើមសំណើរសុំបង្កើតសហគមន៍ព្រៃឈើ ដែលសំណើរនោះនៅកំពុងរង់ចាំការចំរេច ។ដីសម្បទានមួយចំនួនដែលបានផ្តល់អោយក្រុមហ៊ុន ត្រួតគ្នាជាមួយតំបន់ដែលបានស្នើដោយសហគមន៍ ហើយគ្រប់ដណ្តប់លើព្រៃគោរពសក្ការៈរបស់សហគមន៍ទៀតផង ។

ចំពោះសហគមន៍នានា ការបាត់បង់មុខរបររកអនុផលព្រៃឈើ ជាពិសេសការដងជ័រ បានប៉ះពាល់ធ្ងន់ធ្ងរលើប្រាក់ចំណូលគ្រួសារ និងរបៀបរបបរស់នៅជាប្រពៃណី ។ អាស្រ័យទៅតាមតំបន់ និងខេត្តផ្សេងៗ សហគមន៍បានរាយការណ៍ថា ពួកគេអាចរកប្រាក់ ចំណូលបានរហូតដល់ ១០.០០០ រៀល (២,៥០ ដុល្លារ) ក្នុងមួយថ្ងៃ ដោយការដងជ័រ និងការលក់អនុផលព្រៃឈើ ។ ផ្ទុយទៅវិញ កម្មករស៊ីឈ្នួលដែលធ្វើការប្រចាំថ្ងៃនៅក្រុមហ៊ុនសម្បទានបានទទួលប្រាក់ឈ្នួលពី ៥.០០០ ទៅ ១០.០០០ រៀល (១,២៥ - ២,៥០ ដុល្លារ) ក្នុងមួយថ្ងៃ ដោយមិនមានការធានាថានឹងមានការងារធ្វើបន្ត ឬប្រាក់ចំណូលទៀងទាត់រាល់ខែនោះឡើយ ។ សហគមន៍បានកត់សំគាល់ថា ក្រុមហ៊ុនដីសម្បទានភាគច្រើន បាននាំយកកម្មករពីខេត្តផ្សេង ហើយមានអ្នកស្រុកតិចតួចប៉ុណ្ណោះ ត្រូវបានគេជួលឱ្យធ្វើការនៅទីនោះ ។

### *៥.៣. ការផ្លាស់ប្តូរទីកន្លែងរស់នៅ*

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា បញ្ជាក់ថា ប្រជាពលរដ្ឋខ្មែរគ្រប់រូប មានសិទ្ធិជាម្ចាស់កម្មសិទ្ធិលើដីធ្លី ដែលការដកហូតកម្មសិទ្ធិអំពីជនណាម្នាក់បាន លុះត្រាតែផលប្រយោជន៍សាធារណៈតម្រូវឱ្យធ្វើ ហើយត្រូវធ្វើអោយស្របច្បាប់ និងត្រូវផ្តល់សំណងជាមុនដោយសមរម្យ និងយុត្តិធម៌ ។[២៧] ប៉ុន្តែទោះជាដូច្នោះក៏ដោយ សហគមន៍ជនបទនៅទូទាំងប្រទេសកម្ពុជាត្រូវបានគេដកហូតសិទ្ធិធ្វើជាម្ចាស់លើដីធ្លី តាមរយៈការផ្តល់សម្បទានដីសេដ្ឋកិច្ច ។ ពួកគេមិនបានទទួលនូវការផ្តល់សំណងជាមុន ឬបានទទួលការផ្តល់សំណងមិនសមរម្យ និងមិនមានការបង្ហាញបញ្ជាក់អំពីផលប្រយោជន៍សាធារណៈនៃសម្បទានទាំងនេះឡើយ ។

កង្វល់អំពីការផ្លាស់ទីលំនៅរបស់ប្រជាពលរដ្ឋជាច្រើនគ្រួសារ ត្រូវបានលើកឡើងពាក់ព័ន្ធនឹងសម្បទាន អានម៉ាឌី គ្រុប ក្នុងខេត្តកំពង់ធំ ។ សម្បទាន មិត្តភាព ម៉ែន សារុន ក្នុងខេត្តរតនគិរី សម្បទានវ៉ាន់ម៉ា អាហារណ៍ និហារណ៍ ក្នុងខេត្តកំពង់ចាម ។ ជាឧទាហរណ៍ មានសេចក្តីរាយការណ៍ថា សម្បទាន អាន ម៉ាឌី គ្រុប ក្នុងខេត្តកំពង់ធំ បានជម្លៀសជនជាតិដើមភាគតិចតួយប្រមាណជា ៣០គ្រួសារ ។ ក្រុមហ៊ុនបានផ្តល់សំណងជាប្រាក់ចំនួន ៧០.០០០ ទៅ ៨០.០០០ រៀល (២០ ដុល្លារ) ក្នុងមួយហិកតា: អ្នកស្រុកខ្លះត្រូវបានបង្ខំឱ្យទទួលយកសំណងនេះ ឬត្រូវតែទទួលយកសំណងនេះព្រោះដីរបស់ពួកគេត្រូវបានឈូសឆាយអស់ហើយ ។ គ្រួសារទាំងនោះ ត្រូវបានផ្លាស់ប្តូរអោយទៅនៅលើដីឡូតិ៍

---

[២៧] មាត្រា ៤៤ ហើយឆ្លុះបញ្ចាំង ក្នុងមាត្រា ៥ នៃច្បាប់ភូមិបាល

ស្ថិតនៅតាមដងផ្លូវ ដែលវាមានទំហំតូចពេកសំរាប់ធ្វើការដាំដុះ ។ អ្នកស្រុកខ្លះបានរកពុំនឹងចិញ្ចឹមជីវិត ដោយដើរស៊ីឈ្នួលប្រចាំថ្ងៃ អ្នកខ្លះបានចាកចេញពីស្រុកភូមិ ដើម្បីទៅស្វែងរកការងារធ្វើនៅខេត្តផ្សេងទៀត ។ អ្នកខ្លះទៀតបានចូលទៅក្នុងព្រៃឆ្ងាយៗ ដើម្បីកាប់ឆ្ការដីធ្វើកសិកម្ម ។

ទន្ទឹមនឹងមានសម្បទានជាច្រើនមិនបានធ្វើអាជីវកម្មពេញលេញ គេសង្កេតឃើញថាការជម្លៀសប្រជាពលរដ្ឋអាចនឹងមានបន្តទៀត ។ទោះបីជាគ្រួសារទាំងនោះ មិនត្រូវបានគេបង្ខំឱ្យចេញក៏ដោយ ក៏ពួកគេអាចត្រូវចេញពីទីនោះដែរ ពីព្រោះថាមិនមានដីនៅសេសសល់ សំរាប់ពួកគេដាំដុះទៀតឡើយ ។

*៥.៤. ផលប៉ះពាល់លើផ្នែកសំខាន់ខាងវប្បធម៌ និងខាងជំនឿ*

កង្វល់អំពីការទន្ទ្រានៃក្រុមហ៊ុនសម្បទានមកលើដីព្រៃឈើ ឬដីដែលជាកន្លែងគោរពសក្ការៈ ត្រូវបានលើកឡើងពាក់ព័ន្ធនឹងសម្បទានចំនួន ៩ ក្នុង៦ខេត្ត ដែលប៉ះពាល់ទាំងសហគមន៍ជនជាតិដើមភាគតិច និងសហគមន៍មិនមែនជនជាតិដើមភាគតិច ។

ឧទាហរណ៍ ដីសម្បទានក្រុមហ៊ុន អ៊្វូជីសាន បានប៉ះពាល់ដីព្រៃឈើរបស់សហគមន៍ជនជាតិដើមភាគតិចភ្នង ក្នុងស្រុកអូរាំង ខេត្តមណ្ឌលគីរី ចាប់តាំងពីឆ្នាំ ២០០៤ មក ។ ក្រុមហ៊ុនបានបំពានលើព្រៃអ្នកតា និងជីកប់សពបុព្វបុរសរបស់សហគមន៍ភ្នង ដែលពួកគេមានជំនឿថា អារក្សអ្នកតាគ្រប់គ្រងលើជីវិតពួកគេនៅផ្ទះសំបែង នៅក្នុងព្រៃ និងនៅតាមដីស្រែចំការរបស់ពួកគេ ។ សកម្មភាពការងាររបស់ក្រុមហ៊ុនបានធ្វើអោយប៉ះពាល់ដល់ដីបំរុង វាលស្មៅសំរាប់ចិញ្ចឹមសត្វ និងដីស្រែចំការ ។[២៨] ទោះបីជាសហគមន៍បានសំដែងកង្វល់របស់ខ្លួន ប្រាប់ក្រុមហ៊ុន និងអាជ្ញាធរខេត្ត រដ្ឋាភិបាលបានចុះកិច្ចសន្យាសម្បទានជាមួយក្រុមហ៊ុន នៅខែធ្នូ ឆ្នាំ២០០៥ ហើយក្រុមហ៊ុនបានបន្តសកម្មភាពការងាររហូតមក ។

សម្បទានទេសចរណ៍សេដ្ឋកិច្ចមួយ ត្រូវបានផ្តល់ឱ្យក្រុមហ៊ុនញ៉ូកូស្ទ ឌីវីឡុបមិន (ខេមបូឌា) ក្នុងខែឧសភា ឆ្នាំ២០០៤ ដើម្បីបង្កើតរមនីយដ្ឋាន និងកន្លែងវាយកូនគោល ដែលធ្វើអោយប៉ះពាល់ដីព្រៃឈើរបស់ជនជាតិដើមភាគតិចសួយ ក្នុងស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ ។ ដីដែលនៅជុំវិញតេទឹកពុះធម្មជាតិ ហើយជាតំបន់ដែលមានសារសំខាន់ខាងវប្បធម៌ និងខាងជំនឿរបស់ជនជាតិសួយ ។ ក្រុមហ៊ុន និងអាជ្ញាធរមូលដ្ឋាន បានព្យាយាមជាច្រើនលើកច្រើនសារ ដើម្បីធ្វើការរុះរើរូបសំណាកជាទីសក្ការៈរបស់ជនជាតិដើមភាគតិចសួយ ឈ្មោះ យាយ តេ ពីទីតាំងដែលស្ថិតនៅជិតតេទឹកពុះធម្មជាតិ ហើយបច្ចុប្បន្ននេះសមាជិកសហគមន៍ដែលជាចាស់ទុំនៃជនជាតិដើមភាគតិចសួយ បាននៅឃ្លាំមើល

[២៨] ការវិភាគលំអិតជាងនេះ អំពីផលប៉ះពាល់នៃក្រុមហ៊ុន អ៊្វូជីសាន មាននៅក្នុងឧបសម្ព័ន្ធនៃរបាយការណ៍ ឆ្នាំ២០០៤ ដែលត្រូវបានបន្ថែមបន្ទាប់ពីការចុះផ្សាយដំបូងនៃរបាយការណ៍នេះ ។ របាយការណ៍ អាចរកបាននៅ http://cambodia.ohchr.org/report_subject.aspx.

ជាប្រចាំនៅទីនោះ ដើម្បីរារាំងការរុះរើរូបសំណាក។ សមាជិកសហគមន៍ត្រូវបានគេអនុញ្ញាតអោយចូលទៅត្រឹមតែទីដែលរូបសំណាកតាំងនៅ ប៉ុន្តែសន្តិសុខប្រដាប់អាវុធរបស់ក្រុមហ៊ុនមិនឱ្យពួកគេចូលទៅកន្លែងដទៃទៀត នៅក្នុងតំបន់សម្បទាន ដែលក៏ជាទីកន្លែងមាន សារៈសំខាន់ខាងផ្នែកជំនឿ និងផ្នែកជីវភាពរស់នៅរបស់សហគមន៍ជនជាតិដើមភាគតិចស្ទួយ។

រៀងរាល់ឆ្នាំនៅស្រុកក្រគរ ខេត្តពោធិសាត់ សហគមន៍រៀបចំពិធីបុណ្យប្រពៃណី ដើម្បីថ្លែងអំណរគុណដល់អារុក្ខអារក្សអ្នកតា និងព្រៃឈើ ដែលបានការពារ និងជួយដល់ពួកគេក្នុងឆ្នាំកន្លងមក និងដើម្បីទទួលបានពរជ័យសំរាប់ឆ្នាំបន្ទាប់។ នៅដើមឆ្នាំ២០០៥ នៅពេលដែលក្រុមហ៊ុនភាពីម៉ិច កំពុងធ្វើសកម្មភាពក្នុងឃុំនេះ អាជ្ញាធរមូលដ្ឋាន បានតម្រូវឱ្យអ្នកស្រុកសុំការអនុញ្ញាត ដើម្បីរៀបចំពិធីបុណ្យប្រពៃណីនេះ។ ព្រះគ្រូអនុគុណស្រុកក្រគរ និងប្រធានមន្ទីសាសនាស្រុក បានព្រមានព្រះសង្ឃមិនឱ្យចូលរួមក្នុងពិធីបុណ្យនេះ ដោយចាត់ទុកថាជារឿងនយោបាយ។ អ្នកស្រុក និងព្រះសង្ឃ បានប្រារព្ធពិធីបុណ្យនេះឡើង ដោយមានការឃ្លាំមើលពី នគរបាល និងអជ្ញាធរមូលដ្ឋាន។នគរបាល បានកត់ឈ្មោះព្រះសង្ឃដែលចូលរួមក្នុងពិធីនោះ ។

*៥.៥. ការបង្ខិចបំផ្លាញបរិស្ថាន*

របាយការណ៍ឆ្នាំ២០០៤ បានលើកឡើងនូវកង្វល់អំពីការកាប់ឈើមានតំលៃនៅក្នុងសម្បទានដីសេដ្ឋកិច្ច រួមទាំងសម្បទាន ក្រុមហ៊ុនហ្គ្រីន រិច (Green Rich) ក្នុងខេត្តកោះកុង និងសម្បទានក្រុមហ៊ុនផលិតម្សៅដំឡូងមី (Flour Manufacturing) ក្នុងខេត្តស្ទឹងត្រែង ដែលបើតាម សេចក្តីរាយការណ៍ថា ការកាប់ឈើនៅតែមានបន្ត។

សេចក្តីរាយការណ៍ដែលបានទទួលជាបន្តបន្ទាប់ថាការកាប់ឈើកំពុងតែប្រព្រឹត្តទៅក្នុងសម្បទានដីសេដ្ឋកិច្ចដែលបានផ្តល់អោយលើតំបន់ព្រៃឈើ។ក្រុមហ៊ុន អេឆ.អឹម.អេឆ លីមីធីត(H.M.H) បាននិងកំពុងកាប់ឈើនៅក្នុងសម្បទានរបស់ខ្លួនក្នុងខេត្តកំពង់ធំ ស្ថិតនៅក្នុងទីតាំងព្រៃសម្បទានរបស់ក្រុមហ៊ុន ហ្គេត អ៊ិនធើណាស្យូណាល (GAT International)។ សេចក្តីរាយការណ៍បានបញ្ជាក់ផងដែរថា មានការកាប់ឈើកំពុងកើតមាននៅក្នុង សម្បទានដីសេដ្ឋកិច្ច ក្នុងខេត្តក្រចេះ និងខេត្តស្ទឹងត្រែង ជាពិសេស ក្នុងស្រុកសំបូរ និងស្រុកសេសាន ជាកន្លែងដែលសម្បទានជាច្រើនត្រូវបានផ្តល់នៅលើតំបន់ព្រៃក្រាស់ រួមទាំងនៅលើអតីតទីតាំងព្រៃសម្បទានឃីងវូត (Kingwood) ផងដែរ។

ផលប៉ះពាល់ផ្សេងទៀតលើបរិស្ថាន រួមមានការប្រើប្រាស់ថ្នាំសំលាប់សត្វល្អិត និងសារជាតិគីមីដទៃទៀតដែលធ្វើឱ្យទឹកក្រខ្វក់ និងបានធ្វើឱ្យប៉ះពាល់ដល់សុខភាពរបស់សមាជិកសហគមន៍ និងសត្វពាហណៈរបស់ពួកគេ នៅក្នុងសម្បទានក្រុមហ៊ុន អ្វូជីសាន និងសម្បទានក្រុមហ៊ុនផលិតម្សៅដំឡូងមី។

## ៦.  ផលប៉ះពាល់លើជនជាតិដើមភាគតិច

សម្បទានដីសេដ្ឋកិច្ចមានផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរ ទាំងលើសហគមន៍ជនជាតិដើមភាគតិច និងសហគមន៍មិនមែនជនជាតិដើមភាគតិចដូចគ្នា ដោយលែកសហគមន៍ជនជាតិដើមភាគតិច ដែលសិទ្ធិលើកម្មសិទ្ធិដីសមូហភាពត្រូវបានការពារដោយច្បាប់កម្ពុជានោះ ជាក្រុមងាយរងគ្រោះ ។

### *៦.១. សារសំខាន់នៃដីធ្លី និងធនធានធម្មជាតិចំពោះជនជាតិដើមភាគតិច*

ដីធ្លី និងធនធានព្រៃឈើ គឺជាកត្តាសំខាន់បំផុតសំរាប់ការចិញ្ចឹមជីវិត វប្បធម៌ និងប្រពៃណីរបស់ជនជាតិដើមភាគតិចកម្ពុជា ។ ការចិញ្ចឹមជីវិតរបស់សហគមន៍ជនជាតិដើមភាគតិច ពឹងផ្អែកទាំងស្រុងលើកសិកម្មពនេចរ និងការរកអនុផលព្រៃឈើ ហើយព្រៃគឺជាកត្តាសំខាន់បំផុតសំរាប់ជីវិតវប្បធម៌ និងជំនឿ ។

កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ដែលកម្ពុជាគឺជារដ្ឋជាភាគីនោះ លើកស្ទួយសិទ្ធិក្រុមជនជាតិភាគតិច និងជនជាតិដើមភាគតិច អោយទទួលបានសិទ្ធិខាងវប្បធម៌របស់ពួកគេ ប្រកាន់យកនិងប្រតិបត្តិសាសនាតាមទម្លាប់រៀង១ខ្លួន និងប្រើប្រាស់ភាសារបស់ពួកគេ ។ គណៈកម្មាការសិទ្ធិមនុស្ស បានបញ្ជាក់ថា សិទ្ធិវប្បធម៌ ទាំងនេះរួមមានទាំង ការទទួលបាននូវរបៀបរបបរស់នៅដែលមានទំនាក់ទំនងទៅនឹងដីធ្លី និងការប្រើប្រាស់ដីធ្លី និង ធនធានធម្មជាតិ ។[២៩]

ទាំងអនុសញ្ញាលេខ១៦៩ របស់អង្គការពលកម្មអន្តរជាតិ ស្តីពីពួកកុលសម្ព័ន្ធ និងជនជាតិដើមភាគតិច ទាំងប្រកាសស្តីពីសិទ្ធិជនជាតិដើមភាគតិចដែលអនុម័តដោយក្រុមប្រឹក្សាសិទ្ធិមនុស្ស នៅថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០០៦ ទទួលស្គាល់ជាពិសេស សិទ្ធិរបស់សហគមន៍ជនជាតិដើមភាគតិច នូវសិទ្ធិសមូហភាពលើដីធ្លី ហើយកត់សំគាល់អំពីការទទួលខុសត្រូវរបស់រដ្ឋាភិបាល ក្នុងការការពារសិទ្ធិទាំងនេះ ។ ច្បាប់កម្ពុជាក៏បានទទួលស្គាល់យ៉ាងច្បាស់អំពីសិទ្ធិសហគមន៍ជនជាតិដើមភាគតិច នូវកម្មសិទ្ធិសមូហភាពលើដីធ្លីរបស់ខ្លួន និងការប្រើប្រាស់ជាប្រពៃណីនៃធនធានព្រៃឈើ ។[៣០]

---

[២៩] សេចក្តីផ្តល់មតិទូទៅលេខ២៣ របស់គណៈកម្មាធិការសិទ្ធិមនុស្ស : សិទ្ធិជនជាតិភាគតិច ( មាត្រា២៧ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ) ថ្ងៃទី៨ ខែមេសា ឆ្នាំ១៩៩៤ ។ សូមមើលកំរងប្រចាំឆ្នាំ HRI/GEN/1/Rev.8.

[៣០] សូមមើលជំពូក៣ នៃច្បាប់ភូមិបាល និង ជំពូក៩ នៃច្បាប់ស្តីពីព្រៃឈើ

### *៦.២. សម្បទានដីសេដ្ឋកិច្ច និងសម្បទានដទៃទៀតនៅក្នុងតំបន់ជនជាតិដើមភាគតិច*

នៅខេត្តភាគឦសាន ដូចជាខេត្តរតនគីរីនិងខេត្តមណ្ឌលគីរី មានជនជាតិដើមភាគតិចច្រើនលើសលប់រស់នៅ ហើយក៏មានជនជាតិដើមភាគតិចច្រើនណាស់ដែរនៅខេត្តក្រចេះ និងខេត្តស្ទឹងត្រែង។ សហគមន៍ក្នុងតំបន់ទាំងនេះ បានកំពុងតែរងសំពាធនៃការផ្ទេរកម្មសិទ្ធិដីធ្លីតាមរយៈ " ការដណ្តើមយកដីធ្លី " និងការលក់ដីដោយមានការបង្ខិតបង្ខំ ឬដោយ ខុសច្បាប់។[៣១] ការផ្តល់សម្បទានដីសេដ្ឋកិច្ច និងសម្បទានដទៃទៀត គឺជាការផ្ទេរកម្មសិទ្ធិដីធ្លីយ៉ាងឆាប់រហ័ស ហើយសម្បទានទាំងនេះកំពុងតែគំរាមកំហែងដល់ ជីវភាពរស់នៅ វប្បធម៌ និងសុខមាលភាពរបស់សហគមន៍ជនជាតិដើមភាគតិច។

សម្បទានដីសេដ្ឋកិច្ចយ៉ាងតិច ២៥ ត្រូវបានគេដឹងថា ប៉ះពាល់ដីជនជាតិដើមភាគតិចក្នុងខេត្តកំពង់ធំ ក្រចេះ មណ្ឌលគីរី ឧត្តរមានជ័យ រតនគីរី និងស្ទឹងត្រែង។ សម្បទានដទៃទៀត ដែលបានផ្តល់លើដីជនជាតិដើមភាគតិចរួមមាន សម្បទានទេសចរណ៍សេដ្ឋកិច្ច នៅក្នុងស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ និងនៅទឹកធ្លាក់ប៊ូស្រា ខេត្តមណ្ឌលគីរី និងអាជ្ញាប័ណ្ណរ៉ែជាច្រើន ដែលប៉ះពាល់លើដីជនជាតិដើមភាគតិច ក្នុងខេត្តមណ្ឌលគីរី ពោធិសាត់ និងព្រះវិហារ។

នៅចុងឆ្នាំ២០០៦ អាជ្ញាប័ណ្ណមួយត្រូវបានផ្តល់ឱ្យក្រុមហ៊ុន ប៊ី.អេឆ.ភី. ប៊ីលីតុន និងសាជីវកម្មមីតស៊ុយប៊ីស៊ី ដើម្បីធ្វើការរុករករ៉ែបុកស៊ីតលើដីទំហំ ១០០.០០០ ហិកតា ក្នុងខេត្តមណ្ឌលគីរី ដែលត្រួតលើដីសម្បទានរបស់ក្រុមហ៊ុនអ៊ូជីសាន  និងលាតសន្ធឹងលើដីព្រៃរបស់ជនជាតិដើមភាគតិច។ សម្បទានរ៉ែដទៃទៀត ប៉ះពាល់ដីជនជាតិដើមភាគតិចក្នុងស្រុកវាលវែង ខេត្តពោធិសាត់ និងស្រុករវៀង ខេត្តព្រះវិហារ។ ចំនួនកើនឡើងនៃសម្បទានរ៉ែ បានបង្កឱ្យមានកង្វល់អំពីផលប៉ះពាល់ដែលនឹងកើតមានចំពោះសហគមន៍ជនជាតិដើមភាគតិច សិទ្ធិ និងការចិញ្ចឹមជីវិតរបស់ពួកគេ។

### *៦.៣. ការផ្ទេរកម្មសិទ្ធិដីជនជាតិដើមភាគតិច និងការចុះបញ្ជីកម្មសិទ្ធិដីសមូហភាព*

រដ្ឋាភិបាលបានគូសបញ្ជាក់ជាច្រើនលើកច្រើនសារថា ខ្លួនមានគំរោងដាក់ខេត្តភាគឦសាននៃកម្ពុជាទៅជាប៉ូលទីបួន នៃការអភិវឌ្ឍន៍កម្ពុជា បន្ទាប់ពីក្រុងភ្នំពេញ ខេត្តសៀមរាប និងក្រុងព្រះសីហនុ នៅឆ្នាំ២០១៥។[៣២] រ៉ែ

---

[៣១] សំរាប់ការវិភាគអំពីការផ្ទេរកម្មសិទ្ធិដីធ្លីរបស់ជនជាតិដើមភាគតិច ក្នុងខេត្តរតនគីរី សូមមើលរបាយការណ៍របស់វេទិកាអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា ដែលមានចំណងជើងថា *ការផ្ទេរកម្មសិទ្ធិដីធ្លីក្នុងសហគមន៍ជនជាតិដើមភាគតិច - ខេត្តរតនគីរី កម្ពុជា* ខែសីហា ឆ្នាំ២០០៦ ដែលអាចរកឃើញតាម http://www.ngoforum.org.kh/Land/Docs/Dos4.htm.

[៣២] ក្នុងសន្ទរកថាបើកសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិស្តីពីសេចក្តីព្រាងគោលនយោបាយស្តីពីការចុះបញ្ជី និងសិទ្ធិប្រើប្រាស់ដីសហគមន៍ជនជាតិដើមភាគតិចនៅកម្ពុជា លោក អ៊ឹម ឈុនលឹម រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ បានគូសបញ្ជាក់ថា រាជរដ្ឋាភិបាល

កសិ-ឧស្សាហកម្ម និងទេសចរណ៍សេដ្ឋកិច្ច ត្រូវបានគេចាត់ទុកថាជាកំលាំងចលករ ដើម្បីជំរុញឱ្យមានការរីកចំរើននេះ ដូច បានកត់សំគាល់ដោយនាយករដ្ឋមន្ត្រី នាសម័យប្រជុំមួយជាមួយនាយករដ្ឋមន្ត្រីវៀតណាម និងឡាវ ក្នុងខែធ្នូឆ្នាំ ២០០៦។ ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ចរបស់រដ្ឋាភិបាលក្នុងខេត្តភាគឦសាន ហាក់ដូចជាដាក់ទណ្ឌកម្ម និងជាប្រផ្នូលនៃ ការផ្ទេរកម្មសិទ្ធិដីជនជាតិដើមភាគតិចជាបន្តទៀត។

ការផ្ទេរកម្មសិទ្ធិដីជនជាតិដើមភាគតិច តាមរយៈការផ្តល់សម្បទានដីសេដ្ឋកិច្ច និងសម្បទានដទៃទៀត កំពុង ធ្វើឱ្យខូចលទ្ធភាពរបស់សហគមន៍ជនជាតិដើមភាគតិច ក្នុងការចុះបញ្ជីកម្មសិទ្ធិសមូហភាពនូវដីប្រពៃណី និងការអនុវត្ត សិទ្ធិលើដីធ្លីរបស់ពួកគេតាមច្បាប់ភូមិបាល។ នៅចំពោះមុខនៃការបន្តផ្ទេរកម្មសិទ្ធិដីធ្លីក្នុងតំបន់ជនជាតិដើមភាគតិច មានកង្វល់កាន់តែខ្លាំងឡើងអំពីការនៅសល់ដីធ្លីតិចតួចសំរាប់ចុះបញ្ជី រហូតដល់ពេលដែលក្របខ័ណ្ឌសំរាប់ការចុះបញ្ជី សហគមន៍ជនជាតិដើមភាគតិច និងកម្មសិទ្ធិដីសមូហភាពត្រូវបានអនុម័ត។

វិធានការភ្លាមៗ និងជាបន្ទាន់ ត្រូវតែចាត់អោយមានឡើង ដើម្បីការពារ និងអនុវត្តសិទ្ធិកម្មសិទ្ធិរបស់ជនជាតិ ដើមភាគតិចលើដីប្រពៃណីរបស់ពួកគេ។ ទោះបីជាច្បាប់ភូមិបាល ទទួលស្គាល់សិទ្ធិសហគមន៍ជនជាតិដើមភាគតិចនូវ កម្មសិទ្ធិសមូហភាពលើដីធ្លីរបស់ខ្លួនក្តី កិច្ចដំណើរការនៃការបង្កើតក្របខ័ណ្ឌសំរាប់ចុះបញ្ជីសហគមន៍ជនជាតិដើម ភាគតិចជានីតិបុគ្គល ដែលអាចមានសិទ្ធិ និងទទួលបានកម្មសិទ្ធិសមូហភាព បានអូសបន្លាយពេលយ៉ាងវែង ហើយនៅ មិនទាន់បានអនុម័តនៅឡើយ។ ក្នុងខណៈនេះដែរ សម្បទានដីសេដ្ឋកិច្ច និងសម្បទានដទៃទៀត ត្រូវបានបន្តផ្តល់នៅ លើដីរបស់ជនជាតិដើមភាគតិច។

រដ្ឋាភិបាលបានបង្កើតសេចក្តីព្រាងគោលនយោបាយស្តីពីការចុះបញ្ជី និងសិទ្ធិប្រើប្រាស់ដីសហគមន៍ជនជាតិ ដើមភាគតិចនៅកម្ពុជា ដែលនៅពេលកំពុងធ្វើរបាយការណ៍នេះ នៅមិនទាន់បានអនុម័តនៅឡើយទេ។ ស្ថិតក្នុងទម្រង់ បច្ចុប្បន្នរបស់វា ក្របខ័ណ្ឌគោលនយោបាយដែលបានស្នើសំរាប់ការចុះបញ្ជីដីជនជាតិដើមភាគតិច មិនបានឆ្លុះបញ្ចាំង យ៉ាងពេញលេញ និងការពារសិទ្ធិជនជាតិដើមភាគតិចលើដីធ្លី និងធនធានធម្មជាតិ ដូចដែលបានធានាការពារដោយ ច្បាប់ភូមិបាល និងច្បាប់ព្រៃឈើឡើយ។ ប្រការដែលជាកង្វល់ខ្លាំងបំផុតនោះគឺ សេចក្តីព្រាងគោលនយោបាយនេះ បានស្នើឡើងនូវចលនាមួយអោយឃ្លាតឆ្ងាយពីកសិកម្មពនេចរ ដែលជាផ្នែកមួយនៃរបៀបរបបរស់នៅតាមប្រពៃណី និងទំនៀមទំលាប់របស់សហគមន៍ជនជាតិដើមភាគតិច ហើយដែលត្រូវបានទទួលស្គាល់ជាពិសេសក្នុងច្បាប់ភូមិបាល និងច្បាប់ស្តីពីព្រៃឈើ។

---

កម្ពុជាមានទស្សនៈវិស័យជំរុញការអភិវឌ្ឍន៍ក្នុងតំបន់ជនជាតិដើមភាគតិច នៅភាគឦសាននៃកម្ពុជា រួមទាំងតាមរយៈ ការកសាងហេដ្ឋារចនាសម្ព័ន្ធ ដើម្បីប្រែក្លាយតំបន់នេះទៅជាប៉ូលអភិវឌ្ឍន៍ទីបួននៃកម្ពុជា នៅឆ្នាំ២០១៥។

*៦.៤. ផលប៉ះពាល់ផ្សេងទៀតលើសហគមន៍ជនជាតិដើមភាគតិច*

វត្តមានរបស់ក្រុមហ៊ុនដីសម្បទាន បានបានបង្កឱ្យមានការជួញដូរដីធ្លីនៅក្នុងតំបន់ជនជាតិដើមភាគតិច ដែលវាបន្តកំរិតសិទ្ធិជនជាតិដើមភាគតិចលើដីប្រពៃណីរបស់ខ្លួន ។ ដោយសារការផ្តល់សម្បទានដីសំរាប់ទេសចរណ៍សេដ្ឋកិច្ចឱ្យក្រុមហ៊ុនញ៉ូកូស្នួស នៅស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ សហគមន៍ជនជាតិដើមភាគតិចសួយបាន ប្រឈមមុខនឹងការផ្ទេរសិទ្ធិកាន់កាប់ដីធ្លី និងបានបង្កើនសំពាធលើដីដែលមានសំរាប់ការប្រើប្រាស់របស់ពួកគេ ។ អាជ្ញាធរឃុំបានលក់ដីបំរុងទុកសំរាប់សហគមន៍ប្រើប្រាស់នៅថ្ងៃអនាគត រួមទាំងដីដែលបានប្រើប្រាស់សំរាប់ប្រមូលយកអនុផលព្រៃឈើ ។ ប្រជាពលរដ្ឋមកពីខាងក្រៅតំបន់នោះ រួមទាំងមន្ត្រីរដ្ឋាភិបាលមកពីក្រុងភ្នំពេញ បានទិញដី និងសាងសង់ផ្ទះធំៗនៅក្នុងតំបន់នោះ ។ មានតែផ្នែកតូចមួយនៃដីបំរុង ដែលនៅសេសសល់ ហើយដែលបានក្លាយជាប្រភពមួយនៃទំនាស់នៅក្នុងសហគមន៍ ដោយសារមិនមានដីគ្រប់គ្រាន់សំរាប់បំពេញសេចក្តីត្រូវការរបស់គ្រួសារទាំងនោះ ។ នៅក្នុងដំណើរទស្សនកិច្ចរបស់ខ្ញុំទៅកាន់តំបន់ដីសម្បទាននេះ ក្នុងខែមីនា ឆ្នាំ២០០៦ តំណាងសហគមន៍ជនជាតិសួយជាច្រើននាក់បានសំដែងកង្វល់អំពីអនាគតរបស់ពួកគេ ពីព្រោះបច្ចុប្បន្ននេះ ដីធ្លីភាគច្រើនដែលសហគមន៍ពួកគេប្រើប្រាស់ត្រូវបានបាត់បង់ ។

សហគមន៍ជនជាតិដើមភាគតិចបានសំដែងកង្វល់អំពីវប្បធម៌ របៀបរបបរស់នៅជាប្រពៃណី និងអត្តសញ្ញាណរបស់ពួកគេ ដែលកំពុងទទួលរងការគំរាមកំហែង ។ ពួកគេមានការភ័យខ្លាចថា ការបាត់បង់ដីធ្លី និងព្រៃឈើនេះនឹងឈានទៅរកការបាត់បង់វប្បធម៌របស់ពួកគេ ព្រោះថាមនុស្សជំនាន់ក្រោយនឹងមិនមានអ្វីធ្វើជាសំអាងអំពីវប្បធម៌របស់ខ្លួនឡើយ ។ ដូចតំណាងសហគមន៍ជនជាតិដើមភាគតិចបានគូសបញ្ជាក់ហើយថា ដីធ្លីគឺជាអាយុជីវិត ហើយប្រសិនជាគ្មានដីធ្លីទេ គឺគ្មានអាយុជីវិត សំរាប់សហគមន៍ជនជាតិដើមភាគតិចទាំងនោះឡើយ ។

## ៧. សិទ្ធិទទួលបានការដោះស្រាយប្រកបដោយប្រសិទ្ធិភាព

*៧.១. វិធានការរបស់សហគមន៍*

ប្រឈមមុខនឹងការទន្ទ្រានៃក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច ដែលបាន និងកំពុងតែបំផ្លិចបំផ្លាញមធ្យោបាយចិញ្ចឹមជីវិត និងបង្កគ្រោះថ្នាក់ដល់អនាគតនៃការរស់រានមានជីវិតរបស់ខ្លួន សហគមន៍បានសំដែងមតិជំទាស់ទៅនឹងវត្តមាន និងសកម្មភាពរបស់ក្រុមហ៊ុនដីសម្បទាន ហើយបានអំពាវនាវសុំឱ្យចាត់វិធានការធានាការពារប្រភពចិញ្ចឹមជីវិតរបស់ខ្លួន ។ អ្នកស្រុកបានប្រើប្រាស់វិធានការ តាមរយៈញត្តិ និងការតវ៉ាជាសាធារណៈ ដើម្បីជូនដំណឹងទៅសម្បទានិក និងអាជ្ញាធររដ្ឋាភិបាលអំពី ផលប៉ះពាល់នៃសម្បទានទៅលើដីធ្លី និងការចិញ្ចឹមជីវិតរបស់ពួកគេ ។

ទោះបីជាអ្នកស្រុកធ្វើការតវ៉ា និងផ្ញើរញ្ញត្តិទៅអាជ្ញាធរថ្នាក់ស្រុក ថ្នាក់ខេត្ត និងថ្នាក់ជាតិក៏ដោយ ក៏កង្វល់របស់ពួកគេមិនត្រូវបានគិតគូរ និងដោះស្រាយឡើយ ។ នៅក្នុងករណីខ្លះ មានការសន្យាថានឹងចាត់វិធានការដើម្បីដោះស្រាយបញ្ហាជំលោះនេះ ប៉ុន្តែទោះជាយ៉ាងនេះក្តី ដំណោះស្រាយនៅតែមិនបានទទួលលទ្ធផលគួរជាទីគាប់ចិត្តឡើយ ។ ទន្ទឹមនឹងនេះ ក្រុមហ៊ុនបន្តឈូសឆាយដី និង រុករានទន្រ្ទានលើដីស្រែចំការរបស់អ្នកស្រុក ។

ឧទាហរណ៏ ចាប់ពីខែឧសភា ឆ្នាំ២០០៦ អ្នកស្រុកស្រែអំបិល ខេត្តកោះកុង បានធ្វើការតវ៉ាប្រឆាំងនឹងវត្តមាន និងសកម្មភាពរបស់ក្រុមហ៊ុន កោះកុង ស៊ូហ្គើរ អ៊ិនដាសស្ទ្រី និងក្រុមហ៊ុន កោះកុង ផ្លេនថេសិន ។ ក្នុងខែកញ្ញា ឆ្នាំ ២០០៦ ការតវ៉ានៅការដ្ឋានសម្បទាននេះ បានឈានដល់ការប្រើអំពើហឹង្សា ដោយកំលាំងសន្តិសុខប្រដាប់អាវុធរបស់ក្រុមហ៊ុន ដែលជាបុគ្គលិកយោធា បណ្តាលឱ្យមានការផ្ទុះអាវុធ និងធ្វើឱ្យអ្នកស្រុកស្ត្រីម្នាក់រងរបួស និងបានវាយដំអ្នកស្រុកបួននាក់ផ្សេងទៀត ។ អ្នកស្រុកបានពាំនាំកង្វល់របស់ខ្លួនប្រាប់រដ្ឋសភា និងខុទ្ទកាល័យនាយករដ្ឋមន្ត្រី និងបានដាក់ពាក្យបណ្តឹងទៅអាជ្ញាធរជាតិដោះស្រាយជំលោះដីធ្លី ព្រមទាំងបានធ្វើការតវ៉ានៅខាងមុខរដ្ឋសភា ក្នុងខែកក្កដា ឆ្នាំ ២០០៦ និងខែមីនា ឆ្នាំ២០០៧ ។ ទោះបីជាអាជ្ញាធរខេត្តបានសន្យាដោះស្រាយជំលោះនេះក៏ដោយ ក៏សម្បទានិកនៅតែរុករានទន្ទ្រានយកដីស្រែចំការរបស់អ្នកស្រុកជាបន្តទៀត ។

ចាប់តាំងពីខែមិថុនា ឆ្នាំ២០០៦ សហគមន៏ក្នុងស្រុកសំបូរ ខេត្តក្រចេះបានសំដែងកង្វល់ប្រាប់អាជ្ញាធរឃុំ និងតំណាងក្រុមហ៊ុន  អំពីសកម្មភាពរបស់ក្រុមហ៊ុនប្រាំមួយ ដែលត្រូវបានផ្តល់សម្បទាន ។ នៅពាក់កណ្តាលខែមករា ឆ្នាំ២០០៧ បន្ទាប់ពីអ្នកស្រុកមួយក្រុមបានទៅការដ្ឋានក្រុមហ៊ុន ហ្គ្រីន អាយលេន ស្នើសុំជួបប្រជុំដើម្បីដោះស្រាយកង្វល់របស់ខ្លួន តំណាងក្រុមហ៊ុនម្នាក់ និងលោក ធន់ គ្រី អភិបាលរងខេត្ត បានជួបជាមួយអ្នកស្រុកប្រមាណជា២០០ នាក់ ។ តំណាងរដ្ឋបាលព្រៃឈើ និងអាជ្ញាធរស្រុក កងរាជអាវុធហត្ថ និងនាយទាហានមួយចំនួន ក៏មានវត្តមាននៅទីនោះដែរ ។ មានការសន្យាថា សម្បទានិកត្រូវបញ្ឈប់សកម្មភាព ហើយដោះស្រាយបណ្តឹងរបស់អ្នកស្រុក ។ នៅថ្ងៃទី២៩ ខែមករា ឆ្នាំ២០០៧ មានការប្រជុំមួយទៀត ជាមួយអ្នកស្រុក ២៥ នាក់ដែលទទួលរងផលប៉ះពាល់ នៅសាលាខេត្ត ដើម្បីពិភាក្សារកមធ្យោបាយដោះស្រាយជំលោះ ។ ទោះជាយ៉ាងណាក៏ដោយ សម្បទានិកនៅតែបន្តពង្រីកសកម្មភាពរបស់ខ្លួន ហើយធ្វើការឈូសឆាយដីរបស់សហគមន៍ជាដដែល ។

ក្នុងខែមីនា ឆ្នាំ២០០៧ អ្នកស្រុកជនជាតិដើមភាគតិចក្នុងឃុំក្បាលរមាសបានធ្វើបាតុកម្មប្រឆាំងនឹងសកម្មភាពរបស់ក្រុមហ៊ុនប្រាំ ក្នុងស្រុកសេសាន ខេត្តស្ទឹងត្រែង ដែលកំពុងគំរាមកំហែងយកដីចំការ និងសិទ្ធិប្រមូលអនុផលព្រៃឈើរបស់ពួកគេ ។ អ្នកស្រុកបានទាមទារឱ្យក្រុមហ៊ុនបញ្ឈប់សកម្មភាពនៅជុំវិញភូមិរបស់ខ្លួន បញ្ឈប់ការកាប់ដើមឈ្មោះ ហើយធ្វើការវាស់វែងព្រំដីរបស់ខ្លួនឱ្យបានច្បាស់លាស់ ។ មួយសប្តាហ៏ក្រោយមក អភិបាលខេត្តស្ទឹងត្រែងបានទៅតំបន់នោះ ដើម្បីនិយាយជាមួយអ្នកស្រុក និងប្រាប់មន្ត្រីមូលដ្ឋាន ឱ្យកំណត់ព្រំប្រទល់សម្បទានផ្សេងៗនៅមុនថ្ងៃចូល ឆ្នាំខ្មែរ ខែមេសា ឆ្នាំ២០០៧ ។ ទោះជាយ៉ាងណាក៏ដោយព្រំប្រទល់ដីសម្បទាន មិនទាន់ត្រូវបាន

កំណត់នៅឡើយ ហើយក៏មិនដឹងច្បាស់ថា តើនឹងមានវិធានការអ្វីខ្លះ ដើម្បីជួសជុលការខូចខាតនៃការបំផ្លាញដីធ្លីរបស់ប្រជាពលរដ្ឋ។

*៧.២. បរិយាកាសនៃការបំពេញការងាររបស់សង្គមស៊ីវិល និងសហគមន៍*

សមាជិកសហគមន៍ និងអង្គការក្រៅរដ្ឋាភិបាលនានា ដែលបានសំដែងកង្វល់អំពីផលប៉ះពាល់នៃសម្បទានដីសេដ្ឋកិច្ច បានប្រឈមមុខនឹងការរិតត្បិតសេរីភាពក្នុងការធ្វើដំណើរ និងការជួបប្រជុំ និងការគាបសង្កត់ពីក្រុមហ៊ុន និងអាជ្ញាធរមូលដ្ឋាននានា។

ដូចជា ក្នុងខេត្តមណ្ឌលគីរី ចាប់តាំងពីសហគមន៍បានប្រមូលផ្តុំគ្នា ដើម្បីធ្វើការតវ៉ាប្រឆាំងក្រុមហ៊ុនសម្បទានអ៊ូជីសាន មក សមាជិកសហគមន៍ត្រូវបានគេតម្រូវឱ្យសុំការអនុញ្ញាតពីអាជ្ញាធរមូលដ្ឋាន ដើម្បីធ្វើដំណើរចេញក្រៅខេត្ត ជាពិសេសដើម្បីចូលរួមប្រជុំផ្សេង១ ដែលរៀបចំដោយអង្គការក្រៅរដ្ឋាភិបាលនានា។ ក្នុងខេត្តកំពង់ស្ពឺ ជនជាតិដើមភាគតិចសួយ ដែលទទួលរងផលប៉ះពាល់ដោយសម្បទានទេសចរណ៍សេដ្ឋកិច្ចរបស់ក្រុមហ៊ុនញ៉ូកូស្វូស ត្រូវបានគេរារាំង មិនឱ្យរៀបចំប្រជុំសហគមន៍ ហើយតំណាងសហគមន៍ម្នាក់ ត្រូវបានទទួលការគាបសង្កត់ពីអាជ្ញាធរមូលដ្ឋាន។ ជាច្រើនលើកច្រើនសារ តំណាងសហគមន៍រូបនេះ ត្រូវបាននគរបាលស្រុកហៅមកសាកសួរ ហើយត្រូវមន្ត្រីនគរបាល និងអាជ្ញាធរឃុំ តាមដាន និងបានព្រមានកុំឱ្យទាក់ទងជាមួយអង្គការក្រៅរដ្ឋាភិបាល។ ក្នុងកំឡុងពេលនៃការតវ៉ារបស់សហគមន៍ ក្នុងស្រុកសេសាន ខេត្តស្ទឹងត្រែង ក្នុងខែមីនា ឆ្នាំ២០០៧ សមាជិកសកម្មមួយចំនួនរបស់សហគមន៍ ត្រូវបានព្រមាន ដោយអាជ្ញាធរមូលដ្ឋានកុំឱ្យបង្កបញ្ហា។

អង្គការក្រៅរដ្ឋាភិបាលនានា ក៏បានប្រឈមមុខនឹងការរិតត្បិតក្នុងការងាររបស់ខ្លួនជាមួយសហគមន៍ផងដែរ ហើយនៅក្នុងករណីខ្លះ ការចូលទៅក្នុងតំបន់ដែលរងផលប៉ះពាល់ដោយសម្បទាន ត្រូវបានដាក់កំរិត។ នៅពេលដែលសហគមន៍បានចាប់ផ្តើមធ្វើការតវ៉ាប្រឆាំងនឹងវត្តមានរបស់ក្រុមហ៊ុន កោះកុង ស៊ូហ្គើរ អ៊ិនដាសស្ទ្រី និងក្រុមហ៊ុនកោះកុង ផ្លេនថេសិន ក្នុងស្រុកស្រែអំបិល មានការរិតត្បិតអង្គការក្រៅរដ្ឋាភិបាលមិនឱ្យចូលក្នុងតំបន់នោះ។ អាជ្ញាធរថ្នាក់ឃុំ ស្រុក និងខេត្ត បានរារាំងអង្គការក្រៅរដ្ឋាភិបាលនានា ដូចជា សមាជិកគណៈកម្មាធិការប្រព្រឹត្តកម្មនៃអង្គការ-សមាគមន៍ការពារសិទ្ធិមនុស្សកម្ពុជា មិនឱ្យចូលក្នុងភូមិទាំងឡាយ ក្នុងឃុំជីខលើ ហើយបានព្រមានពួកគេមិនឱ្យញុះញង់អ្នកភូមិ។ ការប្រជុំជាមួយ សមាជិកសហគមន៍ត្រូវបាននគរបាលឃ្លាំមើល បើតាមការអះអាងគឺដើម្បីគោលបំណងសន្តិសុខ។ ដូចគ្នានេះដែរ អង្គការអភិវឌ្ឍន៍សេដ្ឋកិច្ចសហគមន៍ (CED) ដែលជាអង្គការក្រៅរដ្ឋាភិបាលមួយក្នុងខេត្តក្រចេះ បានប្រឈមមុខនឹងការគំរាមកំហែង និងការរិតត្បិតចំពោះការងាររបស់ខ្លួនជាមួយសហគមន៍ទាំងឡាយ ដែលរងផលប៉ះពាល់ដោយសម្បទានដីសេដ្ឋកិច្ចក្នុងស្រុកសំបូរ។ អាជ្ញាធរខេត្តតម្រូវឱ្យអង្គការអភិវឌ្ឍន៍សេដ្ឋកិច្ច

សហគមន៍ សុំការអនុញ្ញាតជាមុន ដើម្បីរៀបចំសកម្មភាពសហគមន៍ក្នុងស្រុកសំបូរ ប៉ុន្តែការរិតត្បិតនេះមិនអនុវត្ត ចំពោះស្រុកដទៃទៀតឡើយ ។

សហគមន៍ទាំងឡាយ ដែលរងផលប៉ះពាល់ដោយសម្បទានដីសេដ្ឋកិច្ច ក៏ប្រឈមមុខនឹងការគាបសង្កត់ពី សម្បទានិក និងមន្ត្រីមូលដ្ឋាន ឱ្យទទួលយកវត្តមាននៃសម្បទាន ហើយឱ្យបញ្ឈប់ការតវ៉ារបស់ខ្លួន ។ ក្រុមហ៊ុនបាន ព្យាយាម " ទិញទឹកចិត្ត " សហគមន៍ និងគ្រួសារប្រជាពលរដ្ឋនានា ដោយការជប់លៀង ការផ្តល់អំណោយ និងការ ផ្តល់ជាលុយកាក់ផ្សេងៗ ។ ការនេះធ្វើឱ្យមានការបែកបាក់គ្នានៅក្នុងសហគមន៍ ហើយការគាបសង្កត់នេះអាចនាំឱ្យមាន ជំលោះនៅក្នុងសហគមន៍ទៀតផង ។ សមាជិកសហគមន៍ស្ថិតក្នុងស្ថានភាពមួយដែលលំបាក កំពុងប្រឈមមុខនឹងការ បាត់បង់ដីធ្លីរបស់ខ្លួន និងការតស៊ូរិះរកមធ្យោបាយផ្គត់ផ្គង់ជីវភាពគ្រួសាររបស់ខ្លួន ។

ជំនួសឱ្យការស្តាប់អំពីកង្វល់របស់សហគមន៍ មន្ត្រីរដ្ឋាភិបាល និងតំណាងក្រុមហ៊ុនបានចោទប្រកាន់សមាជិក សហគមន៍ថាជា " សមាជិកគណបក្សប្រឆាំង " ហើយបានចោទប្រកាន់អង្គការក្រៅរដ្ឋាភិបាលថា " ញុះញង់ " អ្នក ស្រុកឱ្យធ្វើការតវ៉ា និងបង្កឱ្យមានភាពចលាចល បំបាក់ទឹកចិត្តវិនិយោគិន និងបន្ថយបង្អាក់ដល់ការអភិវឌ្ឍន៍ ។

*៧.៣. ការប្រើប្រាស់ប្រព័ន្ធយុត្តិធម៌*

ក្នុងករណីមួយចំនួន ការចោទប្រកាន់ពីបទព្រហ្មទណ្ឌត្រូវបានធ្វើឡើងប្រឆាំងនឹង សមាជិកសហគមន៍ ដែល បានសកម្មក្នុងការរៀបចំសហគមន៍របស់ខ្លួន និងបានធ្វើការតវ៉ាប្រឆាំងនឹងផលប៉ះពាល់នៃសម្បទាន ។ ប៉ុន្តែប្រព័ន្ធ យុត្តិធម៌ មិនត្រូវបានគេប្រើប្រាស់ ដើម្បីលើកស្ទួយសិទ្ធិរបស់សហគមន៍ឡើយ ហើយក្រុមហ៊ុនដែលបំពានច្បាប់ មិនត្រូវបានដាក់ឱ្យទទួលខុសត្រូវចំពោះ អំពើបំពានច្បាប់របស់ពួកគេទេ ។

ក្នុងខែធ្នូ ឆ្នាំ២០០៥ សកម្មជនសហគមន៍បីនាក់ ក្នុងខេត្តពោធិសាត់ ឈ្មោះ គុជ វេង, ហង្ស គាល និងឡុង សាមាន ត្រូវបានចោទប្រកាន់ពីបទញុះញង់ និងបំផ្លិចបំផ្លាញទ្រព្យសម្បត្តិ ។ ក្រុមហ៊ុនសម្បទាន រតនាវិសាល បានដាក់ ពាក្យបណ្តឹង បន្ទាប់ពីបុរសពីរនាក់ ក្នុងចំណោមបុរសទាំងបីនាក់បានចុះហត្ថលេខាលើញត្តិមួយ ក្នុងនាមសហគមន៍ដែល រងផលប៉ះពាល់ ដើម្បីធ្វើការតវ៉ាទៅអាជ្ញាធរប្រឆាំងនឹងក្រុមហ៊ុនដែលបានបិទប្រឡាយទឹក ដែលជាប្រភពចាំបាច់ សំរាប់ការស្រោចស្រប់ដីស្រែរបស់ខ្លួន ។ គេជឿថាសកម្មជនសហគមន៍ម្នាក់ទៀត ដែលមានឈ្មោះនៅក្នុងពាក្យបណ្តឹង នោះដែរ គឺដោយសារតែភាពសកម្មរបស់គាត់ប្រឆាំងការកាប់ឈើខុសច្បាប់ក្នុងឃុំនោះ ។ ទោះបីជាមានកិច្ចខិតខំ ប្រឹងប្រែង ដើម្បីអោយមានការលើកលែងការចោទប្រកាន់ ក៏បទចោទនេះទុកនៅដដែល ដោយទោះបីជាមិនមាន ការបន្តនីតិវិធីក្តីតទៅទៀតក៏ដោយ ។

នៅក្នុងខែធ្នូ ឆ្នាំ២០០៤ វ៉ែន ហ៊ុល ជាកសិករម្នាក់ដែលសកម្មក្នុងការតវ៉ាប្រឆាំងក្រុមហ៊ុនភាពីម៉ិច ត្រូវបានចាប់ខ្លួន បន្ទាប់ពីតំណាងក្រុមហ៊ុនបានដាក់ពាក្យបណ្តឹង ។ គាត់ត្រូវបានចោទប្រកាន់ពីបទប៉ុនប៉ងធ្វើឃាតតំណាងក្រុមហ៊ុន បន្ទាប់ពីព្រឹត្តិការណ៍ខែវិច្ឆិកា ឆ្នាំ២០០៤ ដែលក្នុងពេលនោះ គាត់បានចោទប្រកាន់ក្រុមហ៊ុនថា "ធ្វើអោយប្រទេសកម្ពុជាទៅជាប្រទេសខ្មោច" ហើយបានប្រាប់អ្នកបច្ចេកទេសក្រុមហ៊ុនឱ្យចាកចេញពីទីនោះ ។ការស្នើសុំអោយ វ៉ែន ហ៊ុល នៅក្រៅឃុំត្រូវបានបដិសេធ ហើយគាត់ត្រូវបានជាប់ឃុំឃាំងនៅក្នុងអំឡុងពេលនៃការស៊ើបអង្កេតលើពាក្យបណ្តឹង ។ ក្រោយពីឃុំខ្លួនរយៈពេលប្រាំមួយខែមក តុលាការបានលើកលែងចោទប្រកាន់នៅក្នុងសវនាការសាធារណៈមួយ នៅថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០០៥ ។ ទន្ទឹមគ្នានេះដែរ មិនមានការរីកចំរើន ក្នុងការស៊ើបអង្កេតលើការវាយប្រហារដោយគ្រាប់ដៃ ដែលបានបណ្តាលឱ្យបាតុករប្រាំបីនាក់រងរបួស ក្នុងឃុំអន្សាចំបក់ ខេត្តពោធិសាត់ កាលពីថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០០៤ទេ ហើយមិនមាននរណាម្នាក់ត្រូវបាននាំខ្លួនទៅកាត់ទោសតាមច្បាប់នៅឡើយ ។

រដ្ឋាភិបាលមិនមានវិធានការជាក់ស្តែងណាមួយ ដើម្បីជំរុញឱ្យក្រុមហ៊ុនគោរពច្បាប់ភូមិបាល និងកិច្ចសន្យាសម្បទានឡើយ ។ ឧទាហរណ៍ ក្រសួងបរិស្ថានបានរកឃើញថា ក្រុមហ៊ុន ហ្គ្រីន រិច បានរំលោភលើលក្ខខណ្ឌនៃកិច្ចសន្យារបស់ខ្លួន ដោយការកាប់ឈើនៅខាងក្រៅតំបន់ដីសម្បទាន ហើយបំផ្លាញផ្នែកមួយនៃឧទ្យានជាតិបុទុមសាគរ ក្នុងខេត្តកោះកុង ។ ក្រសួងបរិស្ថានបានដាក់ពាក្យបណ្តឹងមួយប្រឆាំងនឹងក្រុមហ៊ុននេះ នៅដើមឆ្នាំ២០០៥ ប៉ុន្តែបណ្តឹងនេះត្រូវបានតុលាការខេត្តតំកល់ទុកមិនចាត់ការ ក្នុងខែវិច្ឆិកា ឆ្នាំ២០០៥ បន្ទាប់ពីសវនាការមួយ ដែលក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងក្រសួងកសិកម្មបានឆ្លើយបំភ្លឺការពារឱ្យក្រុមហ៊ុន ហ្គ្រីន រិច ។ ក្រសួងបរិស្ថានបានប្តឹងឧទ្ធរណ៍ ប៉ុន្តែបានដកបណ្តឹងឧទ្ធរណ៍របស់ខ្លួនវិញ ក្នុងខែវិច្ឆិកា ឆ្នាំ២០០៦ ដោយមិនដឹងមូលហេតុ ។

## ៨. តើអ្នកណាទទួលផលពីសម្បទានដីសេដ្ឋកិច្ច?

### *៨.១. អ្នកទទួលផលពីសម្បទានដីសេដ្ឋកិច្ច*

សម្បទានដីសេដ្ឋកិច្ចសរុបចំនួន ៣៦ ត្រូវបានផ្តល់ទៅឱ្យជនបរទេស ឬឥស្សរជនល្បីឈ្មោះខាងជំនួញ និងខាងនយោបាយ ដែលស្មើនឹង ៦១ ភាគរយ នៃសម្បទានដីសេដ្ឋកិច្ចទាំងអស់ដែលបានផ្តល់ ។ ចំនួននេះមិនរាប់បញ្ចូលនូវម្ចាស់កម្មសិទ្ធនៃដីសម្បទានសេដ្ឋកិច្ចដែលមានទំហំមិនលើសពី ១.០០០ ហិកតា ដោយសារ ព័ត៌មានស្តីពីសម្បទានទាំងនេះ និងកម្មសិទ្ធិរបស់វាមិនត្រូវបានគេបង្ហើបឱ្យដឹង ។

ការវិភាគលើព័ត៌មានដែលផ្តល់ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បង្ហាញថា សម្បទានដីសេដ្ឋកិច្ចចំនួន២៥ មានម្ចាស់ជាជនបរទេស ស្មើនឹងជាង៤២ ភាគរយនៃសម្បទានដីសេដ្ឋកិច្ចទាំងអស់ដែលបានផ្តល់ ។ ក្នុងចំនួននេះ មានដីសម្បទានចំនួន១២ មានម្ចាស់ជាជនជាតិចិន ៣ ជាជនជាតិថៃ ៣ ជាជនជាតិវៀតណាម ៣ ជាជន

ជាតិអាមេរិកាំង ៣ ជាជនជាតិកូរ៉េ ហើយ១ ទៀត ជាជនជាតិតៃវ៉ាន់ ។ ក្រៅពីនេះ នៅពេលថ្មីៗនេះ មានសេចក្តីរាយការណ៍ថា ក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ បានយល់ព្រមជួលដី ១០០.០០០ ហិកតា ឱ្យក្រុមហ៊ុនវៀតណាម ចំនួន ១០ ដើម្បីដាំដំណាំកៅស៊ូ ។ មកទល់ពេលនេះមានដីចំនួន ១០.០០០ ហិកតា ត្រូវបានកំណត់ ។[៣៣]

ការវិភាគលើព័ត៌មានដដែល ក៏បានបង្ហាញឱ្យឃើញថា ឥស្សរជនល្បីឈ្មោះខាងជំនួញ និងខាងនយោបាយរបស់កម្ពុជា រួមទាំងសមាជិកព្រឹទ្ធសភា និង ឧកញ៉ា ជាម្ចាស់ ឬមានភាគហ៊ុនក្នុងសម្បទានដីសេដ្ឋកិច្ច យ៉ាងហោចណាស់ក៏ចំនួន១១ ដែរ ។ ចំណែកឯសម្បទានដទៃទៀត ក៏អាចមានជាប់ទាក់ទងជាមួយឥស្សរជនទាំងនេះផងដែរ តែការនេះមិនអាចបញ្ជាក់បាន ដោយសារមិនអាចរកបានបញ្ជីម្ចាស់ភាគហ៊ុននៃក្រុមហ៊ុនដីសម្បទាន និងព័ត៌មានលំអិតថែមទៀត អំពីអ្នកទទួលផលប្រយោជន៍ពីសម្បទានទាំងនេះ ។

## *៨.២. ការបំពេញតាមគោលដៅនៃសម្បទានដីសេដ្ឋកិច្ច*

សម្បទានដីសេដ្ឋកិច្ច ត្រូវបានជាគោលដៅនៃផ្នែកមួយនៃក្របខ័ណ្ឌការកាត់បន្ថយភាពក្រីក្រ និងការអភិវឌ្ឍន៍ជនបទ ដូចមានចែងក្នុងផែនការអភិវឌ្ឍន៍យុទ្ធសាស្រ្តជាតិឆ្នាំ២០០៦-២០១០ ។ ជាពិសេស វាមានគោលដៅដើម្បីអភិវឌ្ឍន៍ដីធ្លី តាមលក្ខណៈសមស្រប និងចិរភាព ដោយផ្អែកលើប្រព័ន្ធបរិស្ថានសមស្រប បង្កើនការងារនៅតំបន់ជនបទ និងបង្កើតចំណូលជាតិ ។ ទោះជាយ៉ាងណាក៏ដោយ ដូចដែលរបាយការណ៍នេះ និងរបាយការណ៍ដទៃទៀត បានបង្ហាញ សម្បទានដីសេដ្ឋកិច្ចមិនបំពេញបានតាមគោលដៅទាំងនេះទេ ។ ការវាយតំលៃពីភាពក្រីក្រ ដោយធនាគារពិភពលោកឆ្នាំ២០០៦ បានផ្តល់អនុសាសន៍ឱ្យមានការកាន់កាប់ធ្វើអាជីវកម្មលើដីជាទ្រង់ទ្រាយតូចៗ ដើម្បីបង្កើនផលិតផលកសិកម្ម និងកាត់បន្ថយភាពក្រីក្រ ជាជាងការកាន់កាប់ដីក្នុងទ្រង់ទ្រាយធំតាមបែបចំការកសិ-ឧស្សាហកម្ម ។

សម្បទានិកមិនបានគ្រប់គ្រងដីធ្លីតាមលក្ខណៈសមស្រប និងចិរភាព តាមប្រព័ន្ធបរិស្ថានដែលមានស្រាប់ ហើយមិនផ្តល់ប្រយោជន៍ជាក់ស្តែងដល់សហគមន៍មូលដ្ឋានទេ ។ជាទូទៅ សម្បទានមិនបានផ្តល់ការងារដល់សហគមន៍ជនបទដែលរងផលប៉ះពាល់ទេ ។ ប្រសិនបើមានការងារ ក្នុងករណីភាគច្រើនក្រុមហ៊ុនតែងតែនាំយកកម្មករមកពីខេត្តផ្សេងៗ ។ ប្រសិនបើគេជួលអ្នកស្រុកឱ្យធ្វើការនោះ នោះក៏រិតប្រាក់ឈ្នួលគឺទាប ធៀបទៅនឹងកំរៃដែលពួកគេបានទទួលពីផលិតផលកសិកម្មនិងពីអនុផលព្រៃឈើ ។ ម្យ៉ាងវិញទៀត វាមិនច្បាស់លាស់ថាតើសម្បទាន

[៣៣] កាសែតឌឹខាំបូឌាដេលី : *រដ្ឋាភិបាលយល់ព្រម " ជាគោលការណ៍ " ជួលដីឱ្យវៀតណាម* ថ្ងៃទី២៥ ខែមេសា ឆ្នាំ២០០៧ ។

ដីសេដ្ឋកិច្ចរួមចំណែកអ្វីខ្លះដល់ចំណូលជាតិនៅកម្ពុជា ហើយរដ្ឋាភិបាលគួរតែបញ្ចេញឱ្យដឹងអំពីចំណូលដែលបានមកពីសម្បទានទាំងនេះ ។[៣៤]

ជំនួសឱ្យការជំរុញការអភិវឌ្ឍន៍ និងការកាត់បន្ថយភាពក្រីក្រ សម្បទានដីសេដ្ឋកិច្ចបានធ្វើឱ្យប៉ះពាល់ដល់សិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ របស់សហគមន៍ជនបទក្នុងប្រទេសកម្ពុជា ។ ប្រទេសកម្ពុជាមិនទាន់បានបញ្ជូនរបាយការណ៍ដំបូងរបស់ខ្លួន ក្រោមកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដែលបានដល់ពេលកំណត់ក្នុងឆ្នាំ១៩៩៤ នៅឡើយទេ ។ ចំពោះស្ថានភាពបច្ចុប្បន្ននេះ គឺជាការចាំបាច់ណាស់ ដែលកម្ពុជាត្រូវបំពេញកាតព្វកិច្ចធ្វើរបាយការណ៍របស់ខ្លួន ក្រោមកតិកាសញ្ញានេះ ដែលជាជំហានជាក់ស្តែងមួយឆ្ពោះទៅការអនុវត្តន៍ប្រកបដោយប្រសិទ្ធិភាពនូវសិទ្ធិទាំងឡាយ ដែលមានចែងក្នុងកតិកាសញ្ញានេះ ។ សេចក្តីផ្តល់មតិទូទៅរបស់គណៈកម្មាធិការសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ បានទទួលស្គាល់ថា សិទ្ធិមានលំនៅដ្ឋានសមរម្យ រួមមានទាំងរបៀបរបបនៃការកាន់កាប់ដីតាមផ្លូវច្បាប់ដ៏គត់មត់ ហើយថាសន្តិសុខស្បៀងដែលមានចិរភាព សំរាប់មនុស្សនាជំនាន់បច្ចុប្បន្ន និងជំនាន់ក្រោយ គឺជាចំណុចស្នូលនៃសិទ្ធិខាងស្បៀងអាហារ ។[៣៥]

*៨.៣. គំនិតផ្តួចផ្តើមអភិវឌ្ឍន៍ដោយសហគមន៍ និងសេចក្តីត្រូវការរបស់សហគមន៍*

នៅក្នុងករណីជាច្រើន ការផ្តួចផ្តើមគំនិតក្នុងការអភិវឌ្ឍន៍សហគមន៍មូលដ្ឋាន ដើម្បីគ្រប់គ្រងដីធ្លី និងធនធានធម្មជាតិប្រកបដោយចិរភាព ត្រូវបានរាំងស្ទះដោយសារតែការផ្តល់សម្បទានដីសេដ្ឋកិច្ច និងសម្បទានដទៃទៀត ដោយមិនគិតគូរអើពើអំពីគោលដៅនៃផែនការអភិវឌ្ឍន៍យុទ្ធសាស្ត្រជាតិ ស្តីពីការលើកកំពស់ជីវភាពរស់នៅ និងការកាត់បន្ថយភាពក្រីក្រនៅតំបន់ជនបទ ។ ការផ្តល់អាទិភាពដល់ការវិនិយោគទ្រង់ទ្រាយធំ ពីលើគំនិតផ្តួចផ្តើមនៅសហគមន៍មូលដ្ឋាន ក៏មានលក្ខណៈផ្ទុយទៅនឹងអនុសាសន៍ស្តីពីការកាត់បន្ថយភាពក្រីក្រនៅជនបទ ដែលបានធ្វើឡើងដោយការសិក្សារបស់ធនាគារពិភពលោក ស្តីពីវចនាសម្ព័ន្ធកសិកម្មកម្ពុជា ឆ្នាំ២០០៥ និងការវាយតំលៃពីភាពក្រីក្រឆ្នាំ២០០៦ នៅកម្ពុជា ។

---

[៣៤] នៅក្នុងសម័យប្រជុំក្រុមការងារបច្ចេកទេសស្តីពីដីធ្លី ក្នុងខែមីនា ឆ្នាំ២០០៧ លោក ឆាន់ សាផាន រដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ បានគត់សំគាល់ថា មានតែសម្បទានមួយគត់ដែលអនុវត្តបានជោគជ័យ គឺក្រុមហ៊ុនចំការដូងប្រេងម៉ុងឫទ្ធី នៅក្រុងព្រះសីហនុ ។

[៣៥] សេចក្តីផ្តល់មតិទូទៅ លេខ ៤ របស់គណៈកម្មាធិការសេដ្ឋកិច្ច សង្គមកិច្ច និង វប្បធម៌ : សិទ្ធិមានលំនៅដ្ឋានសមរម្យ ថ្ងៃទី១៣ ខែធ្នូ ឆ្នាំ១៩៩១ និង សេចក្តីផ្តល់មតិទូទៅ លេខ ១២ របស់គណៈកម្មាធិការសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ : សិទ្ធិមានស្បៀងអាហារគ្រប់គ្រាន់ ថ្ងៃទី១២ ខែឧសភា ឆ្នាំ១៩៩៩ ។ សូមមើលកម្រងប្រចាំឆ្នាំ HRI/GEN/1/Rev.8.

នៅស្រុកស្រែអំបិល ខេត្តកោះកុង គណៈកម្មាធិការសេវាកម្មមិត្តអាមេរិកាំង (AFSC) បានអនុវត្តគំរោងផែនការប្រើប្រាស់ដីធ្លីដោយមានការចូលរួម ក្នុងឃុំជីខលើ ដោយធ្វើការជាមួយសហគមន៍ និងអាជ្ញាធរមូលដ្ឋាន ដើម្បីកំណត់អំពីផ្ទៃដីដែលមានការប្រើប្រាស់នៅក្នុងតំបន់នោះ ។ ការកំណត់ពីផ្ទៃដី ដោយផែនការប្រើប្រាស់ដីធ្លីដែលមានការចូលរួមនេះ បានបញ្ចប់នៅឆ្នាំ២០០៦ ប៉ុន្តែក្រុមហ៊ុន កោះកុង ស៊ូហ្គើរ អ៊ិនដាសស្ទ្រី និង សម្បទានក្រុមហ៊ុន កោះកុង ផ្លេនថេសិន បានចាប់ផ្តើមសកម្មភាពការងារនៅលើដីសម្បទាន នៅមុនពេលដែលកិច្ចដំណើរការរបស់ផែនការនេះត្រូវបានបញ្ចប់ ។ មិនមានការពិគ្រោះយោបល់ ឬជូនដំណឹងទៅសហគមន៍ អាជ្ញាធរ-មូលដ្ឋាន ឬ អង្គការក្រៅរដ្ឋាភិបាលដែលធ្វើការលើគំរោងនេះទេ អំពីការផ្តល់សម្បទានទាំងនេះ ។

នៅស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ ជនជាតិដើមភាគតិចសួយ កំពុងធ្វើគំរោងទេសចរណ៍សេដ្ឋកិច្ចនៅសហគមន៍ ដើម្បីគ្រប់គ្រងតំបន់តេទឹកពុះ និងបង្កើតចំណូលសហគមន៍ ដោយមានការគាំទ្រពីអង្គការ Lutheran World Federation និង អង្គការ Fauna and Flora International និងក្នុងកិច្ចសហប្រតិបត្តិការជាមួយក្រសួងបរិស្ថាន និងក្រសួងទេសចរណ៍ ។ ក្នុងខែតុលា ឆ្នាំ២០០៤ សហគមន៍ត្រូវបានប្រាប់ឱ្យបញ្ឈប់ការងារនៃគំរោងរបស់ខ្លួន បន្ទាប់ពីតំបន់នេះត្រូវផ្តល់សម្បទានសំរាប់ទេសចរណ៍សេដ្ឋកិច្ចអោយ ក្រុមហ៊ុន ញ៉ូកូស្ទស ។ ស្រដៀងគ្នានេះដែរ សហគមន៍ជនជនជាតិដើមភាគតិចភ្នង នៅជិតទឹកធ្លាក់ ប៊ូស្រា ក្នុងខេត្តមណ្ឌលគីរី បាននិងកំពុងធ្វើការជាមួយអាជ្ញាធរមូលដ្ឋាន ដោយមានការគាំទ្រពីអង្គការដានីដា ដើម្បីគ្រប់គ្រងតំបន់ទឹកធ្លាក់នេះ និងដើម្បីបង្កើតជាកន្លែងទេសចរណ៍ទ្រង់ទ្រាយតូចមួយ ។ ទោះជាមានគំនិតផ្តួចផ្តើមនេះក៏ដោយ ក៏ផែនការដើម្បីផ្តល់សម្បទានទេសចរណ៍សេដ្ឋកិច្ច អោយដល់ការអភិវឌ្ឍន៍ជាទ្រង់ទ្រាយធំ កំពុងតែបន្តធ្វើ ។

សម្បទានដីសេដ្ឋកិច្ចក៏បានធ្វើឱ្យប៉ះពាល់ដល់គំនិតផ្តួចផ្តើមរបស់សហគមន៍ ក្នុងការបង្កើតព្រៃសហគមន៍ ស្របតាមច្បាប់ភូមិបាល ។ ចាប់ពីឆ្នាំ២០០៥ អង្គការអភិវឌ្ឍន៍សេដ្ឋកិច្ចសហគមន៍ (CED) បានធ្វើការជាមួយសហគមន៍មូលដ្ឋានក្នុងខេត្តក្រចេះ រួមមានជនជាតិដើមភាគតិចភ្នង និងមិល ដើម្បីបង្កើតព្រៃសហគមន៍មួយនៅឃុំក្បាលដំរី ក្នុងស្រុកសំបូរ ។ អាជ្ញាធរមូលដ្ឋាន និងមន្ត្រីព្រៃឈើបានដឹងអំពីគំនិតផ្តួចផ្តើមនេះ ។ ទោះជាយ៉ាងណាក៏ដោយ ក្នុងឆ្នាំ ២០០៦ សម្បទានដីសេដ្ឋកិច្ចចំនួន៣ ត្រូវបានផ្តល់នៅលើដីដែលគ្រោងបង្កើតជាព្រៃសហគមន៍ ។ ក្នុងខេត្តឧត្តរមានជ័យក្រុមហ៊ុន មៀង លីហេង ត្រូវបានផ្តល់សម្បទានដីទំហំ ១.០០០ ហិកតា សំរាប់ដំណាំដំឡូងមី នៅលើដីដែលប្រជាពលរដ្ឋមូលដ្ឋានបានបង្កើតសហគមន៍ព្រៃឈើ ហើយដែលសហគមន៍នេះ កំពុងតែស្ថិតនៅក្នុងដំណើរការរកការទទួលស្គាល់តាមផ្លូវច្បាប់ ស្របតាមច្បាប់ស្តីពីព្រៃឈើ ។

ទាំងនេះគឺជាឧទាហរណ៍បង្ហាញពី ការបង្កើតយុទ្ធសាស្ត្រគ្រប់គ្រងដីធ្លី និងការចិញ្ចឹមជីវិត ដោយសហគមន៍មូលដ្ឋានខ្លួនឯង ដើម្បីផ្តល់ប្រយោជន៍ដល់សហគមន៍របស់ពួកគេ ដោយពួកគេបានធ្វើការជាមួយអាជ្ញាធរមូលដ្ឋាន អង្គការក្រៅរដ្ឋាភិបាល និងទីភ្នាក់ងារសហប្រតិបត្តិការអភិវឌ្ឍន៍នានា ។ កិច្ចដំណើរការនៃការផ្តល់សម្បទាន មិនត្រឹម

តែមិនគិតគូរដល់គំនិតផ្តួចផ្តើមទាំងនេះប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបានផ្តល់សិទ្ធិកម្មសិទ្ធិដាច់មុខឱ្យទៅសហគ្រាសឯកជនទៀតផង ។ បច្ចុប្បន្ននេះ សហគមន៍ជាច្រើន មិនមានដីធ្លី និងធនធានធម្មជាតិគ្រប់គ្រាន់សំរាប់ការអភិវឌ្ឍន៍ នៅថ្ងៃអនាគត ហើយមិនមានលទ្ធភាពក្នុងការអនុវត្តន៍ផែនការអភិវឌ្ឍន៍ប្រកបដោយចិរភាព សំរាប់សហគមន៍ខ្លួនបានឡើយ ។

## ៩. សេចក្តីសន្និដ្ឋាន

ប្រទេសកម្ពុជាសំរេចបាននូវការលូតលាស់ផ្នែកសេដ្ឋកិច្ចយ៉ាងឆាប់រហ័ស និងការកាត់បន្ថយជារួមនូវភាពក្រីក្រ ក្នុងទសវត្សកន្លងមក ប៉ុន្តែផលប្រយោជន៍ដែលទទួលបានពីការលូតលាស់នេះ មិនបានបែងចែកប្រកបដោយសមធម៌ ក្នុងចំណោមប្រជាពលរដ្ឋរបស់ខ្លួនទេ ។ភាពខុសគ្នាកាន់តែកើនឡើង នៃចំណូល និងការទទួលបានឱកាសជាពិសេសក្នុងតំបន់ជនបទ ។ សហគមន៍នៅជនបទ ពឹងផ្អែកយ៉ាងខ្លាំងលើ ដី និងធនធានព្រៃឈើ ហើយភាពគ្មានដីធ្លីត្រូវបានកត់សំគាល់ថា ជាមូលហេតុចំបងនៃភាពក្រីក្រដ៏រាលដាល នៅក្នុងតំបន់ជនបទកម្ពុជា ។[៣៦] សម្បទានដីសេដ្ឋកិច្ចត្រូវបានផ្តល់ជាបន្ត កាន់តែកើនចំនួនច្រើនឡើង ដែលការនេះកាន់តែធ្វើឱ្យមានកំហិតលើសិទ្ធិលើដីធ្លី និងធនធានធម្មជាតិរបស់សហគមន៍ ។

សម្បទានដីសេដ្ឋកិច្ច មិនបាននាំទៅដល់ការបង្កើន ផលិតភាពកសិកម្ម ឬការរីកលូតលាស់ផ្នែកសេដ្ឋកិច្ចនៅកម្ពុជាទេ ហើយដីភាគច្រើនក្នុងតំបន់សម្បទានដែលបានផ្តល់អោយក្រុមហ៊ុន ត្រូវបានទុកចោលដោយឥតប្រយោជន៍ ឬមិនបានប្រើប្រាស់ទេ ។[៣៧] ដូចដែលរបាយការណ៍វាយតំលៃភាពក្រីក្ររបស់ធនាគារពិភពលោក បានផ្តល់អនុសាសន៍ សុវត្ថិភាពនៃបណ្ណកម្មសិទ្ធិដីធ្លី និង កសិកម្មជាលក្ខណៈគ្រួសារ ឬជាទ្រង់ទ្រាយតូចៗ និងលើកកំពស់ដល់លទ្ធផលអភិវឌ្ឍន៍ សំរាប់សហគមន៍នៅជនបទ ។ គំនិតផ្តួចផ្តើមដោយសហគមន៍ខ្លួនឯង ដើម្បីគ្រប់គ្រងដីធ្លី និងធនធានធម្មជាតិ គួរតែត្រូវបានផ្តល់អាទិភាពផងដែរ ។

របាយការណ៍នេះបានធ្វើសេចក្តីសន្និដ្ឋានថា សម្បទានដីសេដ្ឋកិច្ច មិនបានបង្ហាញឱ្យឃើញថាជាមធ្យោបាយមានប្រសិទ្ធិភាពក្នុងការជំរុញការអភិវឌ្ឍន៍ ដែលផ្តល់ប្រយោជន៍ឱ្យប្រជាជនកម្ពុជាភាគច្រើនឡើយ ។ ផ្ទុយទៅវិញ វាធ្វើឱ្យប៉ះពាល់ដល់ការចិញ្ចឹមជីវិតរបស់ប្រជាជននៅជនបទ ដើម្បីផ្តល់ភាពមានបានឱ្យមនុស្សមួយចំនួនតូច ព្រមទាំងពាណិជ្ជករបទេសនានាប៉ុណ្ណោះ ។

---

[៣៦] សូមមើលរបាយការណ៍សិក្សា ស្តីពី ដី និងការអភិវឌ្ឍន៍មនុស្សនៅកម្ពុជា របស់សាលាស្តុកខម នៃសេដ្ឋកិច្ច (Stockholm School of Economics) និងឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ ខែកុម្ភៈ ឆ្នាំ២០០៧ ។

[៣៧] សូមមើល ដី និងការអភិវឌ្ឍន៍មនុស្ស នៅកម្ពុជា ដូចដែលបានពោលនៅចំនុចយោងខាងលើ និងមើល របាយការណ៍វាយតំលៃភាពក្រីក្រ ឆ្នាំ២០០៦ របស់ធនាគារពិភពលោក ។

ការទទួលបានការដោះស្រាយប្រកបដោយប្រសិទ្ធិភាព សំរាប់សហគមន៍ដែលរងផលប៉ះពាល់ នៅតែចោទជាបញ្ហា ហើយកង្វល់របស់សហគមន៍ទាំងនេះ នៅមិនទាន់បានទទួលការឆ្លើយតបដ៏ទូលំទូលាយពីរដ្ឋាភិបាលទេ ។ អជ្ញាធរពាក់ព័ន្ធ និងតុលាការមិនបំពេញកាតព្វកិច្ចរបស់ខ្លួន ដើម្បីលើកស្ទួយ និងការពារសិទ្ធិ កម្មសិទ្ធិដីធ្លី និងប្រើប្រាស់ធនធានព្រៃឈើ របស់សហគមន៍ជនបទទេ ។ ពួកគេក៏ខកខានក្នុងការគោរពតាម និងប្រតិបត្តិ ច្បាប់ភូមិបាល និងច្បាប់ស្តីពីព្រៃឈើ និងអនុក្រឹត្យដែលពាក់ព័ន្ធ ។ការណ៍នេះមិនបានឆ្លុះបញ្ចាំងជាវិជ្ជមានពីការ ទទួលខុសត្រូវរបស់ស្ថាប័នរដ្ឋ និងការទទួលបាននូវការដោះស្រាយប្រកបដោយប្រសិទ្ធិភាព ។

ដី និងធនធានធម្មជាតិនៅកម្ពុជា ត្រូវតែបានគ្រប់គ្រង សំរាប់ជាប្រយោជន៍ដល់ប្រជាជនកម្ពុជាគ្រប់រូប ស្របតាមច្បាប់ និងការប្តេជ្ញាចិត្តរបស់កម្ពុជា ក្រោមសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិនានា ។ តម្រូវឱ្យមានការការពារជាពិសេសចំពោះដីធ្លី និងរបៀបរបបរស់នៅជាប្រពៃណីរបស់ជនជាតិដើមភាគតិច ។ ការការពារ និងការបំពេញបានការគោរពសិទ្ធិមនុស្ស រួមមានសិទ្ធិទាំងឡាយដែលមានចែងក្នុងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដែលសិទ្ធិទាំងនេះ ជាស្នូលនៃការអភិវឌ្ឍន៍ និងការកាត់បន្ថយភាពក្រីក្រ ។ ការអភិវឌ្ឍន៍ គឺជាកិច្ចដំណើរការមួយដែលគិតគូរប្រជាពលរដ្ឋជាសំខាន់ដោយត្រូវគិតទាំងសេដ្ឋកិច្ចផង និងសុខមាលភាពសង្គម និងវប្បធម៌ផង ។ ការអភិវឌ្ឍន៍ត្រូវតែផ្តល់ផលប្រយោជន៍ ដល់ប្រជាពលរដ្ឋទាំងមូល ហើយប្រជាពលរដ្ឋត្រូវតែបានចូលរួមក្នុងការធ្វើសេចក្តីសំរេចចិត្តអំពីដីធ្លី និងជីវភាពរស់នៅរបស់ខ្លួន ។ការចូលរួមដោយសហគមន៍ដែលរងផលប៉ះពាល់ នឹងជួយក្នុងការចែករំលែកផលប្រយោជន៍ ពីដីធ្លី និងធនធានធម្មជាតិរបស់ប្រទេសកម្ពុជា និងជួយកាត់បន្ថយ ផលប៉ះពាល់ជាអវិជ្ជមាននៃសម្បទានដីសេដ្ឋកិច្ច ។

កិច្ចការដែលនៅចំពោះមុខប្រទេសកម្ពុជា ដោយត្រូវធ្វើការជាមួយដៃគូរអភិវឌ្ឍន៍របស់ខ្លួន គឺ បង្កើត និងអនុវត្តគោលនយោបាយ និងការអនុវត្តន៍ដែលជំរុញឱ្យមានការចែករំលែកដោយស្មើភាពគ្នាពីកំនើន សេដ្ឋកិច្ចក្នុងប្រទេសកម្ពុជា និងការគ្រប់គ្រងធនធានរួម សំរាប់ជាប្រយោជន៍របស់ប្រជាជនកម្ពុជាគ្រប់រូប ។ សហគមន៍អន្តរជាតិ ត្រូវតែធ្វើនូវអ្វីៗទាំងអស់ដែលខ្លួនអាចធ្វើបានក្នុងចំនែករបស់ខ្លួន ដើម្បីធានាថា ការអភិវឌ្ឍន៍ពិតជាបានគិតគូរដល់ប្រជាពលរដ្ឋ ហើយគោរព និងការពារសិទ្ធិប្រជាពលរដ្ឋកម្ពុជាទាំងអស់ ។

## ១០. អនុសាសន៍

ខាងក្រោមនេះគឺជាអនុសាសន៍ដែលបានស្នើឡើង ដើម្បីដោះស្រាយផលប៉ះពាល់អវិជ្ជមាននៃសម្បទានដីសេដ្ឋកិច្ច និងដើម្បីការគោរព និងលើកស្ទួយសិទ្ធិរបស់ប្រជាពលរដ្ឋកម្ពុជា ការលើកកំពស់ការប្រើប្រាស់ប្រកបដោយសមធម៌ និងចិរភាពនូវដីធ្លី និងធនធានធម្មជាតិរបស់កម្ពុជា។ លោកតំណាងពិសេស ចូលរួមជាមួយទស្សនៈរបស់លោកតំណាងពិសេសមុន ដែលលើកឡើងថា ប្រព័ន្ធសម្បទានគួរតែពិនិត្យឡើងវិញ ហើយថាគួរតែធ្វើការពិចារណាលើជំរើសនៃគំរូកសិកម្មផ្សេងវិញ។

<u>ការអនុវត្តន៍ក្របខ័ណ្ឌច្បាប់</u>

- ធានាថា រាល់សម្បទានដីសេដ្ឋកិច្ចថ្មីទាំងអស់ រួមទាំងសម្បទានដីទាំងឡាយដែលមានទំហំមិន លើសពី ១.០០០ ហិកតា ផងដែរ ត្រូវគោរពយ៉ាងពេញលេញនូវបទបញ្ញត្តិនៃច្បាប់ភូមិបាល និង អនុក្រឹត្យស្តីពីសម្បទានដីសេដ្ឋកិច្ច។ ជាពិសេស ធានាឱ្យមានការពិគ្រោះយោបល់ជាសាធារណៈ និងការវាយតំលៃពិតប្រាកដពីហេតុប៉ះពាល់បរិស្ថាន និងសង្គម មុននឹងផ្តល់សម្បទានណាមួយ ហើយត្រូវមានការចូលរួមប្រកបដោយប្រសិទ្ធិភាពពីប្រជាពលរដ្ឋមូលដ្ឋាន។

- ត្រួតពិនិត្យឡើងវិញរាល់សម្បទានដីសេដ្ឋកិច្ចដែលមានស្រាប់ ដើម្បីឱ្យស្របតាមច្បាប់ភូមិបាល និងអនុក្រឹត្យស្តីពីសម្បទានដីសេដ្ឋកិច្ច និងកិច្ចសន្យាសម្បទាន និងធានាមិនឱ្យមានការទន្ទ្រានលើដី ដែលជាកម្មសិទ្ធិ និងដែលសហគមន៍ប្រើប្រាស់ រួមទាំងដីព្រៃផងដែរ។

- លុបចោលសម្បទានដីសេដ្ឋកិច្ចទាំងឡាយណា ដែលមិនគោរពតាមបញ្ញត្តិច្បាប់ភូមិបាល និង អនុក្រឹត្យស្តីពីសម្បទានដីសេដ្ឋកិច្ច និងកាត់បន្ថយសម្បទានទាំងឡាយណាដែលមាន ទំហំលើសពី ១០.០០០ ហិកតា។

- ធានាការគោរពច្បាប់ស្តីពីព្រៃឈើ និងបទបញ្ជាស្តីពីព្រៃឈើ។ ជាពិសេសធានាថា សម្បទានដី សេដ្ឋកិច្ចមិនត្រូវបានផ្តល់នៅលើដីព្រៃ ឬអតីតតំបន់ព្រៃសម្បទាន ហើយការពារ សិទ្ធិប្រើប្រាស់ ព្រៃឈើ និងដីជាប្រពៃណីរបស់សហគមន៍។

**<u>សិទ្ធិលើដីធ្លីរបស់ជនជាតិដើមភាគតិច</u>**

- ប្រកាស និងអនុវត្តការផ្អាកជាបណ្តោះអាសន្ន ការលក់ និងការចុះបញ្ជីដី និងការផ្តល់សម្បទានដី សេដ្ឋកិច្ច និងសម្បទានដទៃទៀត នៅក្នុងតំបន់ដែលមានជនជាតិភាគតិចកាន់កាប់។

- ជួយសហគមន៍ជនជាតិដើមភាគតិច ក្នុងការកំណត់ព្រំប្រទល់ដីប្រៃព្រៃណីរបស់ខ្លួន សំរាប់ការចុះបញ្ជី និងផ្តល់ការទទួលស្គាល់ជាបឋមចំពោះដីធ្លីនេះ ក្នុងខណៈពេលរង់ចាំការចុះបញ្ជីសហគមន៍ ជនជាតិដើមភាគតិចជានិតិបុគ្គល និងការចុះបញ្ជីដីកម្មសិទ្ធិសមូហភាព ។

- គាំទ្រសហគមន៍ជនជាតិដើមភាគតិច ដើម្បីធ្វើតាមវិធានការតម្រូវផ្សេងទៀត ដើម្បីចុះបញ្ជី កម្មសិទ្ធិសមូហភាព រួមទាំងការចុះបញ្ជីសហគមន៍ជនជាតិដើមភាគតិចជានិតិបុគ្គល ។

## សិទ្ធិទទួលព័ត៌មាន

- ផ្សព្វផ្សាយព័ត៌មានស្តីពីសម្បទានដីសេដ្ឋកិច្ចទាំងអស់ ដែលបានផ្តល់ និងសំណើរដែលកំពុងស្ថិតក្នុង ការពិចារណា រួមទាំងសម្បទានដែលមិនលើសពី១.០០០ ហិកតា ។ ព័ត៌មាននោះគួរបញ្ចូលនូវ ទីតាំង ទំហំ ការប្រើប្រាស់ និង ស្ថានភាពនៃសម្បទាន និងការគោរពតាមលក្ខខ័ណ្ឌតម្រូវ ដែលមាន ចែងក្នុងអនុក្រឹត្យស្តីពីសម្បទានដីសេដ្ឋកិច្ច ។ ព័ត៌មានទាំងនេះ ក៏ត្រូវដាក់ផ្សព្វផ្សាយ នៅថ្នាក់ មូលដ្ឋាន អោយសាធារណជនបានដឹងផងដែរ ។

- បញ្ចេញឱ្យដឹងព័ត៌មានអំពីសម្បទានិក រួមទាំងនាយកក្រុមហ៊ុន ម្ចាស់ភាគហ៊ុន និងអ្នកទទួលផលប្រយោជន៍ ពីសម្បទាន ។

## សិទ្ធិទទួលបានការដោះស្រាយប្រកបដោយប្រសិទ្ធិភាព

- អនុវត្តច្បាប់ភូមិបាល និងអនុក្រឹត្យស្តីពីសម្បទានដីសេដ្ឋកិច្ច ជាពិសេស មាត្រា៥៩ នៃច្បាប់ ភូមិបាល ទាក់ទងនឹងការកាន់កាប់ដីសម្បទានច្រើនកន្លែងរួមគ្នាដែលមានទំហំលើសពី ១០.០០០ ហិកតា ។

- បង្កើតយន្តការមួយ ដែលផ្តល់លទ្ធភាពឱ្យសហគមន៍ ឬតំណាងសហគមន៍ ផ្តួចផ្តើមសកម្មភាពដើម្បី តវ៉ាអំពី សុពលភាពនៃសម្បទានដីសេដ្ឋកិច្ច និងស្នើសុំឱ្យពិនិត្យឡើងវិញ ឬលុបចោល ។

- ជួយដល់គ្រួសារប្រជាពលរដ្ឋនៅសហគមន៍ជនបទ ដើម្បីចុះបញ្ជីនូវអ្វីៗដែលជា អត្ថប្រយោជន៍ របស់ពួកគេលើដីធ្លី ស្របតាមច្បាប់ភូមិបាល ។

## ឧបសម្ព័ន្ធ ១៖ ស្ថិតិដីសម្បទានគោលដៅសេដ្ឋកិច្ចដែលមានកិច្ចសន្យា និងការយល់ព្រមជាគោលការណ៍

( ប្រភព៖ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ គិតត្រឹមថ្ងៃទី 31 ខែធ្នូ ឆ្នាំ2006)

| លេខរៀង | ទីតាំង<br>ប្រភេទសហគមន៍<br>ប្រភេទដំណាំ | សម្បទានិក | ប្រធានក្រុមហ៊ុន<br>សញ្ជាតិ | ផ្ទៃដី<br>(ហិកតា) | កាលបរិច្ឆេទ<br>ចុះកិច្ចសន្យា | ប្រាក់កក់ | សកម្មភាព | |
|---|---|---|---|---|---|---|---|---|
| | | | | | | | កំណត់ផ្ទៃដីធ្វើអាជីវកម្ម | ដាំដុះ |
| **ខេត្តស្ទឹងត្រែង** | | | | | | | | |
| 1 | -ស្រុក ស្ទឹងត្រែង និង ស្រុក ថាឡាបរិវត្ត<br>-ម៉ៃសាក់ | ក្រុមហ៊ុនផលិតម្សៅដំឡូងមីចំកាត់ | -កែវ វុទ្ធី<br>-ខ្មែរ | 7.400 | 13/09/99 | បង់រួច | បានកំណត់ | បានដាំ |
| 2 | -ស្រុក ស្ទឹងត្រែង<br>-ម៉ៃសាក់ ច័ន្ទក្រឹះស្នា ឈើហូបផ្លែ | ក្រុមហ៊ុន ជី.ជី វើលគ្រុប<br>(GG World Group (Cambodia) Development Ltd) | -អាន យ៉ាំង យិន ឆាំង<br>-ចិន | 5.000 | 18/05/05 | ពុំទាន់បង់ | បានកំណត់ | មិនបានដាំ |
| 3 | -ស្រុក សេសាន<br>-ជនជាតិដើមភាគតិច<br>-អាកាស្យា កៅស៊ូ ម៉ៃសាក់ | ក្រុមហ៊ុនសុភក្តិនីកា អ៊ិនវេសមេន អាហ្គ្រោ អ៊ិនដាសស្ទ្រៀល ផ្លេន | -ម៉ែន សុភក្តិ<br>-ខ្មែរ | 10.000 | 08/08/05 | ពុំទាន់បង់ | បានកំណត់ | បានដាំ |
| 4 | -ស្រុក សេសាន<br>- ជនជាតិដើមភាគតិច<br>-អាកាស្យា កៅស៊ូ ម៉ៃសាក់ | ក្រុមហ៊ុន សលុ សុភា ពាណិជ្ជ | -ឈុន កុសល<br>-ខ្មែរ | 9.917 | 08/08/05 | ពុំទាន់បង់ | បានកំណត់ | បានដាំ |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| 5 | -ស្រុក សេសាន<br>- ជនជាតិដើមភាគតិច<br>-ម៉ៃសាក់<br>និងប្រភេទឈើផ្សេងទៀត | ក្រុមហ៊ុន ហ្គ្រេនលេន<br>(Grand Land Agriculture Development (Cambodia) Co Ltd) | -អាន យ៉ាំង យិន ឆាំង<br>-ចិន | 9.854 | 23/01/06 | ពុំទាន់បង់ | បានកំណត់ | បានដាំ |
| 6 | -ស្រុក សេសាន<br>- ជនជាតិដើមភាគតិច<br>-ម៉ៃសាក់<br>និងប្រភេទឈើផ្សេងទៀត | ក្រុមហ៊ុន ស៊ីវ ហ្គេក អ៊ិនវេសមេន | -អ៊ឹង ស៊ីវហ្គេក<br>-ខ្មែរ | 10.000 | 24/01/06 | ពុំទាន់បង់ | ពុំទាន់<br>បានកំណត់ | បានដាំ |
| 7 | -ស្រុក សេសាន<br>- ជនជាតិដើមភាគតិច<br>-ម៉ៃសាក់<br>និងប្រភេទឈើផ្សេងទៀត | ក្រុមហ៊ុន ភូ ម៉ាឌី អ៊ិនវេសមេន គ្រុប | -អាន យ៉ាំង យិន ឆាំង<br>-ចិន | 9.854 | 24/01/06 | ពុំទាន់បង់ | ពុំទាន់<br>បានកំណត់ | បានដាំ |
| 8 | -ស្រុក សេសាន<br>-ម៉ៃសាក់ អាកាស្យា<br>និងប្រភេទឈើផ្សេងទៀត | ក្រុមហ៊ុន សុក ហេង | -លី សុខហេង<br>-ខ្មែរ | 7.172 | 27/01/06 | ពុំទាន់បង់ | ពុំទាន់<br>បានកំណត់ | បានដាំ |
| 9 | -ស្រុក សៀមប៉ាង<br>-ជនជាតិដើមភាគតិច<br>-កសិ-ឧស្សាហកម្ម<br>និងចិញ្ចឹមសត្វ | ក្រុមហ៊ុន សេកុង អភិវឌ្ឍន៍ | -តាំង ហួត<br>-ខ្មែរ | 9.850 | 12/04/06 | បង់រួច | ពុំទាន់<br>បានកំណត់ | មិនបានដាំ |
| 10 | -ស្រុក ស្ទឹងត្រែង និង ស្រុក | ក្រុមហ៊ុន ហ្គ្រីន ស៊ី អ៊ិនដាសស្ទ្រី | -ម៉ុង រិទ្ធី | 100.852 | 23/11/01 | បង់រួច | បានកំណត់ | មិនបានដាំ |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| | សៀមប៉ាង<br>-ជនជាតិដើមភាគតិច<br>-ម៉ៃសាក់ | (បច្ចុប្បន្នមានឈ្មោះ ហ្គ្រីន ស៊ី អាហ្គ្រីខលឆឺ) | -ខ្មែរ | | | | | |
| **ខេត្តក្រចេះ** | | | | | | | | |
| 11 | -ស្រុក សំបូរ<br>-ជនជាតិដើមភាគតិច<br>-ម៉ៃសាក់ | ក្រុមហ៊ុន គ្លូបល អាហ្គ្រីខលឆឺរល ឌីវឺឡុបមិន (Global Agricultural Development (Cambodia) Co Ltd) | -ក្វុក ឡាយ ងាន់ វ៉ាន់<br>-អាមេរិកកាំង | 9.800 | 15/03/06 | បង់រួច | បានកំណត់ | បានដាំ |
| 12 | -ស្រុក សំបូរ<br>-ជនជាតិដើមភាគតិច<br>-ម៉ៃសាក់ | ក្រុមហ៊ុន អាស៊ី វឺល អាហ្គ្រីខលឆឺរល ឌីវឺឡុបមិន (Asia World Agricultural Development (Cambodia) Co Ltd) | -វ៉ាន់ អ៊ីលូ ម៉ីង<br>-ចិន | 10.000 | 15/03/06 | បង់រួច | បានកំណត់ | បានដាំ |
| 13 | -ស្រុក សំបូរ<br>-ជនជាតិដើមភាគតិច<br>-ម៉ៃសាក់ | ក្រុមហ៊ុន ហ្គ្រីន អាយលេន អាហ្គ្រីខលឆឺរល ឌីវឺឡុបមិន (Green Island Agricultural Development (Cambodia) Co Ltd) | -ក្វុក ស្តេនលីយ កាគឿន<br>-អាមេរិកកាំង | 9.583 | 15/03/06 | បង់រួច | បានកំណត់ | បានដាំ |
| 14 | -ស្រុក សំបូរ<br>-ជនជាតិដើមភាគតិច<br>-ឈើហ្វាលាន | ក្រុមហ៊ុន ផ្លេនថេស៊ិន អាហ្គ្រីខលឆឺរល ឌីវឺឡុបមិន (Plantation Agricultural Development (Cambodia) Limited) | -ក្វុក ស្តេនលីយ កាគឿន<br>-អាមេរិកកាំង | 9.214 | 11/08/06 | បង់រួច | ពុំទាន់ បានកំណត់ | បានដាំ |
| 15 | -ស្រុក សំបូរ<br>-ជនជាតិដើមភាគតិច<br>-ឈើហ្វាលាន | ក្រុមហ៊ុន ហ្គ្រេត អេសេធ អាហ្គ្រីខលឆឺរល ឌីវឺឡុបមិន (Great Asset Agricultural Development (Cambodia) Limited) | -យ៉ាង យ៉ុង ហ្សុង<br>-ចិន | 8.985 | 11/08/06 | បង់រួច | ពុំទាន់ បានកំណត់ | បានដាំ |
| 16 | -ស្រុក សំបូរ | ក្រុមហ៊ុន ហ្គ្រេត វនឌឺ អាហ្គ្រីខលឆឺរល | -ក្វុក វិញ | 9.231 | 11/08/06 | បង់រួច | ពុំទាន់ | បានដាំ |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| | -ជនជាតិដើមភាគតិច<br>-ឈើហ្វាលាន | ឌីវីឡុបមិន<br>(Great Wonder Agricultural Development (Cambodia) Limited) | -ចិន | | | | បានកំណត់ | |
| 17 | -ស្រុក ស្នួល<br>-ជនជាតិដើមភាគតិច<br>-ដំឡូងមី កៅស៊ូ និង ស្វាយចន្ទី | ក្រុមហ៊ុន តាយ ណាំ ខេ | -ហា ធៀវ<br>-វៀតណាម | 7.560 | 18/09/06 | បង់រួច | ពុំទាន់<br>បានកំណត់ | មិនបានដាំ |
| **ខេត្ត រតនគិរី** | | | | | | | | |
| 18 | -ស្រុក អូយ៉ាដាវ<br>-ជនជាតិដើមភាគតិច<br>-ដូងប្រេង | ក្រុមហ៊ុន គ្លូបល តិច អេសឌីអេន ប៊ីអេចឌី រ៉ាម៉ាខ្មែរ អ៊ិនធឺណាស្យូណល និង មិត្តភាពម៉ែន សារ៉ុន<br>(Global Tech, Sdn Bhd, Rama Khmer International and Mittapeheap Men Sarun) | -ម៉ែន សារ៉ុន<br>-ខ្មែរ | 20.000 | 21/12/99 | ពុំទាន់បង់ | បានកំណត់ | មិនបានដាំ |
| 19 | -ស្រុក អូយ៉ាដាវ<br>-ជនជាតិដើមភាគតិច<br>-កៅស៊ូ ស្វាយចន្ទី និង ប៉ូឡូញ៉ា | ក្រុមហ៊ុន ៣០/៤ យ៉ាឡៃ<br>(30/4 Gialai Company Limited) | -ង្វៀន ស៊ីញ<br>-វៀតណាម | 9.380 | 26/04/05 | ពុំទាន់បង់ | មិនដឹង | មិនបានដាំ |
| 20 | -ស្រុក កូនមុំ<br>-ជនជាតិដើមភាគតិច<br>-ម៉ៃសាក់ | ក្រុមហ៊ុន ប៉េលីន ហ្គ្រុប អាហ្គ្រីខលឆឺរល ឌីវីឡុបមិន (Pelin Goup Agricultural Development (Cambodia) Limited) | -យ៉ាំង អិន ឆាំង<br>-ខ្មែរ | 8.847 | 11/08/06 | បង់រួច | ពុំទាន់<br>បានកំណត់ | មិនបានដាំ |
| 21 | -ស្រុក អណ្ដូងមាស<br>-ជនជាតិដើមភាគតិច<br>-អាកាស្យា និង កៅស៊ូ | ក្រុមហ៊ុន ហេង អភិវឌ្ឍន៍ | -ស៊ាង ចាន់ហេង<br>-ខ្មែរ | 8.654 | 25/05/06 | បង់រួច | ពុំទាន់<br>បានកំណត់ | មិនបានដាំ |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| 22 | -ស្រុក អណ្តូងមាស<br>-ជនជាតិដើមភាគតិច<br>-កៅស៊ូ | ក្រុមហ៊ុន អរយ៉ាំង ខនស្រាក់សិន (Oryung Construction (ACM) Co Ltd) | -លឹម សុង ជុល<br>-កូរ៉េ | 6.866 | 04/04/06 | បង់រួច | ពុំទាន់បានកំណត់ | មិនបានដាំ |
| 23 | -ស្រុក អូយ៉ាដាវ<br>-ជនជាតិដើមភាគតិច<br>-កសិ-ឧស្សាហកម្ម | ក្រុមហ៊ុន ហេង ហ៊ាប អ៊ិនវេសមេន | (មិនមានព័តិមាន) | 7.000 | ទទួលការយល់ព្រមជាគោលការណ៍ចុះថ្ងៃទី 25/07/0៦ | | | |
| 24 | (មិនមានពត័មាន) | ក្រុមហ៊ុន តាយ សេង | (មិនមានព័តិមាន) | 2.000 | ទទួលការយល់ព្រមជាគោលការណ៍ចុះថ្ងៃទី 25/12/98 | | | |
| **ខេត្តមណ្ឌលគិរី** | | | | | | | | |
| 25 | -ស្រុក កែវសីម៉ា<br>-ជនជាតិដើមភាគតិច<br>-ដំឡូងមី កៅស៊ូ និង ស្វាយចន្ទី | ក្រុមហ៊ុន តាយ ណាំ ប៊ី.ភី.អឹម | -ហា ដាយ វ៉ុង<br>-វៀតណាម | 7.600 | 18/09/06 | បង់រួច | ពុំទាន់បានកំណត់ | មិនបានដាំ |
| 26 | -ស្រុក អូរាំង<br>-ជនជាតិដើមភាគតិច | ក្រុមហ៊ុន អ៊ូជីសាន អេល.អេស ហ្គ្រុប (Wuzhishan LS Group Co Ltd) | -លីវ វ៉េយ<br>-ចិន | 10.000 | 30/12/05 | ពុំទាន់បង់ | មិនដឹង | បានដាំ |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| | -ឈើស្រល់ | | | | | | | |
| 27 | -ស្រុក អូរាំង | ក្រុមហ៊ុន យ៉ាលីន អ៊ិនធើណាស្យូណល ត្រាស់ អ៊ិនវេសមេន និង ក្រុមហ៊ុន អូសៀន ស្ពេក អ៊ិនវេសមេន (Yalin International Trust and Investment (Cambodia) Co Ltd and Ocean Spact Investment (Cambodia) Co Ltd) | ( មិនមាន ព័តិមាន) | 19.900 | ទទួលការ យល់ព្រមជា គោលការណ៍ ចុះថ្ងៃទី 11/09/04 | | | |
| **ខេត្ត កំពង់ស្ពឺ** | | | | | | | | |
| 28 | -ស្រុក ភ្នំស្រួច<br>-ដំឡូងមី | សាជីវកម្ម ស៊ី.ជេ ខាំបូឌាចំកាត់<br>(Cambodia C.J Corporation Ltd.) | -អ៊ី.ជេ. ឆយ<br>-កូរ៉េ | 3.000 | 15/11/99 | បង់រួច | បានកំណត់ | បានដាំ |
| 29 | -ស្រុក ភ្នំស្រួច<br>-ដំឡូងមី | សាជីវកម្ម ស៊ី.ជេ ខាំបូឌាចំកាត់<br>(Cambodia C.J Corporation Ltd.) | -អ៊ី.ជេ. ឆយ<br>-កូរ៉េ | 5.000 | 20/04/01 | បង់រួច | បានកំណត់ | មិនបានដាំ |
| 30 | -ស្រុក ភ្នំស្រួច<br>-ដំឡូងមី | ក្រុមហ៊ុន គីមស្វិល ខប<br>(Kimsville Corp) | -ជេ ហ៊ិ គីម<br>-ចិន | 3.200 | 24/10/00 | បង់រួច | ពុំទាន់ បានកំណត់ | មិនបានដាំ |
| 31 | -ស្រុក ភ្នំស្រួច<br>-ដំណាំកសិកម្ម និង ចិញ្ចឹមសត្វ | ក្រុមហ៊ុន ហេណាន<br>(Henan (Cambodia) Economic & Trade Development Zone) | -លី ដុងហ្វា<br>-ចិន | 4.100 | 29/07/99 | ពុំទាន់បង់ | ពុំទាន់ បានកំណត់ | មិនបានដាំ |
| 32 | -ស្រុក ឱរ៉ាល់ និងស្រុក ភ្នំស្រួច<br>-ល្ហុងប្រេង និងពហុកសិកម្ម | ក្រុមហ៊ុន ខាំបូឌា ហៃនីញ ហ្គ្រុប<br>(Cambodia Haining Group Co Ltd) | -យ៉ាំង ស៊ាវហ្វ<br>-ចិន | 23.000 | 23/07/98 | ពុំទាន់បង់ | ពុំទាន់ បានកំណត់ | ពិសោធន៍ដំណាំ |
| 33 | -ស្រុក ភ្នំស្រួច<br>-ស្វាយចន្ទី | ក្រុមហ៊ុន អភិវឌ្ឍន៍ដំណាំឧស្សាហកម្ម អ៊ុក ឃុន | -សុក សុភាព<br>-ខ្មែរ | 12.506 | 25/05/01 | បង់រួច | ពុំទាន់ បានកំណត់ | បានដាំ |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| 34 | -ស្រុក ឱរ៉ាល់ ស្រុក ភ្នំស្រួច និងស្រុក សំរោងទង<br>-ដំណាំកសិកម្ម | ក្រុមហ៊ុន ខាំបូ វិចទឺ<br>(Cambo Victor Investing and Developing Co Ltd) | -វ៉ាង ស៊ិនមិញ<br>-ចិន | 26.550 | 13/08/01 | ពុំទាន់បង់ | ពុំទាន់បានកំណត់ | មិនបានដាំ |
| 35 | -ស្រុក ភ្នំស្រួច<br>-ដំណាំកសិ-ឧស្សាហកម្ម | ក្រុមហ៊ុន ឆាយណា ណាស្យូណល ខភឺរេស្សិន<br>(China National Corporation for Overseas Economic Cooperation Laostar Development Co Ltd) | -ជូ ជុន ជេ<br>-ចិន | 8.000 | 26/09/00 | ពុំទាន់បង់ | ពុំទាន់បានកំណត់ | មិនបានដាំ |
| 36 | -ស្រុក ភ្នំស្រួច<br>-ដំណាំកសិ-ឧស្សាហកម្ម | ក្រុមហ៊ុន ហ្គោលឌិន លេន ឌីវឺឡុបមិន | -ឆាំង អ៊ី ភីន<br>-តៃវ៉ាន់ | 4.900 | 04/03/04 | ពុំទាន់បង់ | | បានដាំ |
| 37 | (មិនមានព័ត៌មាន) | ក្រុមហ៊ុន ហួរ ហុង អ៊ិនវេសមេន | (មិនមានព័ត៌មាន) | 2.040 | ទទួលការយល់ព្រមជាគោលការណ៍ ចុះថ្ងៃទី 14/08/04 | | | |
| 38 | (មិនមានព័ត៌មាន) | ក្រុមហ៊ុន អឹម ខនសូលីឌេត ផ្លេនថេសិន<br>(M Consolidated Plantation) | (មិនមានព័ត៌មាន) | 12.700 | ទទួលការយល់ព្រមជាគោលការណ៍ ចុះថ្ងៃទី 04/08/97 | | | |
| **ខេត្តកំពង់ធំ** | | | | | | | | |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| 39 | -ស្រុក សន្ទុក<br>-កប្បាស | ក្រុមហ៊ុន ខាំបូឌា អេវើស្កាយ អាហ្គ្រីខលឆឺរល ឌីវើឡុបមិន<br>(Cambodia Eversky Agricultural Development) | -តាំង កាំសាន<br>-ខ្មែរ | 10.000 | 03/01/98 | បង់រួច | ពុំទាន់ បានកំណត់ | ពិសោធន៍ដំណាំ |
| 40 | -ស្រុក ប្រាសាទបល័ង្គ<br>-ជនជាតិដើមភាគតិច<br>-អាកាស្យា | ក្រុមហ៊ុន អាន ម៉ាឌី គ្រុប | -អាន ម៉ាឌី<br>-ខ្មែរ | 9.863 | 09/05/05 | ពុំទាន់បង់ | បានកំណត់ | មិនបានដាំ |
| 41 | -ស្រុក សន្ទុក<br>-អាកាស្យា និង ប្រភេទឈើផ្សេងទៀត | ក្រុមហ៊ុន អេឆ.អឹម.អេឆ<br>(HMH Co Ltd) | -អេល វ៉ាដា<br>-ខ្មែរ | 5.914 | 17/03/06 | បង់រួច | បានកំណត់ | មិនដឹង |
| 42 | -ស្រុកសន្ទុក<br>-កៅស៊ូ និង អាកាស្យា | ក្រុមហ៊ុន មាន ឫទ្ធី ខូអិល ធីឌី | -មាន ឫទ្ធី<br>-ខ្មែរ | 9.784 | 16/03/06 | បង់រួច | បានកំណត់ | មិនដឹង |
| **ខេត្តបាត់ដំបង** | | | | | | | | |
| 43 | -ស្រុក កំរៀង<br>-ដំណាំអំពៅ | ក្រុមហ៊ុន លាង ហួ ហុង អាហារណ៍ និហរណ៍ និង អភិវឌ្ឍន៍ ដំណាំកសិ-ឧស្សាហកម្ម និង កែច្នៃ | -លី មៀន<br>-ខ្មែរ | 8.000 | 07/06/00 | បង់រួច | ពុំទាន់ បានកំណត់ | បានដាំ |
| **ខេត្តពោធិសាត់** | | | | | | | | |
| 44 | -ស្រុក ក្រគរ | ក្រុមហ៊ុន រតនា វិសាល | -វ៉ាន់ វិសាល | 3.000 | 15/10/99 | បង់រួច | ពុំទាន់ | បានដាំ |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| | -ស្វាយចន្ទី | | -ខ្មែរ | | | | បានកំណត់ | |
| 45 | -ស្រុក ក្រគរ ស្រុក សំពៅមាស និងស្រុក ក្រវ៉ាន់<br>-អាកាស្យា | ក្រុមហ៊ុន ភាពីម៉ិច | -ឡាវ ម៉េងឃីន<br>-ខ្មែរ | 138.963 | 08/01/00 | ពុំទាន់បង់ | ពុំទាន់<br>បានកំណត់ | មិនបានដាំ |
| **ខេត្តកំពង់ឆ្នាំង** | | | | | | | | |
| 46 | -ស្រុក ទឹកផុស ស្រុក សាមគ្គីមានជ័យ និងស្រុក បរិបូរណ៍<br>-អាកាស្យា | ក្រុមហ៊ុន ភាពីម៉ិច | -ឡាវ ម៉េងឃីន<br>-ខ្មែរ | 176.065 | 08/01/00 | ពុំទាន់បង់ | ពុំទាន់<br>បានកំណត់ | មិនបានដាំ |
| **ក្រុងព្រះសីហនុ** | | | | | | | | |
| 47 | -ខ័ណ្ឌ ព្រៃនប់<br>-ដូងប្រេង | ក្រុមហ៊ុន ម៉ុង ឫទ្ធី វិនិយោគទុន ដំណាំដូងប្រេង កម្ពុជា | -ម៉ុង ឫទ្ធី<br>-ខ្មែរ | 11.000 | 09/01/95 | ពុំទាន់បង់ | ពុំទាន់<br>បានកំណត់ | បានដាំ |
| 48 | - ខ័ណ្ឌ ព្រៃនប់<br>-ដំឡូងមី | ក្រុមហ៊ុន ម៉ុង ឫទ្ធី វិនិយោគទុន ដំណាំដំឡូងមី កម្ពុជា | -ម៉ុង ឫទ្ធី<br>-ខ្មែរ | 1.800 | 18/03/00 | ពុំទាន់បង់ | ពុំទាន់<br>បានកំណត់ | បានដាំ |
| **ខេត្ត កំពង់ចាម** | | | | | | | | |
| 49 | -ស្រុក ម៉េមត់<br>-កៅស៊ូ | ក្រុមហ៊ុន ធី ធី វ៉ាយ<br>(TTY Industrial Crops Development Import-Export) | -សេង ទូច<br>-ខ្មែរ | 1.070 | 02/05/00 | ពុំទាន់បង់ | ពុំទាន់<br>បានកំណត់ | មិនបានដាំ |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| 50 | -ស្រុក ម៉េមត់<br>-ដំឡូងមី និងអំពៅ | ក្រុមហ៊ុន វ៉ាន់ម៉ា អាហារណ៍ និហរណ៍ | -ព្រែល ប៊ុនម៉ាណែត<br>-ខ្មែរ | 1.200 | 29/09/04 | ពុំទាន់បង់ | | បានដាំ |
| 51 | -ស្រុក ម៉េមត់<br>-កៅស៊ូ | ក្រុមហ៊ុន មឿង លីហេង វិនិយោគ | -សុខ នី<br>-ខ្មែរ | 3.000 | 08/11/05 | បង់រួច | បានកំណត់ | មិនបានដាំ |
| 52 | -ស្រុក ម៉េមត់<br>-កៅស៊ូ ដំឡូងមី អាកាស្យា និង ស្វាយចន្ទី | ក្រុមហ៊ុន មិត្តភាព ម៉ែន សារុន | -ម៉ែន សារ៉ុន<br>-ខ្មែរ | 4.400 | 10/02/06 | ពុំទាន់បង់ | ពុំទាន់<br>បានកំណត់ | បានដាំ |
| 53 | -ស្រុក ជើងព្រៃ<br>-ស្វាយចន្ទី | ក្រុមហ៊ុន អាគ្រោ ស្តា | -សុខ មុនី<br>-ខ្មែរ | 2.400 | 09/01/95 | ពុំទាន់បង់ | បានកំណត់ | បានដាំ |
| 54 | (មិនមានព័ត៌មាន) | ក្រុមហ៊ុន បុផ្ផា អង្គរីម៉ិច ត្រង់កុង | (មិនមាន ព័ត៌មាន) | 5.000 | ទទួលការយល់ព្រមជាគោលការណ៍ ចុះថ្ងៃទី 17/02/៩៩ | | | |
| **ខេត្ត កំពត** | | | | | | | | |
| 55 | -ស្រុក ឈូក<br>-ពោត សណ្តែក ដំឡូងមី | ក្រុមហ៊ុន ហ្វឺស បៃអឺ តិច<br>(First Bio-Tech Agricultural (Cambodia) Co Ltd) | -ចាន់ សុធា<br>-ខ្មែរ | 10.000 | 21/04/05 | បង់រួច | បានកំណត់ | មិនបានដាំ |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| | អាកាស្សា និង ប្រេងខ្យល់ | | | | | | | |
| 56 | -ស្រុក កំពត និង ស្រុក កំពង់បាយ<br>-ដូងប្រេង | ក្រុមហ៊ុន ខេមលេន អាហារណ៍ នីហរណ៍ (Camland Import Export) | -អ៊ឹង សុភាព<br>-ខ្មែរ | 16.400 | 26/10/00 | ពុំទាន់បង់ | ពុំទាន់ បានកំណត់ | មិនបានដាំ |
| 57 | -ស្រុក ឈូក<br>-ពោត សណ្តែក អាកាស្សា និង ប្រេងខ្យល់ | ក្រុមហ៊ុន វើល ទ្រីស្តា អិនធឺថេនមេន (World Tristar Entertainment (Cambodia) Co Ltd) | -គីម ហួត<br>-ខ្មែរ | 9.800 | 21/04/05 | បង់រួច | បានកំណត់ | មិនបានដាំ |
| **ខេត្ត ឧត្តរមានជ័យ** | | | | | | | | |
| 58 | -ស្រុក សំរោង<br>-ជនជាតិដើមភាគតិច<br>-ដំឡូងមី និង ដំណាំកសិ-ឧស្សាហកម្ម | ក្រុមហ៊ុន រៀលហ្គ្រីន (Real Green Co Ltd) | -ប៊ូនស៊ុង ប៉ាតារ៉ាសុងក្រាម<br>-ថៃ | 8.000 | 06/09/06 | បង់រួច | ពុំទាន់ បានកំណត់ | មិនបានដាំ |
| 59 | -ស្រុក សំរោង<br>-ជនជាតិដើមភាគតិច<br>-ដំឡូងមី និង ដំណាំ កសិ-ឧស្សាហកម្ម | ក្រុមហ៊ុន គ្រីស្តាល អាហ្គ្រោ (Crystal Agro Company Limited) | -ស៊ូរីត វីតឆាវូត<br>-ខ្មែរ | 8.000 | 17/07/06 | បង់រួច | ពុំទាន់ បានកំណត់ | មិនបានដាំ |
| **ខេត្ត កោះកុង** | | | | | | | | |
| 60 | -ស្រុក កោះកុង<br>-ដូងប្រេង និង អាកាស្សា | ក្រុមហ៊ុន ហ្គ្រីន រិច (The Green Rich Co Ltd) | -ឈិន ឆាំង ប៉ាង<br>-ចិន | 60.200 | 25/11/98 | បង់រួច | ពុំទាន់ បានកំណត់ | មិនបានដាំ |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| 61 | -ស្រុក ស្រែអំបិល<br>-ដំណាំអំពៅ | ក្រុមហ៊ុន កោះកុង ស៊ូហ្គើរ អ៊ិនដាសស្ទ្រី ខមភេនី លីមីធីត (Koh Kong Sugar Industry Company Limited) | -ចំរើន ឈឹនថាមិត<br>-ថៃ | 9.700 | 02/08/06 | ពុំទាន់បង់ | ពុំទាន់ បានកំណត់ | បានដាំ |
| 62 | -ស្រុក បុទុមសាគរ<br>-ដំណាំអំពៅ | ក្រុមហ៊ុន កោះកុង ផ្លេនថេសិន ខមភេនី លីមីធីត (Koh Kong Plantation Company Limited) | -លី យ៉ុងផាត់<br>-ខ្មែរ | 9.400 | 02/08/06 | ពុំទាន់បង់ | ពុំទាន់ បានកំណត់ | មិនបានដាំ |
| 63 | -ស្រុក កំពង់សីលា និង ស្រុក ស្រែអំបិល<br>-អាកាស្យា និង ដំណាំកសិ-ឧស្សាហកម្ម | ក្រុមហ៊ុន កាំម៉ាក្រា អិនវេសមេន (Camagra Investment Co Ltd) | ( មិនមាន ព័ត៌មាន) | 5.525 | ទទួលការ យល់ព្រមជា គោលការណ៍ ចុះថ្ងៃទី 30/11/06 | | | |
| **ខេត្ត សៀមរាប** | | | | | | | | |
| 64 | -ស្រុក ជីក្រែង និង ស្រុក ស្វាយលើ<br>-កៅស៊ូ | ក្រុមហ៊ុន ខេន (Kain Co Ltd) | -ឡាំង សាលី<br>-ខ្មែរ | 4.535 | 29/09/06 | បង់រួច | ពុំទាន់ បានកំណត់ | មិនបានដាំ |
| 65 | -ស្រុក វ៉ារិន និង ស្រុក អន្លង់វែង<br>-កៅស៊ូ និង អាកាស្យា | ក្រុមហ៊ុន សំរោងរ៉ាប់បឺរ អ៊ីនដាសស្ទ្រី ភីធីអ៊ី អិលធីឌី (Samrong Rubber Industry PTT Ltd) | -ប៉ាង ណាំ<br>-ខ្មែរ | 9.658 | 12/04/06 | បង់រួច | ពុំទាន់ បានកំណត់ | បានដាំ |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| 66 | -ស្រុក ជីក្រែង<br>-កៅស៊ូ | ក្រុមហ៊ុន សោភ័ណ ធារី ពាណិជ្ជ | -សំ គិមលីន<br>-ខ្មែរ | 5.042 | 29/09/06 | បង់រួច | ពុំទាន់បានកំណត់ | មិនបានដាំ |
| 67 | -ស្រុក បន្ទាយស្រី<br>-ដំណាំកសិ-ឧស្សាហកម្ម | ក្រុមហ៊ុន រតនា ខភីរសិន | ( មិនមាន ព័ត៌មាន) | 1.351 | ទទួលការយល់ព្រមជាគោលការណ៍ចុះថ្ងៃទី 12/11/06 | | | |
| **ខេត្ត ព្រះវិហារ** | | | | | | | | |
| 68 | -ស្រុក រវៀង | ក្រុមហ៊ុន ខាំបូឌា អាគ្រោ អ៊ិនដាសស្ទ្រី គ្រុប (Cambodian Agro Industry Group) | ( មិនមាន ព័ត៌មាន) | 8.692 | ទទួលការយល់ព្រមជាគោលការណ៍ចុះថ្ងៃទី 26/07/06 | | | |

**សារុបៈ** **ក្រុមហ៊ុនដីសម្បទានដែលមានកិច្ចសន្យា** **943.069 ហិកតា**

**ក្រុមហ៊ុនដីសម្បទានដែលបានមានការយល់ព្រមជាគោលការណ៍ពីរដ្ឋាភិបាល** **64.208 ហិកតា**

## ឧបសម្ព័ន្ធ 2: ស្ថិតិដីសម្បទានគោលដៅសេដ្ឋកិច្ចដែលបានលុបកិច្ចសន្យា និងគោលការណ៍

(ប្រភព: ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ គិតត្រឹមថ្ងៃទី 31 ខែធ្នូ ឆ្នាំ2006)

| លេខរៀង | ឈ្មោះក្រុមហ៊ុន | ទីតាំង | ផ្ទៃដី (ហិកតា) | ការព្រមព្រៀងជាគោលការណ៍ | ចុះហត្ថលេខាលើកិច្ចសន្យា | លុបច្បាប់អនុញ្ញាតិ និង សេចក្ដីយោង | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| 1 | ក្រុមហ៊ុន អភិវឌ្ឍន៍កសិកម្ម លីមត្រី | ខេត្ត តាកែវ | 1,050 | លិខិត លេខ 686 គ.វិ.ក ចុះថ្ងៃទី 03.08.95 | មិនទាន់ចុះ | លិខិតទីស្ដីការគណៈរដ្ឋមន្ត្រី លេខ 1780 សជណ.សរ ចុះថ្ងៃទី 25.10.05 | -មិនបានចូលមកបំពេញ បែបទវិនិយោគ<br>-មិនមានសកម្មភាព និង មិនបំពេញទៅតាម តំរូវការនៃនិតិវិធីនៃវិនិយោគ<br>-គ្មានអាស័យដ្ឋានទាក់ទង |
| 2 | ក្រុមហ៊ុន វ៉ាត វណ្ណី | ខេត្ត កំពង់ធំ | 3,000 | លិខិត លេខ 5400 កសក.ផផក ចុះថ្ងៃទី 05.04.95 | មិនទាន់ចុះ | លិខិតទីស្ដីការគណៈរដ្ឋមន្ត្រី លេខ 1381 សជណ.សរ ចុះថ្ងៃទី 14.08.00 | -គ្មានអាស័យដ្ឋានទាក់ទង<br>-បាត់ទំនាក់ទំនង |
| 3 | ក្រុមហ៊ុន អាស៊ី ហ្គោលឌិន ត្រាហ្គន (Asia Golden Dragon) | ខេត្ត កំពង់ចាម | 4,000 | លិខិត លេខ 6204 កសក.ផផក ចុះថ្ងៃទី 11.10.95 | មិនទាន់ចុះ | ប្រកាសរបស់ក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ លេខ 333 ប្រក.កសក.ផ.ផក ចុះថ្ងៃទី 31.05.00 ស្ដីពីការលុបគោលការណ៍ សម្បទាន | -មិនមានសកម្មភាព<br>-បោះបង់ចោល គំរោងវិនិយោគ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| 4 | ក្រុមហ៊ុន យូនីក យូនីហ្វាយ អ៊ិនធឺណា-ស្យូណាល់ ត្រេដ (Unique Unified International Trade) | ខេត្ត មណ្ឌលគិរី | 20,000 | លិខិត លេខ 185 សជណ.ផស ចុះថ្ងៃទី 14.02.96 | មិនទាន់ចុះ | លិខិតទីស្តីការគណៈរដ្ឋមន្ត្រី លេខ 142 សជណ.កស ចុះថ្ងៃទី 20.03.00 | -មិនបានបំពេញត្រឹមត្រូវ នូវដំណើរការនៃការចុះកិច្ចសន្យា<br>-មិនបានចូលមកទាក់ទង |
| 5 | ក្រុមហ៊ុន ជុង ស៊ីង ខាំបូឌា (Chung Shin Cambodia) | ខេត្ត កោះកុង | 16,000 | លិខិត លេខ 476 សជណ ចុះថ្ងៃទី 15.06.96 | មិនទាន់ចុះ | លិខិតទីស្តីការគណៈរដ្ឋមន្ត្រី លេខ 1780 សជណ.សរ ចុះថ្ងៃទី 25.10.05 | -មិនបានចូលមកបំពេញ បែបទវិនិយោគ<br>-មិនមានសកម្មភាព និង មិនបំពេញទៅតាម តំរូវការនៃនិតិវិធីនៃវិនិយោគ<br>-គ្មានអាស័យដ្ឋានទាក់ទង |
| 6 | ក្រុមហ៊ុន ស៊ីង យូ ខាមឺសល (Shing YUE Commercial) | ខេត្ត កំពត | 10,000 | លិខិត លេខ 040/96 គ.វិ.ក ចុះថ្ងៃទី 11.01.96 | មិនទាន់ចុះ | លិខិតទីស្តីការគណៈរដ្ឋមន្ត្រី លេខ 1780 សជណ.សរ ចុះថ្ងៃទី 25.10.05 | -មិនបានចូលមកបំពេញ បែបទវិនិយោគ<br>-មិនមានសកម្មភាព និង មិនបំពេញទៅតាម តំរូវការនៃនិតិវិធីនៃវិនិយោគ<br>-គ្មានអាស័យដ្ឋានទាក់ទង |
| 7 | ក្រុមហ៊ុន ស៊ីនថៃកំពត (Sin Tahi Kampot Co., Ltd0 | ខេត្ត កំពត | 5,700 | លិខិត លេខ 864/96 គ.វិ.ក ចុះថ្ងៃទី 26.06.96 | មិនទាន់ចុះ | លិខិតទីស្តីការគណៈរដ្ឋមន្ត្រី លេខ 1780 សជណ.សរ ចុះថ្ងៃទី25.10.05 | -មិនបានចូលមកបំពេញ បែបទវិនិយោគ<br>-មិនមានសកម្មភាព និង មិនបំពេញទៅតាម តំរូវ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | | | | | | | ការនៃនិតិវិធីនៃវិនិយោគ<br>-គ្មានអាស័យដ្ឋានទាក់ទង |
| 8 | ក្រុមហ៊ុន យៀន ជេន ត្រេឌីង ឬ សាជីវកម្ម ដំឡូងឈើកម្ពុជា (Yean Jan Trading Co Ltd or Cambodia Tapioca Corporation Limited) | ខេត្ត កំពត | 3,800 | លិខិត លេខ 2507/96 គ.វិ.ក ចុះថ្ងៃទី 06.11.96 | មិនទាន់ចុះ | លិខិតទីស្តីការគណៈរដ្ឋមន្ត្រី លេខ 442 សជណ.កស ចុះថ្ងៃទី 20.03.00 | -មិនបានបំពេញត្រឹមត្រូវ នូវបែបបទនៃការចុះកិច្ចសន្យា<br>-មិនបានចូលមកទាក់ទង |
| 9 | សហគ្រាស ដំឡូងឈើកម្ពុជា (Cambodian Tapioca Interprise) | ខេត្ត កំពត | 5,100 | លិខិត លេខ 2504/96 គ.វិ.ក ចុះថ្ងៃទី 06.11.96 | មិនទាន់ចុះ | លិខិតទីស្តីការគណៈរដ្ឋមន្ត្រី លេខ 1780 សជណ.សរ ចុះថ្ងៃទី 25.10.05 | -មិនបានចូលមកបំពេញ បែបទវិនិយោគ<br>-មិនមានសកម្មភាព និង មិនបំពេញទៅតាម តំរូវការនៃនិតិវិធីនៃវិនិយោគ<br>-គ្មានអាស័យដ្ឋានទាក់ទង |
| 10 | ក្រុមហ៊ុន ណាកូរ៉ៃ (Naco Rice) | ខេត្ត បាត់ដំបង | 2,000 | លិខិត លេខ 6857 កសក.ផ.ផក ចុះថ្ងៃទី 11.11.96 | មិនទាន់ចុះ | លិខិតទីស្តីការគណៈរដ្ឋមន្ត្រី លេខ 1780 សជណ.សរ ចុះថ្ងៃទី 25.10.05 | -មិនបានចូលមកបំពេញ បែបទវិនិយោគ<br>-មិនមានសកម្មភាព និង មិនបំពេញទៅតាម តំរូវការនៃនិតិវិធីនៃវិនិយោគ<br>-គ្មានអាស័យដ្ឋានទាក់ទង |
| 11 | ក្រុមហ៊ុន លី សេង | ខេត្ត បាត់ដំបង | 2,000 | លិខិត លេខ 6857 កសក.ផ.ផក ចុះថ្ងៃទី | មិនទាន់ចុះ | លិខិតទីស្តីការគណៈរដ្ឋមន្ត្រី លេខ 442 | -មិនបានបំពេញត្រឹមត្រូវ នូវបែបបទ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | អាហារណ៍ និហារណ៍ | | | 31.12.96 | | សជណ.កស ចុះថ្ងៃទី 20.03.00 | នៃការចុះកិច្ចសន្យា<br>-មិនបានចូលមកទាក់ទង |
| 12 | ក្រុមហ៊ុន ដួងប្រេងកម្ពុជា | ខេត្ត តាកែវ | 15,200 | លិខិត លេខ 7036/607 កសក.ផ.ផក ចុះថ្ងៃទី 19.12.96 | មិនទាន់ចុះ | ប្រកាសរបស់ក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ លេខ 333 ប្រក.កសក.ផ.ផក ចុះថ្ងៃទី 31.05.00 ស្តីពីការលុប គោលការណ៍ សម្បទាន | -មិនមានសកម្មភាព<br>-បោះបង់ចោលគំរោង វិនិយោគ |
| 13 | ក្រុមហ៊ុន ជុង ថៃ អ៊ិនវេសមេន (Chung Thai Investment) | ខេត្ត កោះកុង | 550 | លិខិត លេខ 7235 កសក.ផ.ផក ចុះថ្ងៃទី 31.12.96 | មិនទាន់ចុះ | លិខិតទីស្តីការគណៈរដ្ឋមន្ត្រី លេខ 1381 សជណ.សរ ចុះថ្ងៃទី 14.08.00 | -មិនមានគោលការណ៍ អនុញ្ញាតិពីរដ្ឋាភិបាល |
| 14 | ក្រុមហ៊ុន ជេល ជាដេន (ស៊ី.ជេ កម្ពុជា) (Chel Jadan (C.J Cambodia) | ខេត្ត កំពង់ស្ពឺ | 18,300 | លិខិត លេខ 2258/៩៧ កអខ ចុះថ្ងៃទី 04.08.97 | មិនទាន់ចុះ | លិខិតទីស្តីការគណៈរដ្ឋមន្ត្រី លេខ 442 សជណ.កស ចុះថ្ងៃទី 20.03.00 | -មិនបានបំពេញត្រឹមត្រូវ នូវបែបបទនៃការចុះកិច្ចសន្យា<br>-មិនបានចូលមកទាក់ទង |
| 15 | ក្រុមហ៊ុន អេស ខេ ចំរើន អភិវឌ្ឍន៍ (SK Chamroeun Akphiwath) | ខេត្ត រតនគិរី | 4,000 | លិខិត លេខ 243 សជណ.កស ចុះថ្ងៃទី 11.03.97 | មិនទាន់ចុះ | លិខិតទីស្តីការគណៈរដ្ឋមន្ត្រី លេខ 442 សជណ.កស ចុះថ្ងៃទី 20.03.00 | -មិនបានបំពេញត្រឹមត្រូវ នូវបែបបទនៃការចុះកិច្ចសន្យា<br>-មិនបានចូលមកទាក់ទង |
| 16 | ក្រុមហ៊ុន សួរ គា | ខេត្ត ពោធិសាត់ | 300 | លិខិត លេខ 001/96 គ.វិ.ក ចុះថ្ងៃទី | មិនទាន់ចុះ | លិខិតទីស្តីការគណៈរដ្ឋមន្ត្រី លេខ 1780 សជណ.កស ចុះថ្ងៃទី 25.10.05 | -មិនបានចូលមកបំពេញ បែបទវិនិយោគ<br>-មិនមានសកម្មភាព និង មិនបំពេញទៅតាម តំរូវ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | | | | 07.01.98 | | | ការនៃនិតិវិធីនៃវិនិយោគ<br>-គ្មានអាស័យដ្ឋានទាក់ទង |
| 17 | សហគ្រាស ខេ.សេ ហ្គិចសិន (K.C Gecin Enterprise) | ខេត្ត កំពង់ចាម | 6.250 | លិខិត លេខ 0299/636 កសក.ផផក ចុះថ្ងៃទី 20.01.98 | មិនទាន់ចុះ | ប្រកាសរបស់ក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ លេខ 333 ប្រក.កសក.ផ.ផក ចុះថ្ងៃទី 31.05.00 ស្តីពីការលុប គោលការណ៍ សម្បទាន | -មិនមានសកម្មភាព<br>-បោះបង់ចោល គំរោងវិនិយោគ |
| 18 | ក្រុមហ៊ុន ឆាយណា អេវើគ្រេត<br>(China Evergret) | ខេត្ត កំពត | 4.000 | លិខិត លេខ 416 សជណ ចុះថ្ងៃទី 23.05.98 | មិនទាន់ចុះ | លិខិតទីស្តីការគណៈរដ្ឋមន្ត្រី លេខ 1780 សជណ.កស ចុះថ្ងៃទី 25.10.05 | -មិនបានចូលមកបំពេញ បែបទវិនិយោគ<br>-មិនមានសកម្មភាព និង មិនបំពេញទៅតាម តំរូវការនៃនិតិវិធីនៃវិនិយោគ<br>-គ្មានអាស័យដ្ឋានទាក់ទង |
| 19 | ក្រុមហ៊ុន អភិវឌ្ឍន៍ ជំនួយកសិកម្ម អ៊ុន ប៊ូរិន | ខេត្ត កំពង់ស្ពឺ | 16.600 | លិខិត លេខ 740 សជណ ចុះថ្ងៃទី 11.06.98 | មិនទាន់ចុះ | លិខិតទីស្តីការគណៈរដ្ឋមន្ត្រី លេខ 1780 សជណ.កស ចុះថ្ងៃទី 25.10.05 | -មិនបានចូលមកបំពេញ បែបទវិនិយោគ<br>-មិនមានសកម្មភាព និង មិនបំពេញទៅតាម តំរូវការនៃនិតិវិធីនៃវិនិយោគ<br>-គ្មានអាស័យដ្ឋានទាក់ទង |
| 20 | ក្រុមហ៊ុន កំបូ ខេម | ខេត្ត កំពង់ធំ | 11.400 | លិខិត លេខ 918 សជណ ចុះថ្ងៃទី | មិនទាន់ចុះ | លិខិតទីស្តីការគណៈរដ្ឋមន្ត្រី លេខ 1381 សជណ.សរ ចុះថ្ងៃទី 14.08.00 | -មិនមានគោលការណ៍ អនុញ្ញាតិពីរដ្ឋាភិបាល |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | | | | 18.08.98 | | | |
| 21 | ក្រុមហ៊ុន វិនិយោគចំការកៅស៊ូ សូគីម៉ិច | ខេត្ត កំពង់ចាម | 9,900 | លិខិត លេខ 26 សជណ ចុះថ្ងៃទី 09.05.98 | កិច្ចសន្យា ចុះថ្ងៃទី 27.05.98 | លិខិតទីស្តីការគណៈរដ្ឋមន្ត្រី លេខ 1441 សជណ ចុះថ្ងៃទី 12.10.05 | -លុបចោលកិច្ចសន្យា<br>-ក្រុមហ៊ុនមិនអនុវត្តតាម កិច្ចសន្យា និងការណែនាំ របស់ក្រសួង បន្តសុំពន្យាពេលបង់ប្រាក់កក់ ការប្រព្រឹត្តមិនត្រឹមត្រូវ |
| 22 | ក្រុមហ៊ុន កាំ ជី អ៊ិនធឺណាស្យូណាល់ អាហ្គ្រីខលឆឺ ឌីវីឡុបមេន (Cam Chi International Agricultural Development) | ខេត្ត កំពង់ធំ | 26,500 | លិខិត លេខ 22 សជណ ចុះថ្ងៃទី 06.01.00 | កិច្ចសន្យា ចុះថ្ងៃទី 03.03.00 | លិខិតទីស្តីការគណៈរដ្ឋមន្ត្រី លេខ 581 សជណ ចុះថ្ងៃទី 07.04.06 | -លុបចោលកិច្ចសន្យា<br>-ក្រុមហ៊ុនមិនអនុវត្តតាម កិច្ចសន្យា និងការណែនាំ របស់ក្រសួង បន្តសុំពន្យាពេលបង់ប្រាក់កក់ ការប្រព្រឹត្តមិនត្រឹមត្រូវ |
| 23 | សមាគមន៍ អភិវឌ្ឍន៍កសិកម្ម | ខេត្ត កំពង់ចាម | 500 | មិនមានឯកសារ | មិនទាន់ចុះ | លិខិតទីស្តីការគណៈរដ្ឋមន្ត្រី លេខ 1381 សជណ.សរ ចុះថ្ងៃទី 14.08.00 | -មិនមានគោលការណ៍អនុញ្ញាតិពីរដ្ឋាភិបាល |
| 24 | ក្រុមហ៊ុន ម៉ាកា ផ្លេនថេស៊ិន (Maca Plantation) | ខេត្ត កំពង់ស្ពឺ | 10,800 | មិនមានឯកសារ | មិនទាន់ចុះ | លិខិតទីស្តីការគណៈរដ្ឋមន្ត្រី លេខ 1381 សជណ.សរ ចុះថ្ងៃទី 14.08.00 | -មិនមានគោលការណ៍អនុញ្ញាតិពីរដ្ឋាភិបាល |
| 25 | ក្រុមហ៊ុន Cambodia Shan Shoei | ខេត្ត កោះកុង | 3,830 | មិនមានឯកសារ | មិនទាន់ចុះ | លិខិតទីស្តីការគណៈរដ្ឋមន្ត្រី លេខ 1381 សជណ.សរ ចុះថ្ងៃទី 14.08.00 | -មិនមានគោលការណ៍អនុញ្ញាតិពីរដ្ឋាភិបាល |
| 26 | ក្រុមហ៊ុន អភិវឌ្ឍន៍ | ខេត្ត កំពង់ស្ពឺ | 20,000 | មិនមានឯកសារ | កិច្ចសន្យា | ប្រកាសរបស់ក្រសួងកសិកម្ម រុក្ខា | -លុបចោលកិច្ចសន្យា |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | កសិ-ឧស្សាហកម្ម អង្គរ | | | | ចុះថ្ងៃទី 04.11.94 | ប្រម៉ាញ់ និងនេសាទ លេខ 406 ប្រក.កសក.ផ.ផក ចុះថ្ងៃទី 15.09.98 ស្តីពីការលុបកិច្ចសន្យា សម្បទាន និងការដកហូតមកវិញ នូវដីសម្បទាន ពី ក្រុមហ៊ុន អភិវឌ្ឍន៍ កសិ-ឧស្សាហកម្ម អង្គរ | -ក្រុមហ៊ុនមិនអនុវត្តតាម កិច្ចសន្យា និង ការណែនាំ របស់ក្រសួង បន្តសុំ ពន្យាពេលបង់ប្រាក់កក់ ការប្រព្រឹត្តមិនត្រឹមត្រូវ |
| 27 | ក្រុមហ៊ុន ហ្វតថៃ | ខេត្ត មណ្ឌលគិរី | 200 | មិនមានឯកសារ | មិនទាន់ចុះ | លិខិតទីស្តីការគណៈរដ្ឋមន្ត្រី លេខ 1780 សជណ.កស ចុះថ្ងៃទី 25.10.05 | -បាត់ទំនាក់ទំនង |
| 28 | ក្រុមហ៊ុន ស អ៊ុត | ខេត្ត កំពង់ស្ពឺ | 1,550 | មិនមានឯកសារ | (គ្មានព័ត៌មាន) | មិនមានឯកសារ | -លុបចោលកិច្ចសន្យា |
| 29 | ក្រុមហ៊ុន តាឡាំ ផ្លេនថេស៊ិន ហូលឌីង អេសអិនឌី.ប៊ីអេឆឌី (Talam Plantation Holding Snd. Bhd) | ខេត្ត កោះកុង | 36,700 | លិខិតក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ លេខ 0297/635 កសក.ផ.ផក ចុះថ្ងៃទី 19.01.98 | កិច្ចសន្យា ចុះថ្ងៃទី 05.10.98 | -លិខិតទីស្តីការគណៈរដ្ឋមន្ត្រី លេខ 567 សជណ ចុះថ្ងៃទី 06.05.98<br>-លិខិតរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍ កម្ពុជា លេខ 4243/06 ករអក ចុះថ្ងៃទី 30.11.06<br>-សេចក្តីប្រកាស លេខ 431 ប្រក/513 កសក.ណផ ចុះថ្ងៃទី 12.12.06 | -លុបចោលកិច្ចសន្យា |
| 30 | ក្រុមហ៊ុន ឆាយណា ខាំបូឌា ស្តេត ហ្វាម អ៊ិនធឺណាស្យូណាល់ | ខេត្ត កោះកុង | 7,500 | លិខិត លេខ 364/98 ចុះថ្ងៃទី 13.02.98 | កិច្ចសន្យា ចុះថ្ងៃទី | -លិខិតទីស្តីការគណៈរដ្ឋមន្ត្រី លេខ 1138 សជណ ចុះថ្ងៃទី 19.05.98 | -លុបចោលកិច្ចសន្យា |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | (China Cambodia State Farm International) | | | | 06.10.98 | -លិខិត លេខ 33 សប្រទ ចុះថ្ងៃទី 30.09.98<br>-លិខិតរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា លេខ 4243/06 កអក ចុះថ្ងៃទី 30.11.06<br>-សេចក្តីប្រកាស លេខ 431 ប្រក/513 កសក.ណផ ចុះថ្ងៃទី 12.12.06 | |
| **សារុប** | | | **265,230 ហិកតា** | | | | |